វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៨-០៩





ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០០៨-២០០៩

*Annual Development Review*
*2008 - 2009*

ភ្នំពេញ ខែមីនា ឆ្នាំ២០០៩

*ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយ ចំណេះដឹង និងការកសាងសមត្ថភាព ។*

*CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

© ២០០៩ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-២០០៩
*Annual Development Review 2008-09*
ភ្នំពេញ ខែមីនា ឆ្នាំ២០០៩

ការបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អាសយដ្ឋាន ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤/៧០១, ៨៨៣-៦០៣, ៨៨១-៩១៦ / ០១២ ៨៦៧-២៧៨
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល: cdrimail@online.com.kh website: http://www.cdri.org.kh

កែសម្រួល និងរចនាដោយ: យូ-សិទ្ធីរិទ្ធ អ៊ុំ-ចាន់ថា និង គីម-ចិត្រ្តា
បោះពុម្ពនៅប្រទេសកម្ពុជា ដោយសហគ្រាសបោះពុម្ព ព្រីនម៉ាស្ទ័រ

# មាតិកា


បុព្វកថា........................................................................................................៧

បញ្ជីអក្សរកាត់ ................................................................................................៨

ជំពូក ១ សេចក្តីផ្តើម .............................................................................................. ៩

ជំពូក ២ បំរែបំរួលថ្លៃម្ហូបអាហារ និងផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ

មេរៀនទទួលបាន........................................................................................ ១៥

ជំពូក ៣ ផលប៉ះពាល់នៃម្ហូបអាហារមានថ្លៃខ្ពស់នៅកម្ពុជា.............................................................២១

ជំពូក ៤ អត្ថបទសង្ខេបស្តីពីផលប៉ះពាល់នៃការឡើងថ្លៃទំនិញទៅលើភាពក្រីក្រនៅក្នុងភូមិសិក្សា

ប្រាំបួននៅជនបទ: របកគំហើញបឋម...............................................................២៧

ជំពូក ៥ វិបត្តិហិរញ្ញវត្ថុសាកល: ផលប៉ះពាល់នៅក្នុងតំបន់ និងនៅប្រទេសកម្ពុជា.............................៣៩

ជំពូក ៦ ការដឹកនាំនៅថ្នាក់ភូមិ/ឃុំក្នុងឃុំបីនៃប្រទេសកម្ពុជា........................................................ ៥១

ជំពូក ៧ ការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា: តើត្រូវចំណាយប៉ុណ្ណា?................................................ ៥៧

ជំពូក ៨ ចំនួនម៉ោងធ្វើការ និងសុខភាពកុមារក្នុងវិស័យកសិកម្មនៅជនបទ: ភស្តុតាងផ្អែកលើ

ការពិសោធ និងផលប៉ះពាល់ចំពោះគោលនយោបាយ........................................................ ៦៥

បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ CDRI .......................................................................៧១

# បុព្វកថា

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-០៩ នេះ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានចេញផ្សាយនាឱកាសបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី៣ ដែលបានរៀបចំឡើងក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និងធនាគារអេអិនហ្សេដរ៉ូយ៉ាល់ នៅសណ្ឋាគារភ្នំពេញនាថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ។ ស្របតាមប្រធានបទ "ប្រទេសកម្ពុជា និងវិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព" សន្និសីទនេះមានរួមប្រជុំថ្នាក់ដឹកនាំមកពីខាងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសហគមន៍អ្នកផ្តល់ជំនួយ ដើម្បីត្រិះរិះពិចារណាពីសមិទ្ធផលដែលប្រទេសកម្ពុជាសំរេចបាន និងការងារទៅអនាគត ។ ដូចគ្នានឹងសន្និសីទចក្ខុវិស័យលើកមុនៗដែរ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី៣ នេះ ទទួលកិត្តិយសដ៏វិសេសដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ ។

សន្និសីទចក្ខុវិស័យនៅឆ្នាំនេះ មានសារៈសំខាន់ជាពិសេស ដោយរៀបចំឡើងចំពេលដែលតំបន់អាស៊ីអគ្នេយ៍ និងប្រទេសកម្ពុជាយើង កំពុងទទួលរងឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសាកល ។ សន្និសីទនេះជាឱកាសល្អឯកសំរាប់ចែករំលែកចំណេះដឹង និងធ្វើការជជែកវែកញែកលើផលប៉ះពាល់ដែលអាចមើលឃើញច្បាស់ រឺបំរុងមកដល់នៃវិបត្តិ ជាពិសេសសំរាប់វិស័យដ៏សំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា ពោលគឺ កសិកម្ម អភិវឌ្ឍន៍ជនបទ ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ថាមពល កម្មន្តសាលកម្ម អចលនទ្រព្យ និងការសាងសង់ ព្រមទាំងសំរាប់ជនក្រីក្រ និងជនងាយរងគ្រោះ នៅតាមសហគមន៍នានាក្នុងប្រទេសកម្ពុជា ហើយនិងសំរាប់ចម្លើយតបជាគោលនយោបាយ និងសកម្មភាព ។

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-០៩ ផ្តល់ការវិភាគលំអិតលើផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារនិងបញ្ហាចោទខាងគោលនយោបាយ ការពិនិត្យជាលក្ខណៈមីក្រូពីផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារនៅកំរិតភូមិ ផ្តល់លទ្ធផលរកឃើញមួយចំនួនក្នុងការស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ស្តីពីការដឹកនាំនៅថ្នាក់ភូមិ និងការពិនិត្យត្រួសៗពីផលប៉ះពាល់ដែលវិបត្តិហិរញ្ញវត្ថុសាកល អាចបង្កចំពោះតំបន់អាស៊ី ប្រទេសកម្ពុជា និងជាពិសេសចំពោះជនក្រីក្រ និងជនងាយរងគ្រោះ ។ របាយការណ៍ក៏ពិនិត្យផងដែរពីបញ្ហាផ្សេងៗទាក់ទិននឹងការអភិវឌ្ឍន៍ចំការកៅស៊ូនៅកម្ពុជា ទំនាក់ទំនងរវាងចំនួនម៉ោងធ្វើការ និងសុខភាពកុមារនៅតាមបណ្តាសហគមន៍ធ្វើកសិកម្មនៅជនបទ ។ អត្ថបទសង្ខេបជាភាសាខ្មែរទាំងនេះ បានរៀបចំឡើងដើម្បីពង្រីកការផ្សព្វផ្សាយខ្លឹមសាររបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ទៅដល់មជ្ឈដ្ឋានអ្នកអានភាសាខ្មែរ ។

*ឡារិ ស្រ្តេន្ទ*
*នាយកប្រតិបត្តិនៃ វិទ្យាស្ថាន CDRI*
*ខែមីនា ឆ្នាំ២០០៩*

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| BMI-age | សន្ទស្សន៍ម៉ាសរាងកាយ តាមអាយុ និងភេទ (Body Mass Index for Age and Sex) |
| CBNRM-LI | វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management Learning Institute) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| EIU | អង្គភាពស្រាវជ្រាវព័ត៌មានរបស់ទស្សនាវដ្តី Economist (Economist Intelligence Unit) |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (Food and Agriculture Organisation) |
| G3 economies | មហាអំណាចសេដ្ឋកិច្ចទាំង ៣ គឺសហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន (G3 economies—US, euro zone and Japan) |
| ILO | អង្គការពលកម្មអន្តរជាតិ (International Labour Organisation) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| NGO Forum | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia) |
| NIE | ប្រទេសឧស្សាហកម្មថ្មី (Newly Industrialising Economies) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ (National Institute of Statistics) |
| OECD | អង្គការសំរាប់សហប្រតិបត្តិការ សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (Organisation for Economic Co-Operation and Development) |

# ជំពូក ១៖ សេចក្តីផ្តើម

*ដោយលោកបណ្ឌិត Hossein Jalilian*

កាលពីឆ្នាំមុន មានកើតព្រឹត្តិការណ៍សំខាន់ៗ ៣ ដែលបានជះឥទ្ធិពលដល់សេដ្ឋកិច្ច និងសង្គមកិច្ចនៅកម្ពុជា ។ ព្រឹត្តិការណ៍ចំនួន ២ គឺកំណើនថ្លៃម្ហូបអាហារ និងវិបត្តិហិរញ្ញវត្ថុសាកល មានដើមកំណើត និងផលប៉ះពាល់ជាសាកល ។ ព្រឹត្តិការណ៍ទី ៣ គឺបញ្ហាព្រំដែនរវាងកម្ពុជា និងថៃ ដែលមានផលប៉ះពាល់តែក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ប៉ុណ្ណោះ ។ ទោះបីវាជាបញ្ហានយោបាយក៏ពិតមែន ប៉ុន្តែបញ្ហាខាងព្រំដែន អាចមានផលប៉ះពាល់រយៈពេលវែងដល់កម្ពុជា ដោយសារវិធានការបែងចែកធនធាន[១] និងការជះឥទ្ធិពលទៅលើឥរិយាបថអ្នកវិនិយោគ ។ *ទស្សនាវដ្តីអភិវឌ្ឍប្រចាំឆ្នាំ* លេខនេះ បានផ្តោតទៅលើព្រឹត្តិការណ៍ពីរខាងដើម ។ ក្នុងឯកសារនេះ អត្ថបទបីដំបូងពិនិត្យពីកំណើនថ្លៃម្ហូបអាហារ ។ អត្ថបទទី ៤ បង្ហាញពីផលប៉ះពាល់នៅកម្ពុជា និងក្នុងតំបន់នៃវិបត្តិហិរញ្ញវត្ថុសាកល ។ អត្ថបទបីបន្ទាប់មកទៀតបង្ហាញពីប្រធានបទសំខាន់ៗ ដែលអ្នកស្រាវជ្រាវរបស់ CDRI បានចូលរួមសិក្សា ។

អត្ថបទទី១ តាក់តែងដោយបណ្ឌិត Hossein Jalilian[២] រៀបរាប់ពីមេរៀនទទួលបានពីបំរែបំរួលថ្លៃម្ហូបអាហារ និងផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះ ។ កំណើនថ្លៃម្ហូបអាហារនៅប៉ុន្មានឆ្នាំចុងក្រោយនេះ បានបង្កើតឱ្យមានការជជែកវែកញែកជាច្រើនពីមូលហេតុ និងរបៀបកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់វា ដោយសារវាបានប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាជនក្រីក្រ និងជនក្រីក្រខ្លាំងនៅគ្រប់ទិសទី ។ អត្ថបទលើកឡើងថា វិបត្តិហិរញ្ញវត្ថុដែលកើតមានភ្លាមៗបន្ទាប់ពីកំណើនថ្លៃម្ហូបអាហារ បានបង្វែរការយកចិត្តទុកដាក់ចេញពីបញ្ហាថ្លៃម្ហូបអាហារវិញ ។

ថ្វីបើបញ្ហាមួយចំនួនដែលបង្កឡើងដោយកំណើនថ្លៃម្ហូបអាហារ បានធូរស្រាលមកវិញខ្លះហើយ ប៉ុន្តែវិបត្តិហិរញ្ញវត្ថុដែលកើតឡើងនាពេលបន្ទាប់ បានធ្វើឱ្យបញ្ហាទាំងនោះបែរជាធ្ងន់ធ្ងរ ។ ដោយឡែកការប្តេជ្ញាខាងហិរញ្ញវត្ថុរបស់អ្នកផ្តល់ជំនួយ និងអង្គការសំខាន់ៗ ដែលសំដៅដោះស្រាយបញ្ហាបង្កឡើងដោយកំណើនថ្លៃម្ហូបអាហារ និងផលប៉ះពាល់ចំពោះអ្នកក្រ គេមិនរំពឹងថានឹងអនុវត្តបានពេញលេញនោះទេ ហើយរឿងនេះអាចធ្វើឱ្យខូចខាតដល់កិច្ចប្រឹងប្រែងដោះស្រាយបញ្ហាធំ ។ ក្នុងករណីខ្លះ វិបត្តិហិរញ្ញវត្ថុបាននាំឱ្យមានការកាត់បន្ថយកម្មវិធីផ្គត់ផ្គង់អាហារមួយចំនួនដែលកំពុងអនុវត្តនៅប្រទេសក្រីក្រ ។ អត្ថបទនេះ មានពិនិត្យដោយសង្ខេបពីមូលហេតុនៃកំណើនថ្លៃម្ហូបអាហារ និងវិភាគពីផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះជាទូទៅ និងជាពិសេសនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតទៅលើមេរៀនទទួលបានពីបំរែបំរួលដែលបានកើតមានជាក់ស្តែង ។

---

១ ក្នុងសុន្ទរកថាបើកវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទី៣ សម្តេចនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា នឹងបង្កើនចំណាយការពារប្រទេសនៅក្នុងគំរោងថវិកាជាតិ ។ ចំណាយការពារជាតិ ជាខ្ទង់ចំណាយមួយដែលប្រកួតប្រជែងជាមួយនឹងកម្មវិធីនានាខាងសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីទាញយកធនធាន ។

២ លោកបណ្ឌិត Hossein Jalilian ជានាយកផ្នែកស្រាវជ្រាវនៅ CDRI ។

អត្ថបទទី២ រៀបរៀងដោយលោក ច័ន្ទ សុផល[៣] មានបង្ហាញពីផលប៉ះពាល់នៃកំនើនថ្លៃម្ហូបអាហារនៅកម្ពុជា ។ អត្ថបទនេះ ព្យាយាមបង្ហាញពីផលប៉ះពាល់នៃថ្លៃដ៏ខ្ពស់នៃម្ហូបអាហារទៅលើអ្នកប្រើប្រាស់ ជាពិសេសក្រុមជនងាយរងគ្រោះ និងទៅលើផលិតករ ។ អ្នកនិពន្ធក៏ប្រឹងប្រែងកំណត់ពីឱកាស និងឧបសគ្គនានា សំរាប់កសិករ ដើម្បីអាចទទួលបានប្រយោជន៍ ពីការឡើងថ្លៃផលិតផលកសិកម្ម ។ របាយការណ៍នេះប្រើប្រាស់ទិន្នន័យទី១ និងទី២ បានពីអង្កេតមួយធ្វើឡើងដោយ CDRI នៅខែមិថុនា ២០០៨ ដែលបានប្រើប្រាស់គំរូតាងតំណាងឱ្យទូទាំងប្រទេស ។ ការវិភាគទិន្នាការថ្លៃ ធ្វើឡើងដោយផ្អែកលើការប្រមូលតួលេខថ្លៃនៅទូទាំងក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត ដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងពាណិជ្ជកម្ម (MoC) ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ (MAFF) ។MAFF បានប្រមូលថ្លៃលក់ដុំនៃផលិតផល និងធាតុចូលកសិកម្មសំខាន់ៗក្នុងខេត្តមួយចំនួន ។ ដើម្បីប្រមូលទិន្នន័យទី១ គេបានធ្វើអង្កេតគ្រួសារចំនួន ២ប្រភេទ ។ ការពិភាក្សាតាមក្រុមគោលដៅក៏បានធ្វើឡើងដែរ ដើម្បីបំពេញឱ្យអង្កេតគ្រួសារ ។

អត្ថបទទី ៣ ចងក្រងដោយ សូ សុវណ្ណារិទ្ធិ[៤] បកស្រាយពីផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារទៅលើភាពក្រីក្រនៅតាមភូមិសិក្សាចំនួន ៩ ដែលបានចុះអង្កេតរួចហើយនៅក្នុងការសិក្សាពីការចាកផុតភាពក្រីក្រ ។ អត្ថបទពិនិត្យលើមេរៀនទទួលបានពីរបៀបដែលប្រទេសកម្ពុជា និងសហគមន៍កសិករកម្ពុជា អាចត្រៀមខ្លួន និងឆ្លើយតបបានកាន់តែប្រសើរទៅនឹងវិបត្តិសេដ្ឋកិច្ចក្នុងតំបន់ និងក្នុងពិភពលោក ។ អត្ថបទក៏បង្ហាញផងដែរពីអត្ថប្រយោជន៍ដែលភូមិនានាក្នុងអង្កេតបានទទួលពីគោលនយោបាយថ្មីៗរបស់រដ្ឋាភិបាល និងពីគំរិតដែលពួកគេអាចទប់ទល់នឹងកំណើនថ្លៃម្ហូបអាហារ ។ អត្ថបទក៏បានព្យាយាមពិនិត្យស្រាវជ្រាវពីផលប៉ះពាល់រយៈពេលខ្លីនៃកំណើនថ្លៃម្ហូបអាហារទៅលើអ្នកក្រដែលអាចធ្វើឱ្យពួកគេចុះក្រថែមទៀតបើសិនគ្មានវិធានការទប់ទល់ ។ ប៉ុន្តែក្នុងរយៈពេលវែង សំរាប់ប្រទេសដែលមានអតិរេកផលិតផលកសិកម្មច្រើនៗ ក៏អាចមានរឿងល្អដែរ ប្រសិនបើមានការចាត់វិធានការធានាឱ្យមានការប្រើប្រាស់ធនធាន ជាពិសេសដីធ្លីប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

អត្ថបទទី ៤ ដោយលោកបណ្ឌិត Jayant Menon[៥] ពិភាក្សាពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលនៅកំរិតក្នុងស្រុកនិងក្នុងតំបន់ ។គាត់រំលេចថាពិភពលោកកំពុងស្ថិតក្នុងវិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរដែលមិនធ្លាប់មានពីមុនមក ។ គេបានមើលឃើញហើយនូវការដួលរលំ និងជិតដួលរលំនៃស្ថាប័នហិរញ្ញវត្ថុធំៗជាច្រើន ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយដោយសារការខាតបង់លើអចលនទ្រព្យ កំណើនភាពមិនច្បាស់លាស់ទាក់ទិននឹងវត្តមាន និងទំហំនៃជំនួយហិរញ្ញវត្ថុព្រមទាំងការខូចខាតកំចីកាន់តែច្រើន ។ អ្នកវិភាគសេដ្ឋកិច្ចជាច្រើនរំលឹកថា ស្ថានការណ៍អាចវិវត្តអាក្រក់ជាងនេះទៀត ។ ទោះបីអាជ្ញាធររូបិយវត្ថុនៅទូទាំងពិភពលោក បានបញ្ចេញសាច់ប្រាក់យ៉ាងច្រើនមកទប់ទល់វិបត្តិក្តី ក៏ទីផ្សារហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុ នៅតែតានតឹង ។ កន្លងមក ប្រទេសអាស៊ាន+៣ អាចទប់ទល់នឹងភាពចលាចលនេះបានល្អជាងប្រទេសភាគច្រើនក្នុងពិភពលោក ។ តាមការព្យាករណ៍ចុងក្រោយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សំរាប់ឆ្នាំ២០០៩ ផសស នៅសហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ នឹងរួមចុះ ០,៧% និង ០,៥% ប៉ុន្តែតំបន់អាស៊ីនៅតែរំពឹង

---

៣ លោក ច័ន្ទ សុផល កាលពីមុនជាអ្នកគ្រប់គ្រងស្រាវជ្រាវជាន់ខ្ពស់នៅ CDRI ហើយបច្ចុប្បន្នជាទីប្រឹក្សាស្រាវជ្រាវ ។

៤ លោក សូ សុវណ្ណារិទ្ធិ ជាអ្នកស្រាវជ្រាវនៅ CDRI ។

៥ លោកបណ្ឌិត Jayant Menon ជាអគ្គសេដ្ឋវិទូនៅការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៃធនាគារអភិវឌ្ឍន៍អាស៊ី និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI ។

ថានឹងមានកំណើន ៧,១% ។ សូម្បីតែប្រទេសឧស្សាហកម្មថ្មី (NIE) ដែលតាមលក្ខណៈបច្ចេកទេសមានសេដ្ឋកិច្ចកំពុងតែធ្លាក់ចុះ ក៏រំពឹងថានឹងស្ទុះឡើងវិញដោយមានកំណើន ២,១% នៅឆ្នាំ២០០៩ ដែរ ។ សំរាប់កម្ពុជាកំណើនទំនងស្ថិតនៅក្នុងចន្លោះ ៣-៤% សំរាប់ឆ្នាំ២០០៩ និង ២០១០ ។ នេះជាការធ្លាក់ចុះយ៉ាងខ្លាំង បើធៀបនឹងកំណើនមានលេខពីរខ្ទង់ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ប៉ុន្តែវាក៏ជាអត្រាមួយល្អគួរសម ដែលនឹងជួយកាត់បន្ថយសម្ពាធអតិផរណា ។ តាមពិត ការថយកំណើន និងការធ្លាក់ចុះថ្លៃប្រេង និងផលិតផលផ្សេងទៀត ក៏មានចំណុចល្អដែរ ដោយវាជួយកាត់បន្ថយអតិផរណានៅកម្ពុជា ដែលបានក្លាយជាបញ្ហាចំបង តាំងពីមុនពេលមានវិបត្តិហិរញ្ញវត្ថុនេះម្លេះ ។

អត្ថបទទី៥ ដោយកញ្ញា ធន់ វិមាលា[៦] និងសហការី បកស្រាយពីការដឹកនាំនយោបាយថ្នាក់មូលដ្ឋាននៅកម្ពុជា ។ ដោយចាប់ផ្តើមពីការសន្មតថា មានគំលាតមួយរវាងរដ្ឋ-ប្រជាជន ការសិក្សាបានខិតខំស្វែងរកប្រភេទផ្សេងៗនៃអ្នកដឹកនាំ (រួមទាំងអ្នកដឹកនាំជាស្ត្រី) ព្រមទាំងលក្ខណៈសម្បត្តិ និងចំនុចផ្សេងៗនៃភាពពេញច្បាប់របស់អ្នកដឹកនាំទាំងនោះ ដើម្បីពិនិត្យថា នៅក្នុងដំណាក់កាលកំណែទំរង់វិមជ្ឈការនេះ តើអ្នកដឹកនាំទាំងនោះអាចតភ្ជាប់គំលាតនេះយ៉ាងដូចម្តេច ។ ក្នុងការសិក្សានេះ មានសម្ភាសន៍ជាមួយអ្នកភូមិ និងអ្នកដឹកនាំ នៅក្នុង ៦ភូមិជនបទ ក្នុង ៣ឃុំ នៃ ៣ខេត្តនៅកម្ពុជា ។ សំរាប់ការសិក្សាទ្រឹស្តី មានការសិក្សាឯកសារអន្តរជាតិ បែបក្លាស៊ិក និងបែបទូទៅ អំពីនិយមន័យនៃអំណាច សិទ្ធិអំណាច និងភាពពេញច្បាប់ ព្រមទាំងប្រព័ន្ធកូនចៅ/អ្នកទទួលផល ហើយនិងមេកើយ/អ្នកជួយឧបត្ថម្ភ ដែលកំណត់ពីគោលការណ៍ដឹកនាំ និងអភិបាលកិច្ចនៅតំបន់អាស៊ីអគ្នេយ៍ ហើយបន្ទាប់មក គឺការពិនិត្យពីប្រវត្តិអភិបាលកិច្ច និងភាពជាអ្នកដឹកនាំនៅកម្ពុជា ។

ការសិក្សាបានរកឃើញថា សំរាប់អ្នកបោះឆ្នោត អ្នកដឹកនាំដ៏សំខាន់ គឺមេភូមិ ក្រុមប្រឹក្សាឃុំ ចាស់ទុំនិងអាចារ្យ និងអ្នកមានទ្រព្យសម្បត្តិ ។ ចំពោះអ្នកដឹកនាំមានចំណេះដឹងខ្ពស់ និងបណ្តាអង្គការផ្អែកលើសហគមន៍វិញ អ្នកភូមិស្ទើរតែមិនដែលនឹកដល់ រឺក៏គិតថាគ្មានអ្វីពាក់ព័ន្ធគាត់ទេ ។ គណៈកម្មការភូមិ និងក្រុមប្រឹក្សាឃុំ មានកំរិតអប់រំជាមធ្យមទាបជាងកំរិតដែលតំរូវឱ្យមាន ដើម្បីបំពេញតួនាទី និងទទួលខុសត្រូវចំពោះមុខតំណែងបច្ចុប្បន្ន ហើយពួកគេភាគច្រើនមានអាយុចាប់ពី ៤៩ឆ្នាំឡើង ។ អ្នកដឹកនាំជាស្ត្រី ជាមធ្យមមានកំរិតអប់រំខ្ពស់ជាងអ្នកដឹកនាំជាបុរស និងមានអាយុតិចជាង ប៉ុន្តែពួកគេថ្មីថ្មោងណាស់ក្នុងតួនាទីជាអ្នកដឹកនាំ ហេតុនេះអាចជួបឧបសគ្គច្រើន ក្នុងនោះមានទាំងឥរិយាបថរបស់ក្រុមគ្រួសារផងដែរ ។ អ្នកដឹកនាំក្នុងការងាររដ្ឋបាល ត្រូវតែពាក់ព័ន្ធជាមួយគណបក្សនយោបាយ ប្រសិនបើចង់ទទួលបានភាពពេញច្បាប់ ហើយពួកគេត្រូវពឹងផ្អែកលើការគាំទ្រខាងហិរញ្ញវត្ថុ និងសិទ្ធិអំណាចពីគណបក្ស ដើម្បីអាចអភិវឌ្ឍឃុំ ។ អ្នកមានទព្យសម្បត្តិច្រើន តែងមានចំនេះដឹងច្រើនជាង និងមានទ្រព្យសម្បត្តិដែលអាចជួយដល់ការអភិវឌ្ឍឃុំ ដូច្នេះហើយពួកគេក៏កាន់តែមានអំណាច និងមានឥទ្ធិពលនៅក្នុងមូលដ្ឋាន ។ ពួកគេមានបណ្តាញភ្ជាប់ទំនាក់ទំនងទៅថ្នាក់ជាតិ ដែលពេលខ្លះអាចជួយឱ្យពួកគេធ្វើការរំលងអាជ្ញាធរមូលដ្ឋាន រកស៊ីផ្តាច់មុខ រឺប្រកបរបរអាជីវកម្ម រឺក៏ធ្វើសកម្មភាពខុសច្បាប់បានយ៉ាងស្រួល ។ ចាស់ទុំ និងអាចារ្យ អាចជួយបានច្រើនក្នុងការភ្ជាប់ទំនាក់ទំនងរវាងអាជ្ញាធរ និងប្រជាជន ដោយបំពេញតួនាទីជាអ្នកកៀងគរកំលាំងពលកម្ម និងរៃអង្គាសសំរាប់គំរោងផ្សេងៗនៅក្នុងភូមិ ដូចជា សកម្មភាពសាសនា ការជួយដោះស្រាយទំនាស់តូចតាចក្នុងគ្រួសារ និងការចូលរួមធ្វើផែនការជាមួយអាជ្ញាធរមូលដ្ឋាន ។ ពួកគាត់ត្រូវគ្នាជាមួយស្ទើរតែគ្រប់តួអង្គនៅក្នុងភូមិឃុំរបស់គាត់ ។ អ្នកដឹកនាំមានចំណេះដឹងខ្ពស់ចេញមុខ

៦ កញ្ញា ធន់ វិមាលា ជាអ្នកស្រាវជ្រាវនៅ វិបសអ ។

តែនៅពេលដែលទ្រព្យពួកគេកាន់កាប់ ស្ថិតក្នុងចំណោមធនធានដែលទទួលរងការគំរាមកំហែងប៉ុណ្ណោះ ។ រីឯអ្នកដឹកនាំជួយដល់ការអភិវឌ្ឍតែងផ្តល់តែជំនួយជាសំភារៈ និងមានសកម្មភាពយូរៗម្តង ហើយពួកនេះមិនស្នាក់នៅក្នុងឃុំទេ ។

ជាលទ្ធផលនៃកំណែទំរង់ គេរកឃើញថា គំលាតរវាងរដ្ឋ និងប្រជាជន ត្រូវបានតភ្ជាប់ ប៉ុន្តែដោយល្បឿនយឺតៗ មិនស្មើភាព និងក្នុងកំរិតតិចតួចប៉ុណ្ណោះ ។ ដើម្បីពន្លឿនដំណើរការកំណែទំរង់គឺ ទី១ គួរផ្តល់ឱ្យក្រុមប្រឹក្សាឃុំនូវមុខតំណែង និងសិទ្ធិអំណាច ដើម្បីអាចអនុវត្តតួនាទីដែលមានចែង ព្រមទាំងផ្តល់សិទ្ធិអំណាចសំរាប់ការប្រមូលពន្ធ ។ ការអនុវត្តដោយប្រយ័ត្នប្រយែងនូវច្បាប់រៀបចំអង្គការ អាចជួយឱ្យការផ្ទេរអំណាចនេះអនុវត្តបានសំរេច ។ ទី២ គួរបែងចែកមូលនិធិឃុំសង្កាត់ឡើងវិញ ដើម្បីជួយទប់ស្កាត់ការប្រែប្រួលខុសភាពដើមនៃគណនេយ្យភាព និងការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលបង្កឡើងដោយការឧបត្ថម្ភខាងហិរញ្ញវត្ថុ និងគោលនយោបាយគណបក្ស ។ ចាំបាច់ត្រូវមានវគ្គបណ្តុះបណ្តាលល្អៗ ដើម្បីជួយឱ្យក្រុមប្រឹក្សាឃុំសង្កាត់យល់ដឹងពីរឿងនេះ ។ ទី៣ គួរបង្កើតបរិយាកាសសំរួលដល់ការងារ ដូចជា ប្រាក់បៀវត្សរ៍ប្រសើរជាងនេះ ដើម្បីទាក់ទាញបេក្ខជនមានសមត្ថភាព និងកាត់បន្ថយអំពើពុករលួយតូចតាចនៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ។ ចំណុចចុងក្រោយ គួរលើកកំពស់យេនឌ័រ ដោយផ្តោតការយកចិត្តទុកដាក់លើកស្ទួយដល់ជីវភាពរបស់ស្ត្រី ជាជាងគ្រាន់តែបង្កើនចំនួនស្ត្រី នៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ រឺក្នុងវគ្គបណ្តុះបណ្តាលអ្នកដឹកនាំ ។

ការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា និងបន្ទុកចំណាយផ្សេងៗ ជាប្រធានបទនៃអត្ថបទទី ៦ ។ លោក យ៉ែម ដារារដ្ឋ[៧] និងសហការី បានបកស្រាយថា ការកាប់បំផ្លាញព្រៃឈើជាបញ្ហាបរិស្ថានដ៏សំខាន់ជាងគេមួយក្នុងពិភពលោក ។ គេតែងគិតថា ការអភិវឌ្ឍចំការកៅស៊ូជាមូលហេតុចំបងនៃការកាប់បំផ្លាញព្រៃឈើនៅប្រទេសកំពុងអភិវឌ្ឍ ។ នៅប្រទេស ជាច្រើនក្នុងតំបន់នេះ ផ្ទៃដីដាំកៅស៊ូនឹងកើនឡើងជាបន្តបន្ទាប់ ។ កំនើនតំរូវការដើមកៅស៊ូ និងថ្លៃខ្ពស់នៃជ័រកៅស៊ូ គឺជាកំលាំងសំខាន់ដែលជំរុញការពង្រីកផ្ទៃដីដាំកៅស៊ូ ។ ការសិក្សាមួយបានធ្វើឡើងដោយប្រៀបធៀបតំលៃដោយផ្ទាល់ និងប្រយោលនៃការប្រើប្រាស់ដីពីមុន ជាមួយនឹងការយកដីទៅដាំកៅស៊ូ ។ ការសិក្សាបានប្រើប្រាស់ប្រាក់ចំណូលប៉ាន់ស្មានរបស់ចំការកៅស៊ូមានវ័យខុសៗគ្នានៅខេត្តកំពង់ចាម និងកំពង់ធំ ដើម្បីធ្វើការគណនា ។ គេបានជ្រើសរើស ១៦៤គ្រួសារ មកពី ៧ភូមិដែលស្ថិតនៅក្នុង រឺនៅក្បែរបរិវេណចំការកៅស៊ូបានជ្រើសរើស ដើម្បីពិនិត្យមើលពីកំរិតប្រែប្រួលរបស់ធនធានធម្មជាតិ និងប្រាក់ចំណូលបានពីកៅស៊ូ នៅមុនពេល និងក្រោយពេលបង្កើតចំការកៅស៊ូ ។ ការចុះទៅសិក្សាដល់ចំការ បានធ្វើឡើងនៅឆ្នាំ២០០៧ ។

ការស្រាវជ្រាវរកឃើញថា ក្រោយពីបង្កើតចំការកៅស៊ូ ជីវភាពរបស់ប្រជាជនប្រែប្រួលយ៉ាងឆាប់រហ័ស ។ ពួកគេបានបាត់បង់ប្រភពចំណូលចំបងរបស់ខ្លួន ពីព្រោះត្រូវបានហាមឃាត់លែងឱ្យទៅរកអុស រឺបេះប្រមូលអនុផលព្រៃឈើ ដូចកាលពីមុន ។ ដីសំរាប់ដាំដំណាំ ក៏បានបាត់បង់ ហើយទិន្នផលស្រូវក៏ថយចុះ ។ មនុស្សត្រូវគេហាមមិនឱ្យចូលទៅចំការកៅស៊ូ ហើយសូម្បីតែគោក្របីក៏គេហាមមិនឱ្យនាំទៅស៊ីស្មៅនៅទីនោះដែរ ។ ប៉ុន្តែក្រុមហ៊ុនក៏បានកសាងហេដ្ឋារចនាសម្ព័ន្ធខ្លះៗ ជាពិសេស ផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យ ។ ការសិក្សាបានផ្តល់របកគំហើញមួយចំនួនដូចតទៅ (១) ពិតមែនតែគ្មានតួលេខប៉ាន់ស្មានពីបន្ទុកចំណាយលើការខូចខាតបរិស្ថានដែលបង្កឡើងដោយចំការកៅស៊ូក្តី ប៉ុន្តែចំការកៅស៊ូខ្នាតធំអាចផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចបានច្រើនជាងបន្តិចដែរ បើធៀបនឹងការអភិរក្សព្រៃឈើ

---

៧ លោក យ៉ែម ដារារដ្ឋ ជាអ្នកស្រាវជ្រាវ និងអ្នកសំរបសំរួលកម្មវិធីធនធានធម្មជាតិ និងបរិស្ថាននៅ CDRI ។

(២) ការខូចខាតបរិស្ថានបណ្តាលពីការប្រែក្លាយដីព្រៃ ទៅជាចំការកៅស៊ូ មានទំហំធំធេងណាស់ ដូច្នេះគួរបង្កើតឱ្យមានការបង់សេវាការពារបរិស្ថាន សំរាប់គំរោងប្រែក្លាយដីព្រៃ ដើម្បីកាត់បន្ថយការខូចខាត និង (៣) គំរោងប្រែក្លាយដីព្រៃ ត្រូវមានចំណែកសង្គមកិច្ចមួយដែលមានអាទិភាពខ្ពស់បំផុត ជាពិសេសសំរាប់សម្បទានដីសេដ្ឋកិច្ច ដើម្បីឱ្យមានផលប្រយោជន៍ធ្លាក់ទៅដល់ដៃប្រជាជនមូលដ្ឋាន ។

អត្ថបទចុងក្រោយ ដោយលោកបណ្ឌិត ហ៊ាន ភូមិន្ទ[៨] សិក្សាពីម៉ោងធ្វើការ និងសុខភាពកុមារក្នុងកសិកម្មនៅជនបទ ។ អត្ថបទនេះ ថ្លឹងថ្លែងពីភស្តុតាងជាក់ស្តែង និងផលប៉ះពាល់ខាងគោលនយោបាយ សំរាប់កុមារជាពលករដោយប្រើប្រាស់ទិន្នន័យប្រមូលបានពីការចុះអង្កេតដល់កន្លែងនៅខែតុលា ២០០៦ ស្តីពីចំនួនម៉ោងធ្វើការរបស់កុមារនៅក្នុងការងារកសិកម្ម និងផលប៉ះពាល់លើសុខភាពកុមារ ។ ម្យ៉ាងទៀត បើសិនក៏រិតពលកម្មបច្ចុប្បន្នរបស់កុមារនៅក្នុងការងារកសិកម្ម បានប៉ះពាល់ដល់សុខភាពពួកគេមែន ការសិក្សានេះ មានគោលដៅវិភាគរកចំនួនម៉ោងជាមធ្យមដែលកុមារអាចចូលរួមក្នុងការងារកសិកម្មដោយមិនរំខានដល់ការលូតលាស់និងសុខភាពរបស់ពួកគេ ។ការសិក្សារកឃើញថាពលកម្មធ្វើការងារកសិកម្ម មានផលប៉ះពាល់អវិជ្ជមានដល់សុខភាពកុមារ បើសិនកុមារធ្វើការលើសពី ២,៥ម៉ោងក្នុងមួយថ្ងៃ ។ ការសិក្សាបង្ហាញទៀតថា កំរិតសុខភាពកុមារ ក៏ជាប់ទាក់ទងច្រើននឹងលទ្ធភាពបានប្រើប្រាស់បណ្តាញព័ត៌មាន ដូចជា វិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន ព្រមទាំងកត្តាមួយចំនួនទៀត ដូចជា ទឹក និងអនាម័យដែរ ។ លទ្ធផលនៃការស្រាវជ្រាវ អាចមានប្រយោជន៍ដល់ការកសាងគោលនយោបាយ សំរាប់ពលកម្មកុមារក្នុងការងារកសិកម្ម ព្រមទាំងគោលនយោបាយធំទូលាយសំរាប់សង្គមទាំងមូលទៀតផង ។

៨ លោកបណ្ឌិត ហ៊ាន ភូមិន្ទ ជាអតីតអ្នកស្រាវជ្រាវ និងអ្នកសំរបសំរួលកម្មវិធីអភិវឌ្ឍន៍សង្គមនៅ វិបសអ ។

# ជំពូក ២
# បំរែបំរួលថ្លៃម្ហូបអាហារ និងផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ មេរៀនទទួលបាន

*ដោយលោកបណ្ឌិត Hossein Jalilian ជានាយកផ្នែកស្រាវជ្រាវនៅ CDRI*

## ១. សេចក្ដីផ្ដើម

នៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ម្ហូបអាហារបានឡើងថ្លៃ ជាពិសេសអង្ករដែលជាអាហារមូលដ្ឋាននៅក្នុងប្រទេសជាច្រើន បាននាំឱ្យមានការពិភាក្សាវែកញែកច្រើនណាស់ពីកត្តាដែលបង្កស្ថានភាពនេះឡើង និងវិធីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃកំណើនថ្លៃទាំងនេះ ទៅលើសុខុមាលភាពរបស់ប្រជាជនក្រីក្រនៅគ្រប់ទីកន្លែង ។ ប៉ុន្តែគួរឱ្យស្តាយ វិបត្តិហិរញ្ញវត្ថុដែលផុសឡើងភ្លាមៗ បន្ទាប់ពីការឡើងថ្លៃ ម្ហូបអាហារនាពេលថ្មីៗ បានបង្វែរចំណាប់អារម្មណ៍ចេញពីម្ហូបអាហារ ទៅផ្ដោតលើវិបត្តិហិរញ្ញវត្ថុវិញ ។ ថ្វីបើបញ្ហាមួយចំនួនដែលបង្កឡើងដោយកំនើនថ្លៃម្ហូបអាហារបានធូរស្រាលមួយកំរិតដោយសារមានការចុះថ្លៃមួយចំនួន ប៉ុន្តែវិបត្តិហិរញ្ញវត្ថុដែលផុសឡើងជាបន្តមកទៀត បានធ្វើឱ្យបញ្ហាទាំងនោះធ្ងន់ធ្ងរថែមទៀត ។ ផលប៉ះពាល់ភ្លាមៗនៃវិបត្តិហិរញ្ញវត្ថុ មិនសូវធ្ងន់ធ្ងរទេចំពោះប្រទេសដែលមិនទាន់ធ្វើសមាហរណកម្មពេញលេញទៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក រឺដែលមានវិស័យហិរញ្ញវត្ថុមិនទាន់អភិវឌ្ឍខ្លាំង ។ ប៉ុន្តែ ក្នុងរយៈពេលខ្លី និងមធ្យម ផលប៉ះពាល់អាចកាន់តែធ្ងន់ធ្ងរ ដោយសារផលប៉ះពាល់ជាប្រយោលដែលវិបត្តិហិរញ្ញវត្ថុអាចបង្កទៅលើពាណិជ្ជកម្ម និងលំហូរវិនិយោគជាដើម ។ ការធ្លាក់ចុះសេដ្ឋកិច្ច និងការថយកំណើនសកម្មភាពសេដ្ឋកិច្ចនៅប្រទេសសំខាន់ៗ ដូចជា សហរដ្ឋអាមេរិក អឺរ៉ុប និងជប៉ុន អាចប៉ះពាល់អវិជ្ជមានដល់ការនាំចេញទំនិញទៅកាន់ប្រទេសទាំងនោះ ព្រមទាំងលំហូរវិនិយោគចេញមកពីប្រទេសទាំងនោះ ហើយរឿងនេះក៏ដូចគ្នាដែរសំរាប់បណ្ដាប្រទេសជាសមាជិកនៃអង្គការសំរាប់សហប្រតិបត្តិការ សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD) ដូចជា កូរ៉េខាងត្បូងដែលជាប្រទេសដ៏សំខាន់មួយនៅអាស៊ីខាងកើត ។ សំរាប់ប្រទេសកម្ពុជា ផលប៉ះពាល់ដោយប្រយោលនេះអាចធ្ងន់ធ្ងរជាងផលប៉ះពាល់ដោយផ្ទាល់ ក្នុងនេះការនាំចេញសំលៀកបំពាក់របស់កម្ពុជា ដែលតំណាងឱ្យ ៩០% នៃការនាំចេញសរុប បានថយចុះជាបណ្ដើរៗ ធ្វើឱ្យមានការកាត់បន្ថយចំនួនកម្មករ[១] ។ ការងារក្នុងវិស័យកាត់ដេរ ជាប្រភពចំនូលចំបងរបស់កម្មករភាគច្រើន ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ។ ដូច្នេះនៅពេលពួកគេបាត់បង់ការងារ នឹងមានគ្រួសារងាយរងគ្រោះជាច្រើនកាន់តែមានជីវភាពលំបាកខ្លាំងឡើង ។

អត្ថបទនេះ មានគោលដៅពិនិត្យត្រួសៗពីមូលហេតុនៃកំនើនថ្លៃម្ហូបអាហារ និងវិភាគពីផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះជាទូទៅ និងជាពិសេសនៅក្នុងប្រទេសកម្ពុជា ដោយផ្ដោតទៅលើមេរៀនទទួលបានពីបំរែបំរួលដែលកើតមានជាក់ស្ដែងក្នុងពេលកន្លងមក ។

១ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៩ ធ្នូ ២០០៨ ។

## ២. បំរែបំរួលថ្លៃម្ហូបអាហារនៅក្នុងប្រវត្តិសាស្ត្រ

នៅក្នុងប្រវត្តិសាស្ត្រ ថ្លៃម្ហូបអាហារដែលតំណាងឱ្យដោយផលិតផលកសិកម្មមួយចំនួន មាននិន្នាការធ្លាក់ចុះតាំងពីឆ្នាំ១៩៧១ ដូចមានបង្ហាញក្នុងក្រាហ្វិក ២.១ ។ ក្នុងរយៈពេលនោះ ថ្វីបើថ្លៃពិតនៃផលិតផល បានស្ទុះឡើងយ៉ាងខ្លាំងនៅពេលខ្លះៗក្តី ប៉ុន្តែជារួមថ្លៃផលដំណាំជាអាហារ បានដើរតាមនិន្នាការធ្លាក់ចុះជាប្រវត្តិសាស្ត្ររបស់វា ។ ដូចនេះ បើពិនិត្យតាមនិន្នាការរយៈពេលវែងជាប្រវត្តិសាស្ត្រនេះ កំណើនថ្លៃហាក់ដូចគ្មានការខុសប្លែកពីអ្វីដែលធ្លាប់កើតមានក្នុងអតីតកាលថ្មីៗនេះទេ ។ ប៉ុន្តែគេឃើញមានចំណុចគួរកត់សំគាល់មួយ រវាងកំណើនថ្លៃបច្ចុប្បន្ន និងកំណើនថ្លៃដែលមានកើតឡើងតាំងពីឆ្នាំ១៩៧១ ។ កំណើនថ្លៃបច្ចុប្បន្ន បានកើតឡើងនៅចំពេលដែលថ្លៃម្ហូបអាហារកំពុងមាននិន្នាការកើនឡើង ។ ដូចមានបង្ហាញច្បាស់ក្នុងក្រាហ្វិក ១ ថ្លៃផលិតផលទាំងអស់សុទ្ធតែមាននិន្នាការកើនឡើងតាំងពីចុងទសវត្សរ៍១៩៩០ រហូតមក ។ នៅពេលនេះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់យោបល់ពីអ្វីដែលអាចកើតមានក្នុងរយៈពេលវែង ប៉ុន្តែគេរំពឹងថា និន្នាការឡើងថ្លៃនឹងបន្តទៅអនាគតទៀត ដោយផ្អែកលើបំរែបំរួលដែលកើតមានក្នុងតំរូវការ ផលដំណាំអាហារភាគច្រើនដែលគេត្រូវប្រើការទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ។ OCED-FAO (២០០៨) បានព្យាករណ៍ថា ផលដំណាំមួយចំនួន ដូចជា ធញ្ញជាតិ អង្ករ និងគ្រាប់រុក្ខជាតិយកប្រេង នឹងឡើងថ្លៃពី ១០% ទៅ ៣៥% ក្នុងរយៈពេល ១០ឆ្នាំខាងមុខ បើធៀបនឹងរយៈពេល ១០ឆ្នាំកន្លងទៅ ។

នៅមានកត្តាសំខាន់ៗមួយចំនួន ដែលបាននាំឱ្យតំរូវការផលិតផលអាហារកើនឡើង ។ កត្តាចំបងក្នុងនោះគឺកំណើនតំរូវការដែលផុសចេញពីបណ្តាប្រទេសមានកំណើនសេដ្ឋកិច្ចលឿនមួយចំនួន ដូចជា ចិន និងឥណ្ឌា ព្រមទាំងប្រទេសខ្លះទៀត ដូចជា ប្រេស៊ីល ឥណ្ឌូនេស៊ី និងអាហ្វ្រិកខាងត្បូងជាដើម ។ កត្តាឯទៀតមានដូចជា កំណើនតំរូវការផលដំណាំអាហារខ្លះសំរាប់បំរើផលិតកម្មជីវឥន្ធនៈ ហើយនិងកំណើនតំរូវការផលដំណាំសំរាប់លក់កេញ្ចយកចំណេញ ។ លក្ខខណ្ឌអាកាសធាតុមិនអំណោយផលក្នុងប៉ុន្មានឆ្នាំថ្មីៗ ក៏បានចូលរួមបង្កភាពមិនទៀងទាត់ និងប៉ះពាល់ដល់ការផ្គត់ផ្គង់ផលិតផលកសិកម្មជាទូទៅផងដែរ ។

កំណើនតំរូវការក្នុងស្រុកនៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដែលមានកំណើនសេដ្ឋកិច្ចលឿន បានជះឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោលទៅលើតំរូវការអន្តរជាតិនូវផលិតផលជាទូទៅ រួមទាំងដំណាំអាហារ ហើយនិងកំរិតថ្លៃរបស់វា ។ កំណើនតំរូវការផលិតផល អាចកើតមានដោយផ្ទាល់ដោយសារកំណើនការប្រើប្រាស់ ឬកើតមានដោយប្រយោលតាមរយៈតំរូវការនូវផលិតផល (ដូចជា សាច់ មាន់ទា ទឹកដោះគោ) ដែលត្រូវប្រើប្រាស់កសិផលយ៉ាងច្រើនដើម្បីផលិតវាឡើង ។ យោងតាមកំណើនតំរូវការមុខទំនិញទាំងនោះនៅលើទីផ្សារអន្តរជាតិ និងការផ្គត់ផ្គង់មិនគ្រប់គ្រាន់ក្នុងរយៈពេលខ្លី ដូច្នេះក៏មានសំពាធជំរុញឱ្យថ្លៃទំនិញនៅអន្តរជាតិកើនឡើង ដូចបានពិនិត្យឃើញនាពេលថ្មីៗ ។

ព្រមគ្នានឹងកំនើនតំរូវការផ្ទាល់ និងប្រយោលនូវផលដំណាំជាអាហារ ក៏មានកំនើនតំរូវការផលដំណាំខ្លះយ៉ាងច្រើន ឧទាហរណ៍ ពោត សំរាប់ការប្រើប្រាស់ជាលក្ខណៈឧស្សាហកម្មដើម្បីផលិតជីវឥន្ធនៈ ដូចជា អេតាណុល ជាដើម ។

កត្តាចំបងទីបីដែលបង្កកំណើនថ្លៃនាពេលថ្មីៗ និងអស្ថិរភាពថ្លៃ គឺកំណើនតំរូវការផលដំណាំអាហារ សំរាប់ជួញកេញ្ចយកចំណេញ ។ រឿងនេះអាចកើតមានឡើងបាន ដោយសារកំរិតសមាហរណកម្មកាន់តែខ្លាំងនៃទីផ្សារពិភពលោក និងការផ្លាស់ប្តូរក្នុងបច្ចេកវិទ្យាដែលជួយសំរួលដល់ការធ្វើជំនួញ ។ កំណើនការជួញដូរកេងយកចំណេញក៏ផុសចេញមួយចំណែកពីភាពមិនទៀងទាត់នៃផលិតកម្មដែលបណ្តាលមកពីលក្ខខណ្ឌអាកាសធាតុ មិនអំណោយផល និងភាពមិនទៀងទាត់នៃតំរូវការ ។

ក្រាហ្វិក ២.១: ថ្លៃប្រើប្រាស់អាហារពីឆ្នាំ១៩៧១-២០០៧ ដែលបង្ហាញដល់ឆ្នាំ២០១៧




*ប្រភព: ការព្យាករណ៍កសិកម្ម ២០០៨-២០១៧ របស់ OECD-FAO*

## ៣. ផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារទៅលើអ្នកក្រ

ផលប៉ះពាល់នៃកំណើនថ្លៃអ្វីមួយទៅលើអ្នកប្រើប្រាស់ វាប្រែប្រួលទៅតាមលទ្ធភាពដែលអ្នកប្រើប្រាស់ អាចរកអ្វីមកជំនួសទំនិញនោះបាន ។ នៅពេលទំនិញជាក់លាក់ណាមួយឡើងថ្លៃ អ្នកប្រើប្រាស់អាចងាកទៅរកទំនិញជំនួសដែលមានតំលៃថោកជាង ។ ប៉ុន្តែនៅពេលបំរែបំរួលថ្លៃជាប់ទាក់ទងនឹងមុខទំនិញមួយក្រុម ដូចជាផលិតផលអាហារជាដើម លទ្ធភាពរកអ្វីជំនួសបានវាត្រូវថយចុះ ហើយយន្តការសំរាប់ដំណោះស្រាយ ក៏ខុសគ្នាដែរ ។ ចំពោះផលិតផលអាហារ លទ្ធភាពរកអ្វីមកជំនួសបាន គឺមានតិចតួចបំផុតសំរាប់អ្នកក្រ ។

របស់ជំនួស ជួនកាលក៏មានផលប៉ះពាល់មិនល្អដែរ ។ កំណើនថ្លៃអាហារ អាចបង្វែរការបរិភោគចេញពីគ្រាប់ធញ្ញជាតិ ទៅរករបស់ជំនួសដូចជាត្រីជាដើម ដែលនាំឱ្យធនធាននេះត្រូវវិហិនហោច ។ហេតុការណ៍នេះ ហាក់ដូចកើតមានឡើងហើយនៅកម្ពុជា ។ ការនេសាទហួសកំរិតវាផុសចេញមួយផ្នែកពីកំណើនថ្លៃម្ហូបអាហារ ដែលនាំឱ្យបរិមាណត្រីក្នុងបឹងទន្លេសាប និងទន្លេ-ស្ទឹងនានាថយចុះយ៉ាងខ្លាំង[២] ។

---

២ ការថយចុះស្តុកត្រីនៅកម្ពុជា ក៏កំណត់ដែរថា មកពីការនាំចេញត្រីទៅកន្លែងផ្សេងៗដូចជា ថៃ និងប្រទេសឯទៀតក្នុងតំបន់ ។

កំណើនថ្លៃម្ហូបអាហារវាប៉ះពាល់ខ្លាំងប៉ុណ្ណាទៅលើគ្រួសារ គឺជាប់ទាក់ទងជាសំខាន់ទៅនឹងភាគរយនៃប្រាក់ចំណូលដែលគ្រួសារបែងចែកទៅលើចំណាយលើម្ហូបអាហារ ។ ប្រទេសក្រីក្រ និងគ្រួសារក្រីក្រក្នុងប្រទេសនីមួយៗតែងចំណាយច្រើនជាងទៅលើម្ហូបអាហារ បើធៀបនឹងប្រទេសធូរធារ និងគ្រួសារធូរធារ ។ ចំណាយលើម្ហូបអាហារគិតជាភាគរយនៃចំណូលក្នុងមនុស្សម្នាក់ តែងធ្លាក់ចុះ នៅពេលចំណូលកើនឡើង ។ គិតជាមធ្យម ប្រទេសក្រីក្រតែងចំណាយទៅលើម្ហូបអាហារ អស់ប្រាក់ចំណូលមួយភាគធំជាងប្រទេសធូរធារ ។

ដោយសារអតិផរណាមានអត្រាខុសគ្នាសំរាប់ទំនិញម្ហូបអាហារ និងទំនិញមិនមែនម្ហូបអាហារ ដូច្នេះគ្រួសារក្នុងក្រុមផ្សេងគ្នា អាចទទួលផលប៉ះពាល់ខុសគ្នា អំពីកំណើនថ្លៃម្ហូបអាហារ ។ យោងតាមថ្លៃម្ហូបអាហារដែលកើនឡើងខ្លាំងគួរសមនាពេលថ្មីៗ គេរំពឹងថា ស្រទាប់ក្រីក្រនៅក្នុងសង្គម នឹងត្រូវប៉ះពាល់ធ្ងន់ធ្ងរជាងពួកគ្រួសារដែលមានជីវភាពធូរធារ ។

បំរែបំរួលនៃថ្លៃទំនិញម្ហូបអាហារ ក៏ជាប់ទាក់ទងដោយផ្ទាល់ទៅនឹងប្រាក់បៀវត្សរ៍ដែរ ។ នៅពេលថ្លៃទំនិញកើនឡើង ប្រាក់បៀវត្សរ៍ទំនងត្រូវកើនឡើងតាមក្រោយដែរ ។ នៅពេលបៀវត្សរ៍កើនឡើង ចំណូលសរុបរបស់គ្រួសារ និងការប្រើប្រាស់ទំនិញរបស់គ្រួសារ ក៏កើនឡើងដែរ ។ ដូចនេះដើម្បីថ្លឹងថ្លែង ពីឥទ្ធិពលនៃកំណើនថ្លៃទំនិញ គេត្រូវពិចារណាជាសំខាន់ថាតើបំរែបំរួលថ្លៃទំនិញនោះ មានអមទៅដោយបំរែបំរួលនៅក្នុងប្រាក់បៀវត្សរ៍ដែរឬទេ ។ សំរាប់ប្រទេសកម្ពុជាទាំងមូល ការអង្កេតដែលធ្វើឡើងនាពេលថ្មីៗ បានបង្ហាញថា ប្រាក់កំរៃសំរាប់កម្មករគ្មានជំនាញ បានកើនឡើងប្រហែល ៥០% ធៀបនឹងឆ្នាំមុន[៣] ។

កត្តាមួយទៀតដែលចូលរួមចំណែកដែរ គឺតួនាទីនៃអ្នកកសាងគោលនយោបាយ អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ ក្នុងប្រទេសមួយចំនួន នៅពេលជួបការលំបាកកាន់តែខ្លាំងឡើង ប្រជាជនក្រីក្រតែងទទួលបានជំនួយគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ ជំនួយគាំទ្រនេះ អាចមានទម្រង់ជាសំភារៈ ឬជាឧបត្ថម្ភធនជួយចេញថ្លៃទំនិញ របបស្បៀងអាហារ ប័ណ្ណម្ហូបអាហារ ស្បៀងពលកម្ម អាហារតាមសាលារៀនជាដើម ។ សំរាប់ការឡើងថ្លៃនាពេលចុងក្រោយនេះ បន្ទាប់ពីមានការឃើតយ៉ាវខ្លះក្នុងករណីមួយចំនួន អ្នកផ្តល់ជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក៏បានចាប់ផ្តើមអនុវត្តកម្មវិធីជំនួយឧបត្ថម្ភផ្សេងៗនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ។ ប៉ុន្តែសំរាប់កម្មវិធីខ្លះ នៅមុនពេលវាចាប់ដំណើរការ វិបត្តិហិរញ្ញវត្ថុក៏ផ្ទុះឡើង ហើយបានដាក់កំហិតយ៉ាងធ្ងន់ធ្ងរទៅលើធនធានសំរាប់អនុវត្តកម្មវិធីជំនួយដែលបានសន្យា ។ ឧទាហរណ៍ អង្គការកម្មវិធីស្បៀងអាហារពិភពលោក ដែលត្រូវប្រឈមមុខនឹងការលំបាក ផ្នែកហិរញ្ញវត្ថុ បានកាត់បន្ថយការទ្រទ្រង់ដល់កម្មវិធីជំនួយឧបត្ថម្ភដែលមានស្រាប់របស់ខ្លួនខ្លះ ដូចជា របបអាហារនៅតាមសាលារៀនជាដើម ដែលរុញច្រានឱ្យគ្រួសារមួយចំនួនកាន់តែលំបាកតោកយ៉ាកថែមទៀត ។ ជំនួយទ្វេភាគី និងពហុភាគី សំរាប់ជួយសង្គ្រោះប្រទេសមួយចំនួនដែលប៉ះពាល់ខ្លាំងដោយសារកំណើនថ្លៃម្ហូបអាហារ ត្រូវបានកាត់ចេញ និងមិនអនុវត្តឡើយ[៤] ។

---

៣ ចំពោះព័ត៌មានលំអិត សូមអានឯកសារ CDRI (2008)

៤ ប៉ុន្តែនៅប្រទេសកម្ពុជា សំរាប់គំរោងជំនួយសង្គ្រោះបន្ទាន់ខាងស្បៀងអាហារ មានការបែងចែកមូលនិធិចំនួន ៤០លានដុល្លារ (ធនាគារ ADB ៣៥លានដុល្លារ និងរដ្ឋាភិបាលកម្ពុជា ៥លានដុល្លារ) សំរាប់ជួយគ្រួសារក្រីក្រ ។ គំរោងនេះកំពុងអនុវត្តសព្វថ្ងៃ ដោយមានការបែងចែកស្បៀងអាហារដោយឥតគិតថ្លៃនៅខែតុលា ២០០៨ ។

នៅប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ជាពិសេសប្រទេសមានសេដ្ឋកិច្ចអភិវឌ្ឍន៍តិច ដូចជានៅកម្ពុជា ដែលមានប្រជាជនភាគច្រើនរស់នៅតំបន់ជនបទ និងធ្វើសកម្មភាពខាងកសិកម្ម ដូចជា ផលិតផលដំណាំអាហារជាដើម លក្ខខណ្ឌដែលត្រូវពិចារណា គឺកំរិតដែលគ្រួសារអាចផលិតបានគ្រប់ហូបខ្លួនឯង រឺមិនគ្រប់ ។ ឧទាហរណ៍ បើសិនលក្ខខណ្ឌឯទៀតគ្មានការផ្លាស់ប្តូរទេ កំណើនថ្លៃទំនិញម្ហូបអាហារ គ្មានឥទ្ធិពលអ្វីទេទៅលើកសិករដែលផលិតបានតែមួយរស់ ។ ដូចបានពិភាក្សានៅខាងលើកំណើនថ្លៃផលដំណាំជាអាហារក្នុងករណីយើងនេះ វាផ្សារភ្ជាប់ទៅនឹងកំណើថ្លៃយ៉ាងច្រើននៃថាមពល និងជីគីមី ។ សំរាប់កសិករផលិតបានមួយរស់ជាអ្នកត្រូវប្រើ ធាតុចូលដែលឡើងថ្លៃ ដូចជា ប្រេងឥន្ធនៈ និងជីគីមី ពួកគាត់ក៏ទទួលរងគ្រោះដែរ ។ សំរាប់គ្រួសារដែលផលិតស្បៀងមិនគ្រប់ហូប បើសិនលក្ខខណ្ឌឯទៀតគ្មានប្រែប្រួលទេ កំណើនថ្លៃម្ហូបអាហារអាចប៉ះពាល់ដល់សុខមាលភាព ស្ថានភាពក្រីក្ររបស់ពួកគេ ។

អ្នកដែលទំនងទទួលបានផលប្រយោជន៍ពីស្ថានភាពនេះ គឺបណ្តាប្រទេស និងក្រុមប្រជាជន មានអតិរេកស្បៀង ។ ប៉ុន្តែរឿងនេះក៏ត្រូវផ្អែកលើទំហំអតិរេកដែរ ពីព្រោះកំណើនថ្លៃផលដំណាំ មានអមដោយកំណើនថ្លៃធាតុចូល ។ ដោយសារកំណើនថ្លៃធាតុចូលអនុវត្តលើផលិតកម្មគ្រប់ប្រភេទ ដូច្នេះអតិរេកត្រូវមានច្រើនលើសកំរិតអប្បបរមាណាមួយទើបអាចផ្តល់ផលចំណេញ ។ សំរាប់ជាច្រើនគ្រួសារអ្នកមានអតិរេកស្បៀងនៅកម្ពុជា អតិរេករបស់ពួកគេ ច្រើនតែនៅទាបជាងកំរិតអប្បបរមាដើម្បីទទួលបានផលចំណេញនេះ ។ កត្តាមួយទៀត ដែលត្រូវពិចារណាក្នុងដំណើរការនេះដែរ គឺតួនាទីរបស់ឈ្មួញកណ្តាលនៅក្នុងទីផ្សារ ។ កំណើនថ្លៃអាចមិនបានទៅដល់កសិករដោយផ្ទាល់នោះទេ គឺយ៉ាងហោចណាស់ក៏មានមួយភាគដែលពួកឈ្មួញបានកាត់យកដែរ ។

## ៤. ផលប៉ះពាល់ខាងគោលនយោបាយ និងសេចក្តីសន្និដ្ឋាន

នាបច្ចុប្បន្ន ថ្វីបើថ្លៃទំនិញអាហារ មាននិន្នាការធ្លាក់ចុះមកវិញក្តី ក៏កំណើនថ្លៃកន្លងមកនៅតែបន្តមានផលប៉ះពាល់អវិជ្ជមានទៅលើប្រជាជនក្រីក្រ ។ វិបត្តិហិរញ្ញវត្ថុជាសាកលនៅពេលថ្មីៗនេះ បានធ្វើឱ្យបញ្ហាចោទកាន់តែខ្លាំង ហើយទំនងជាធ្វើឱ្យយ៉ាប់យឺនថែមទៀតដល់ស្ថានភាពប្រទេសក្រីក្រមួយចំនួន និងគ្រួសារក្រីក្រក្នុងប្រទេសនីមួយៗ ។ ដោយសាររដ្ឋាភិបាល និងអ្នកកសាងគោលនយោបាយ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ដូចជាកម្ពុជា បានជួបវិបត្តិដោយមិនបានត្រៀមខ្លួនទប់ទល់ ដូច្នេះ តើមានអ្វីខ្លះដែលគេអាចរៀនសូត្របានពីបទពិសោធន៍កន្លងមក ដើម្បីអាចជៀសវាងបញ្ហាស្រដៀងគ្នានាពេលអនាគត ។ សំខាន់ជាងនេះទៀត គឺគោលនយោបាយឆ្លើយតប និងផលប៉ះពាល់ក្រោយពេលមានបញ្ហាថ្មីៗនេះ ដែលអាចកើតមានដដែលទៀត នៅពេលមានវិបត្តិសេដ្ឋកិច្ចលើកក្រោយ ។ ប្រជាជនក្រីក្រនៅក្នុងតំបន់ដែលទទួលរងគ្រោះធ្ងន់ធ្ងរពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីភាគច្រើន ទំនងត្រូវទទួលរងគ្រោះដោយសារវិបត្តិហិរញ្ញវត្ថុសាកលនាបច្ចុប្បន្នទៀត ។ ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុនាពេលថ្មីៗ អាចធំប៉ុនគ្នា រឺធ្ងន់ធ្ងរជាងឥទ្ធិពលនៃកំណើនថ្លៃម្ហូបអាហារទៅទៀត ។ ដោយសារស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន ក្រុមងាយរងគ្រោះនានាអាចទទួលរងគ្រោះពីវិបត្តិមុនគេតែម្តង ដោយសារការបាត់បង់ការងារ/ប្រាក់ចំណូល ឬការថយចុះកំលាំងទិញជាផលវិបាកនៃកំណើនថ្លៃ ។

ជាទូទៅ យោងតាមភាពរងគ្រោះនៃគ្រួសារក្រីក្រ ត្រូវមានវិធានការផ្សេងៗក្នុងរយៈពេលខ្លីសំរាប់ការពារពួកគេ ។ វិធានការរយៈពេលខ្លីខាងគោលនយោបាយនេះ រួមមាន ជំនួយគាំទ្រដោយផ្ទាល់តាមរយៈការចែកចាយម្ហូបអាហារ/ប័ណ្ណម្ហូបអាហារ របបស្បៀងអាហារ ជំនួយទ្រទ្រង់ប្រាក់ចំណូល ស្បៀងពលកម្ម អាហារតាមសាលារៀន ព្រមទាំងការបង្កើតធនាគារអាហារដែលអាចជាជំរើសសំរាប់គោលនយោបាយរយៈពេលមធ្យមផងដែរ ។

ធនាគារអាហារ ទំនងជាការវិនិយោគផ្នែកសេដ្ឋកិច្ចដ៏ល្អមួយ ពីព្រោះវាអាចជួយកាត់បន្ថយបន្ទុកចំណាយដ៏ខ្ពស់ ក្នុងការជួញដូរផលដំណាំជាអាហារមួយចំនួន ។ ការគ្រប់គ្រងថ្លៃ ការហាមឃាត់ការនាំចេញ និងឧបករណ៍គោលនយោបាយប្រហាក់ប្រហែលគ្នា អាចមានឥទ្ធិពលមិនល្អក្នុងរយៈពេលវែង ទាំងចំពោះសេដ្ឋកិច្ច និងជនក្រីក្រ ។

សំរាប់រយៈពេលវែង គួរចាត់វិធានការកែលំអសន្តិសុខស្បៀង និងកាត់បន្ថយភាពងាយរងគ្រោះ ។ គោលគំនិតកែលំអកំណើនក្នុងប្រទេសទៅតាមគន្លងកំណើនមានលក្ខណៈរាប់បញ្ចូល (inclusive growth) គឺជាមធ្យោបាយប្រាកដប្រជាបំផុតដើម្បីញ៉ាំងឱ្យវិធានការខាងលើសំរេចបានជោគជ័យក្នុងរយៈពេលវែង ។ ដោយសារនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ប្រជាជនភាគច្រើនរស់នៅក្នុងតំបន់ជនបទ ដូច្នេះគួរយកចិត្តទុកជាពិសេសទៅលើស្ថានភាពកសិកម្មក្នុងប្រទេសទាំងនោះ ។ ដោយឡែក ថ្លៃធញ្ញជាតិអាហាររំពឹងថានឹងបន្តមានកំរិតខ្ពស់ក្នុងរយៈពេលខ្លី និងមធ្យម ។ ស្ថានភាពនេះ ព្រមទាំងបញ្ហាប្រឈមក្នុងការផលិតដូចបានពិភាក្សារួចហើយ គឺជាឱកាសល្អសំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្មនៅក្នុងប្រទេសមួយចំនួន ។ កំណើនថ្លៃនឹងបង្កើនការលើកទឹកចិត្ត ដើម្បីប្រើប្រាស់ដីធ្លីឱ្យកាន់តែប្រសើរ និងលើកកំពស់ប្រសិទ្ធភាពក្នុងផលិតកម្ម ។ ហើយនេះក៏ជាឱកាសល្អសំរាប់ឱ្យអ្នកកសាងគោលនយោបាយចូលពាក់ព័ន្ធកាន់តែពេញលេញក្នុងវិស័យកសិកម្ម ដោយជួយគាំទ្រដល់ការដាក់បញ្ចូល និងប្រើប្រាស់កាន់តែទូលំទូលាយនូវពូជដំណាំមានគុណភាពខ្ពស់ ការកែលំអប្រព័ន្ធធារាសាស្ត្រ ការចែកចាយកាន់តែប្រសើរនូវជីមានកំរិតថ្លៃសមរម្យ ការកែលំអការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតាមតំបន់ជនបទ ព្រមទាំងការងារជាច្រើនទៀត ។ សហគមន៍នៅជនបទកំពុងប្រឈមមុខនឹងបន្ទុកចំណាយធ្ងន់ធ្ងរណាស់នៅក្នុងផលិតកម្ម និងក្នុងជំនួញផលិតផលកសិកម្ម ។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ មានទាំងផ្នែករូបវន្ត សង្គមកិច្ច និងហិរញ្ញវត្ថុអាចជួយកាត់បន្ថយបន្ទុកចំណាយដ៏ច្រើន និងជួយកែលំអផលិតកម្ម និងផលិតភាព ។ ម្យ៉ាងទៀត ក៏មានលទ្ធភាពច្រើនដែរ ដើម្បីកែលំអកិច្ចសហប្រតិបត្តិការ និងជំនួញអន្តរជាតិ ជាពិសេសនៅក្នុងតំបន់យើង សំរាប់ផលដំណាំអាហារដ៏សំខាន់ៗ ដូចជា ស្រូវអង្ករជាដើម ។

កំហិតចំបងៗក្នុងការកសាង និងអនុវត្តគោលនយោបាយក្នុងប្រទេសក្រីក្រភាគច្រើន គឺលទ្ធភាព និងសមត្ថភាពនៃនៅតាមការិយាល័យ ក្នុងការរៀបចំគោលនយោបាយឱ្យបានសមស្រប ជាពិសេសសំរាប់ការអនុវត្ត ។ ដើម្បីអាចកែលំអស្ថានភាពនេះបាន ត្រូវធ្វើវិមជ្ឈការ និងផ្តល់សិទ្ធិអំណាចមួយចំនួនដល់អាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហានៅមូលដ្ឋាន ។ នៅកម្ពុជា ការអនុមតិ និងអនុវត្ត "ច្បាប់រៀបចំអង្គការ" អាចជាជំហានមួយដ៏សំខាន់សំដៅកាត់បន្ថយបន្ទុកដ៏ធ្ងន់ខាងរដ្ឋបាល និងការិយាធិបតេយ្យ ដែលប្រជាជននៅជនបទជាពិសេសកំពុងជួបប្រទះសព្វថ្ងៃ ។

# ឧបសម្ព័ន្ធ ៣
# ផលប៉ះពាល់នៃម្ហូបអាហារមានថ្លៃខ្ពស់នៅកម្ពុជា

*ដោយលោក ច័ន្ទ សុផល*[១]

ដូចនៅប្រទេសជាច្រើនទៀតដែរ ថ្លៃទំនិញ និងសេវាផ្សេងៗនៅកម្ពុជា បានស្ទុះឡើងនៅឆ្នាំ២០០៨ ជាពិសេសប្រេងឥន្ធនៈ និងម្ហូបអាហារ ធ្វើឱ្យអត្រាអតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ កើនឡើងពី ១៣,៧% នៅខែមករា ២០០៨ ដល់ជាង ២៥,៧% ក្នុងខែឧសភា ហើយចុះមកវិញត្រឹម ១៣,៥% នៅខែធ្នូ ២០០៨ យោងតាមវិទ្យាស្ថានជាតិស្ថិតិ ។ សន្ទស្សន៍ថ្លៃទំនិញម្ហូបអាហារ កើនឡើងខ្ពស់ ដល់ទៅ ៣៦,៨% នៅខែកក្កដា ២០០៨ ទើបធ្លាក់ចុះបន្តិចវិញ មកត្រឹម ២៣,២% នៅខែធ្នូ ២០០៨ ។ អតិផរណានេះបង្កជាសំខាន់ដោយសារកំណើនតំរូវការក្នុងពិភពលោក និងកំណើនតំរូវការមួយចំនួនក្នុងស្រុក រីឯការផ្គត់ផ្គង់បានរួមចុះ រឺកើនតំលៃ ដោយសារកំណើនចំណាយលើប្រេងឥន្ធនៈ ។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចកម្ពុជា បានទទួលទាំងផលប៉ះពាល់អវិជ្ជមានសំរាប់អ្នកប្រើប្រាស់ និងឱកាសល្អសំរាប់ឱ្យផលិតកររកចំណូលបានកាន់តែច្រើន ។

អតិផរណាកើតខ្ពស់ ប៉ះពាល់ដល់អ្នកក្រីក្រធ្ងន់ធ្ងរជាង ។ អង្ករគ្រប់ប្រភេទដែលជាអាហារមូលដ្ឋាននៅកម្ពុជា បានឡើងថ្លៃ ១០០% ពីខែមីនា-កក្កដា ២០០៧ ដល់ មីនា-កក្កដា ២០០៨ ក្នុងនេះ សាច់ឡើងថ្លៃ ៥០-៧០% រីឯត្រី និងបន្លែឡើងថ្លៃ ២០-៣០% ។ ការឡើងថ្លៃម្ហូបអាហារ បានប៉ះពាល់ជាអវិជ្ជមានដល់ប្រជាជនគ្រប់ស្រទាប់ ហើយទំហំនៃការប៉ះពាល់ប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ចនៃគ្រួសារនីមួយៗ ។ ប្រជាជនក្រីក្រជាងគេ ៤០% ត្រូវចំណាយ ៧០% នៃចំណូលរបស់ខ្លួនទៅលើម្ហូបអាហារ យោងតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ ។ ដូច្នេះហើយ អ្នកក្រីក្រ និងអ្នកទិញម្ហូបអាហារ ទទួលរងគ្រោះធ្ងន់ធ្ងរជាងគេដោយសារការឡើងថ្លៃយ៉ាងខ្ពស់នេះ ។ ប្រជាជនទាំងនេះ ភាគច្រើនរស់នៅក្នុងតំបន់ក្រីក្រ ។ គ្រួសារមានអសន្តិសុខស្បៀង ភាគច្រើនរស់នៅតំបន់ទន្លេសាប និងតំបន់វាលទំនាប ។ អ្នកក្រីក្រនៅតាមទីប្រជុំជន ក៏ត្រូវប៉ះពាល់យ៉ាងខ្លាំងដែរ ទោះបីពួកគេមានឱកាសរកចំណូលច្រើនជាងក្តី ។

---

១ លោក ច័ន្ទ សុផល ជាទីប្រឹក្សាស្រាវជ្រាវនៃវិទ្យាស្ថានCDRI ។ ឯកសារនេះ ផ្អែកលើការសិក្សាស្តីពីផលប៉ះពាល់នៃការឡើងថ្លៃស្បៀងអាហារ ឧបត្ថម្ភដោយកម្មវិធីស្បៀងអាហារពិភពលោក កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ធនាគារពិភពលោក អ៊ុកស្វាមអាមេរិក វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ។

ក្រាហ្វិក ៣.១: សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ ពីខែធ្នូ ២០០៦ ដល់ ធ្នូ ២០០៨ (ធ្នូ ២០០៦ = ១០០)




*ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ*

ជាផលប៉ះពាល់វិជ្ជមាន គឺកសិផលជាច្រើនបានឡើងថ្លៃ និងផ្តល់ចំណេញដល់ពាណិជ្ជករ និងដល់កសិករប្រហែល ៣០% ដែលមានផលដំណាំនៅសល់សំរាប់លក់ ។ ការសិក្សារបស់យើងបានរកឃើញថា កសិករអ្នកដាំស្រូវ ដំឡូងឈើ ពោត រឺសណ្តែកសៀង ដែលបានលក់នៅដើមនៅឆ្នាំ២០០៨ និងមានប្រហែល ២៥% នៃកសិករទាំងអស់ បានទទួលផលចំណេញសុទ្ធពីការឡើងថ្លៃផលិតផល ។ ប៉ុន្តែផលប៉ះពាល់ល្អនេះ វាមានកំរិត ពីព្រោះប្រជាជនជនបទ មិនមែនមានកសិផលនៅសល់សំរាប់លក់គ្រប់គ្នានោះទេ គឺមានតែ ៣៤% ដែលមានដូច្នេះ រីឯ ២១% ទៀតជាគ្រួសារគ្មានដីធ្លី និង ៤៥% មានដីធ្លីតិច (មិនលើសពី ១ហិកតា/គ្រួសារ) ។

ជាភ័ព្វល្អ ថ្លៃឈ្នួលសំរាប់ពលកម្មពេលថ្ងៃដូចជា ការដកស្ទូង ច្រូតកាត់ ជំរះស្មៅ កាប់ឆ្ការព្រៃរិចរិល ដែលជាប្រភពចំណូលចំបងរបស់អ្នកគ្មានដី និងអ្នកមានដីតិច បានកើនប្រហែល ៥០% ក្នុងឆ្នាំកន្លងទៅ ។ ជាមធ្យម ប្រាក់ឈ្នួលប្រចាំថ្ងៃកើនពី ៧៥០០ ដល់ ១១.០០០រៀល (១,៨៣-២,៦៨ដុល្លារ) ពីឆមាសទី២ ឆ្នាំ២០០៧ ដល់ឆមាសទី១ ឆ្នាំ២០០៨ (តារាង ៣.១) ។ កំណែតំរូវតាមទីផ្សារនេះ បានជួយប្រជាជនជាច្រើននាក់ឱ្យរក្សាស្ថានភាពនៅដដែលបាន រឺក៏មិនចុះក្រកាន់តែខ្លាំងទៀត ។ ទោះយ៉ាងនេះក្តី មានតែគ្រួសារប្រហែល ៣០% រឺប្រហែល ៥០% នៃអ្នកគ្មានដី/អ្នកមានដីតិច ដែលបានធ្វើពលកម្មគិតឈ្នួលប្រចាំថ្ងៃមួយចំនួន ក្នុងខែមករា-មេសា ២០០៨ ។ ថ្វីបើអ្នកគ្មានដី/អ្នកមានតិចមួយចំនួន បានធ្វើការងារផ្សេងទៀតក្រៅពីពលកម្មប្រចាំថ្ងៃក្តី ក៏ក្នុងចំណោមពួកគេនេះមានយ៉ាងហោចណាស់ ២៥% ដែរ ដែលមិនអាចរកចំណូលបានច្រើនថែមទៀតដោយសារកង្វះការងារ ហើយក៏ត្រូវប៉ះពាល់ខ្លាំងជាងគេពីការឡើងថ្លៃម្ហូបអាហារ ។ អ្នកទាំងនេះច្រើនតែរស់នៅតាមតំបន់ក្រីក្រ ជាពិសេសតំបន់ទន្លេសាប និងវាលទំនាបមួយភាគ ដែលមានសក្តានុពលតិចសំរាប់ការបង្កើតប្រាក់ចំណូល ។ សព្វថ្ងៃនេះ មានឱកាសរកចំណូលច្រើនណាស់នៅតាមតំបន់ខ្ពង់រាប ដោយសារកំណើនការបំប្លែងដីព្រៃរិចរិលទៅជាដីកសិកម្ម ។

អ្នកក្រីក្រខ្លាំងទាំងនៅទីក្រុង និងជនបទ ត្រូវតស៊ូជារៀងរាល់ថ្ងៃដើម្បីបានម្ហូបអាហារគ្រប់គ្រាន់ ។ អ្នកទាំងនេះតំណាងឱ្យ ២០% នៃប្រជាជនសរុប និងត្រូវ "រកមួយថ្ងៃហូបមួយថ្ងៃ" ដោយប្រើចំណូលប្រមាណ ២-៣ដុល្លារក្នុងមួយថ្ងៃ ដើម្បីទិញអង្ករ និងម្ហូបអាហារចាំបាច់ឯទៀតសំរាប់មួយថ្ងៃនោះ ។ ដោយប្រើនិយមន័យរបស់អង្គការស្បៀងអាហារពិភពលោក ការអង្កេតបានរកឃើញថា គ្រួសារ ១២% ឬ ១,៧លាននាក់ ពុំមានអាហារហូបចុក "គ្រប់គ្រាន់" ទេ ហើយប្រហែល ១លាននាក់ទៀត មានការហូបចុក "អន់ខ្សោយ" ។ ម្យ៉ាងទៀត គ្រួសារ ៥០% រាយការណ៍ថា បានកាត់បន្ថយការហូបចុក ដើម្បីដោះស្រាយបញ្ហាម្ហូបអាហារឡើងថ្លៃ ។ មធ្យោបាយនេះបានគំរាមកំហែងដល់គីរិតអាហារូបត្ថម្ភ ធ្វើឱ្យសុខភាពចុះទន់ខ្សោយ ហើយអាចមានផលប៉ះពាល់អាក្រក់យូរអង្វែង ។ បញ្ហាបោះបង់ការសិក្សាមានច្រើនបំផុតក្នុងចំណោមគ្រួសារ ជួបអសន្តិសុខស្បៀងដោយ ១៣% នៃគ្រួសារទាំងនេះមានកូនបោះបង់ការសិក្សា នៅខែមករា ២០០៨ និង ២២% មានកូនបោះបង់ការសិក្សា នៅខែមិថុនា ២០០៨ ។ តួលេខនេះបានបញ្ជាក់គាំទ្រដល់ការព្រួយបារម្ភពីផលប៉ះពាល់រយៈពេលវែងនៃថ្លៃដ៏ខ្ពស់នៃម្ហូបអាហារ ។ សហគមន៍នេសាទស្ថិតក្នុងចំណោមអ្នកត្រូវប៉ះពាល់ធ្ងន់ធ្ងរជាងគេ ។ ការឡើងថ្លៃអង្ករមួយជាពីរ បានរុញច្រានគ្រួសារនេសាទឱ្យចុះក្រកាន់តែខ្លាំង ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេថយចុះយ៉ាងខ្លាំង ដោយសារការថយចុះបរិមាណត្រីចាប់បាន និងកំណើនចំណាយប្រចាំថ្ងៃ ។ ត្រីដែលពួកគេចាប់បាន អាចលក់បានថ្លៃជាងមុន ២០% ក៏ពិតមែន ប៉ុន្តែមិនអាចប៉ះប៉ូវការឡើងថ្លៃធាតុចូលផ្សេងៗ និងឧបករណ៍នេសាទបានទេ ។

**តារាង ៣.១: ថ្លៃឈ្នួលមេជ្យាននៃពលកម្មពេលថ្ងៃ**

| ប្រភេទពលកម្មពេលថ្ងៃ | 2007 រដូវវស្សា (កក្កដា-ធ្នូ) | 2008 រដូវប្រាំង (មករា-មេសា) | 2008 ឧសភា-កក្កដា | បំរែបំរួលជាភាគរយ កក្កដា-ធ្នូ ២០០៧ ដល់ ឧសភា-កក្កដា ២០០៨ |
|---|---|---|---|---|
| | | (រៀល/ថ្ងៃ/នាក់) | | |
| ដកស្ទូង | 6000 | 9250 | 10,000 | 67 |
| ច្រូតកាត់ | 7500 | 9000 | 11,000 | 47 |
| ជីរះស្មៅ | 7500 | 9000 | 11,000 | 47 |
| ដាំដំណាំ | 8000 | 10,000 | 11,000 | 38 |
| កាប់ឆ្ការព្រៃគម្ពោត/ព្រៃរិចរិល | 9000 | 12,500 | 13,000 | 44 |
| ការងារសំណង់ | 10,000 | 11,000 | 13,500 | 35 |

*ប្រភព: អង្កេតថ្នាក់ជាតិលើ ២២៣៥គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI*

អ្នកផលិតស្រូវអង្កមួយចំនួន ដែលប្រហែលស្ថិតក្នុងចំណោមគ្រួសារជនបទ ៣៥% ជាអ្នកមានដីកសិកម្មច្រើនជាង ១ហិកតា គឺបានទទួល រឺប្រហែលជានឹងបានទទួលផលចំណេញពីការឡើងថ្លៃស្រូវអង្ករយ៉ាងខ្ពស់ ។ ផ្អែកតាមតំលៃធាតុចូលកសិកម្ម និងថ្លៃទីផ្សារនៃស្រូវ ក្នុងពេលធ្វើអង្កេតនៅខែមិថុនា ២០០៨ ការផលិតស្រូវនៅឆ្នាំ២០០៨ នឹងបានចំនេញច្រើនជាងនៅឆ្នាំ២០០៧ ។ កសិករធ្វើស្រែប្រាំងទទួលបានអត្រាប្រាក់ចំណេញដុលរហូតដល់ ៣២% ថ្វីបើបន្ទុកចំនាយផលិតកម្ម បានកើនឡើង ៥០% ក្តី ។ តារាង ៣.២ បង្ហាញយ៉ាងសង្ខេបពីប្រាក់ចំណេញនៃ

ផលដំណាំសំខាន់ៗនៅឆ្នាំ២០០៨ ។ ដោយសារថ្លៃស្រូវវស្សាបានថយចុះប្រាក់ចំណេញដុលរបស់ផលិតករក៏ថយចុះច្រើនដែរ ។ ជាជាងការកាត់បន្ថយធាតុចូល ដូចជា ជី ដែលបានឡើងថ្លៃមួយជាពីរ រឺមួយជាបីនោះ កសិករតែងខិតខំស្វែងរកកំចី រឺក៏ទិញជឿយ៉ាងថ្លៃនូវធាតុចូលកសិកម្ម ។ កសិករដាំដំណាំដំឡូងមី មានការខាតបង់ច្រើនជាងគេ គឺរហូតដល់ទៅ ១៨០ដុល្លារក្នុងដីមួយហិកតា ដោយសារថ្លៃដំឡូងថយចុះខ្លាំង ។ រឿងនេះគឺមកពីថ្លៃប្រេងធ្លាក់ចុះ ដែលធ្វើឱ្យស្ទើរតែអស់តំរូវការទិញដំឡូងយកទៅផលិតជាប្រេងឥន្ធនៈដូចនៅដើមឆ្នាំ២០០៨ ។

នៅមានកំហិតជាច្រើននិងជាយូរមកហើយដែរ លើការពង្រីក និងធ្វើប្រពលវប្បកម្មកសិកម្ម ។ កសិករជាច្រើនបានរាយការណ៍ថា ការឡើងថ្លៃជីយ៉ាងខ្លាំងនេះជាកំហិតមួយធំណាស់ ។ កំហិតផ្សេងទៀតមានដូចជា កង្វះកំលាំងពលកម្មក្នុងគ្រួសារ/សត្វអូសទាញ និងការគ្មានប្រព័ន្ធធារាសាស្ត្រ ។ តារាង ៣.៣ បង្ហាញពីកំហិតសំរាប់មុខដំណាំសំខាន់ៗដែលបានសិក្សា ។

គួរមានមធ្យោបាយដើម្បីកាត់បន្ថយថ្លៃជីដែលបានកើនឡើង មួយជាពីរ រឺមួយជាបី ក្នុងឆ្នាំកន្លងទៅ ។ គេរាយកាណ៍ថា ជីគីមីទាំងអស់ត្រូវនាំចូលមកតាមច្រកព្រំដែនគ្មានប្រសិទ្ធិភាព ដោយពឹងផ្អែកយ៉ាងខ្លាំង និងជាលក្ខណៈក្រៅផ្លូវការ លើឈ្មួញវៀតណាម និងថៃ ។ ការនាំចូលដុំ និងដោយផ្ទាល់នូវជី អាចជួយកាត់បន្ថយបន្ទុកចំណាយបានយ៉ាងច្រើន ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គួរពិចារណាដោះស្រាយកំហិតដ៏ធំនេះ ដែលកសិករបានលើកឡើង និងយកចិត្តទុកដាក់លើការប្រើប្រាស់ជីគីមីឱ្យបានសមស្រប ។

កង្វះទឹក/ប្រព័ន្ធធារាសាស្ត្រជាបញ្ហាចំបង ថ្វីបើមានកំណើនគួរកត់សំគាល់នូវការផ្តល់ និងការតាំងចិត្តផ្តល់ប្រព័ន្ធធារាសាស្ត្ររបស់រដ្ឋាភិបាលក្តី ។ លទ្ធភាពគ្រប់គ្រងលើការផ្គត់ផ្គង់ទឹកមានសំរាប់តែ ៣០% នៃដីស្រែប៉ុណ្ណោះ ដែលបានផ្តល់ស្ថិរភាពនិងភាពប្រាកដប្រជាដល់ផលិតកម្មផលដំណាំ ។ កសិករក៏ត្រូវប្រើជាចាំបាច់ផងដែរនូវធាតុចូលផ្សេងទៀតដូចជា ជី និងពូជមានទិន្នផលខ្ពស់ ។ ការផ្គត់ផ្គង់ទឹកដែលអាចទុកចិត្ត បានជួយសំរួលការធ្វើប្រពលវប្បកម្ម និងកាត់បន្ថយបន្ទុកចំណាយផលិតកម្ម ។ បើគ្មានប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធរំដោះទឹកទេ ផលិតកម្មក្នុងតំបន់ជាច្រើនមិនអាចធ្វើកើត រឺក៏ប្រថុយខាតធំពេក នៅពេលមានប្រើធាតុចូលល្អៗ ។

កសិករជាច្រើនពុំមានមូលធនសំរាប់ចាប់ផ្តើម រឺពង្រីកផលិតកម្មទេ ។ អ្នកខ្លះអាចទទួលបានកំចីដែលភាគច្រើន មានអត្រាការប្រាក់ខ្ពស់ ដើម្បីបន្តការងារផលិតកម្ម ។ កំចីនេះ បូកនឹងការខ្ចីបុលបន្ថែមសំរាប់ការប្រើប្រាស់ បានធ្វើឱ្យគ្រួសារប្រហែល ៥០% ត្រូវជំពាក់បំណុលគេ ហើយនេះជាកត្តាគួរឱ្យព្រួយបារម្ភ ។ កសិករត្រូវការខ្ចីប្រាក់កាន់តែច្រើន ដើម្បីដោះស្រាយកំណើនបន្ទុកចំណាយផលិតកម្ម ជាពិសេស ជី ថ្នាំសំលាប់សត្វល្អិត គ្រឿងចក្រ និងពលកម្ម ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវតែផ្តល់ទុនឱ្យអ្នកផ្តល់ឥណទាន និងកំណត់មុខសញ្ញាទុននេះសំរាប់បំរើកសិកម្ម ។ វិធានការនេះត្រូវមានប្រព័ន្ធតាមដានដ៏សក្តិសិទ្ធិមួយ ដើម្បីធានាថា ទុននោះបានទៅដល់ដៃកសិករពិតៗ និងបំរើសកម្មភាពផលិតកម្មយ៉ាងត្រឹមត្រូវ ។

តារាង ៣.២: ផលប៉ះពាល់នៃកំនើនថ្លៃលើប្រាក់ចំនេញពីផលដំណាំ (ក្នុងមួយហិកតាក្នុងមួយរដូវ)

| ផលដំណាំ | រដូវប្រាំង | | | រដូវវស្សា | | |
|---|---|---|---|---|---|---|
| | 2007 | 2008 | បំរែបំរួល (%) | 2007 | 2008 | បំរែបំរួល (%) |
| អង្ករ | | | | | | |
| ទិន្នផល (តោន) | 3.7 | 3.7 | 0% | 1.9 | 1.9 | 0% |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | 180 | 250 | 39% | 225 | 250 | 11% |
| ប្រាក់ចំនូលដុល (ដុល្លារ) | 663 | 921 | 39% | 427 | 475 | 11% |
| ចំនាយផលិតកម្មសរុប (ដុល្លារ) | 233 | 350 | 50% | 150 | 225 | 50% |
| ប្រាក់ចំនេញដុល (ដុល្លារ) | **430** | **571** | **33%** | **277** | **250** | **-10%** |
| ពោត | | | | | | |
| ទិន្នផល (តោន) | | | | 4.0 | 4.0 | 0% |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | | | | 150 | 140 | -7% |
| ប្រាក់ចំនូលដុល (ដុល្លារ) | | | | 600 | 560 | -7% |
| ចំនាយផលិតកម្មសរុប (ដុល្លារ) | | | | 205 | 280 | 37% |
| ប្រាក់ចំនេញដុល (ដុល្លារ) | | | | **395** | **280** | **-29%** |
| សណ្តែកសៀង | | | | | | |
| ទិន្នផល (តោន) | | | | 1.5 | 1.5 | 0% |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | | | | 550 | 450 | -18% |
| ប្រាក់ចំនូលដុល (ដុល្លារ) | | | | 825 | 675 | -18% |
| ថ្លៃចំនាយផលិតកម្មសរុប (ដុល្លារ) | | | | 260 | 375 | 44% |
| ប្រាក់ចំនេញដុល (ដុល្លារ) | | | | **565** | **300** | **-47%** |
| ដំឡូងឈើ | | | | | | |
| ទិន្នផល (តោន) | | | | 8.0 | 8.0 | 0% |
| ថ្លៃទិញផ្ទាល់ពីកសិករ (ដុល្លារ/តោន) | | | | 70 | 30 | -57% |
| ប្រាក់ចំនូលដុល (ដុល្លារ) | | | | 560 | 240 | -57% |
| ថ្លៃចំនាយផលិតកម្មសរុប (ដុល្លារ) | | | | 288 | 420 | 46% |
| ប្រាក់ចំនេញដុល (ដុល្លារ) | | | | **272** | **-180** | **-166%** |

*ប្រភព: អង្កេតគ្រួសារសំរាប់ដំណាំស្រូវ និងការពិភាក្សាក្រុមគោលដៅសំរាប់ដំណាំផ្សេងទៀត និង ក្រសួងកសិកម្មសំរាប់ទិន្នន័យថ្មីៗស្តីពីថ្លៃ*

តារាង ៣.៣: កំហិតលើកំណើនផលិតកម្ម បែងចែកតាមមុខដំណាំ (គ្រួសារគិតជា %)

| | ស្រូវវស្សា | ស្រូវប្រាំង | ពោត | ដំឡូងឈើ | ដំណាំផ្សេងៗ | សរុប |
|---|---|---|---|---|---|---|
| គ្មានពលករ/គ្មានសត្វអូសទាញគ្រប់គ្រាន់ | 10.4 | 6.5 | 10.3 | 15.8 | 13.4 | 10.2 |
| គ្មានគ្រឿងចក្រគ្រប់គ្រាន់ | 5.9 | 6.8 | 1.1 | 21.6 | 6.9 | 6.5 |
| គ្មានពេល រឺមានការងារផ្សេងធ្វើ | 0.5 | 0.2 | 2.3 | 2.2 | 1.6 | 0.6 |
| គ្មានលទ្ធភាពស្រោចស្រព | 15.6 | 7.6 | 19.5 | 2.2 | 11.2 | 14.1 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ទិញពូជ | 3.8 | 7.4 | 8.0 | 2.9 | 4.4 | 4.4 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ទិញជី | 25.1 | 26.4 | 18.4 | 13.7 | 18.4 | 24.2 |
| គ្មានប្រាក់គ្រប់គ្រាន់ទិញថ្នាំសំលាប់សត្វល្អិត | 9.2 | 16.7 | 4.6 | 5.8 | 7.8 | 9.8 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ជួលពលករ | 5.7 | 6.3 | 9.2 | 18.7 | 5.3 | 6.3 |
| គ្មានប្រាក់គ្រប់គ្រាន់សំរាប់ធ្វើការស្រោចស្រព | 2.7 | 8.0 | 5.7 | 1.4 | 2.5 | 3.3 |
| មិនអាចរកបានកំចី | 0.4 | 0.3 | 1.1 | 2.2 | 1.2 | 0.5 |
| អត្រាការប្រាក់ខ្ពស់ | 1.2 | 0.9 | 1.1 | 1.4 | 1.9 | 1.2 |
| កង្វះមធ្យោបាយដឹកជញ្ជូន | 2.4 | 2.3 | 2.3 | 2.9 | 3.1 | 2.5 |
| កង្វះច្រកចូលទីផ្សារ | 0.4 | 0.2 | 1.1 | 0.0 | 1.9 | 0.5 |
| គ្មានចំណេះដឹង/គ្មានការបណ្តុះបណ្តាល | 4.0 | 1.7 | 8.0 | 5.8 | 10.3 | 4.2 |
| ទំនាស់ដីធ្លី/ការព្រួយបារម្ភពីទំនាស់ដីធ្លី | 0.1 | 0.0 | 0.0 | 0.0 | 0.3 | 0.1 |
| ទឹកជំនន់/រាំងស្ងួត | 9.3 | 3.1 | 5.7 | 1.4 | 5.3 | 7.9 |
| ផ្សេងៗ | 3.4 | 5.6 | 1.1 | 2.2 | 4.7 | 3.8 |
| សរុប | 100 | 100 | 100 | 100 | 100 | 100 |

*ប្រភព: អង្កេតថ្នាក់ជាតិលើ ២២៣៥គ្រួសារ នៅខែមិថុនា ២០០៨ ធ្វើឡើងដោយ CDRI*

ជំនួយបច្ចេកទេសតាមរយៈសេវាផ្សព្វផ្សាយបច្ចេកទេស ក៏គួរតែពង្រីកផងដែរ ។ កំណើនការចែកចាយថ្នាំបង្ការសំរាប់សត្វចិញ្ចឹម អាចរួមចំណែកបានច្រើនណាស់ដល់កំណើនការផ្គត់ផ្គង់ម្ហូបអាហារ និងការចុះថ្លៃទំនិញ ។ ព័ត៌មានទីផ្សារកសិកម្មក្នុងស្រុក និងអន្តរជាតិ គួរតែផ្សព្វផ្សាយកាន់តែទូលំទូលាយដល់ឈ្មួញ និងកសិករ ដើម្បីឱ្យពួកគេអាចមានគំនិតច្បាស់លាស់ពីនិន្នាការទីផ្សារ ។ គេបានផ្តល់មតិមួយថា គួរប្រើប្រាស់ និងជួយគាំទ្រក្រុមកសិករនានាដែលមានស្រាប់ក្នុងការងារផ្សព្វផ្សាយព័ត៌មាននេះ ។ ផ្អែកលើស្ថានភាពល្អឡើងបែបនេះ ផលិតករខាងកសិកម្មអាចចាប់យកឱកាសល្អនៃការឡើងថ្លៃកសិផលបាន ដោយបង្កើនផលិតកម្មសំរាប់នាំចេញ ។

សំរាប់យុទ្ធសាស្ត្ររយៈពេលវែង គួរមានគោលនយោបាយកាន់តែប្រសើរសំរាប់បែងចែក និងគ្រប់គ្រងដីធ្លី ។ គោលដៅបច្ចុប្បន្ននៃការរក្សាទុកគំរបព្រៃឈើលើ ៦០% នៃផ្ទៃប្រទេស អាចគួរឱ្យចង់បានមែន ប៉ុន្តែមិនសូវប្រាកដនិយមទេ នៅពេលសំពាធប្រជាសាស្ត្រ និងសេដ្ឋកិច្ចចោទឡើងខ្លាំងជាង ។ ដោយសារគោលដៅនេះ ដីកសិកម្មថ្មីៗមានលក្ខណៈច្បាប់មិនច្បាស់លាស់ទេ ហើយច្រើនតែងាយស្រួលឱ្យពួកអ្នកមានប្រាក់ អំណាច ខ្សែរយៈខ្លាំង ប្រមែប្រមូលយកដីទាំងនោះ ចំណែកឯគ្រួសារជនបទភាគច្រើននៅតែជាអ្នកគ្មានដី រឺមានដីតិច ។

# ឧបសម្ព័ន្ធ ៤
# អត្ថបទសង្ខេបស្តីពីផលប៉ះពាល់នៃការឡើងថ្លៃទំនិញទៅលើភាពក្រីក្រនៅក្នុងភូមិសិក្សាប្រាំបួននៅជនបទៈ របកគំហើញបឋម

*ដោយលោក សូ សុវណ្ណារិទ្ធី*[១]

## ១. សេចក្តីផ្តើម

កម្ពុជាកំពុងប្រឹងប្រែងឆ្លើយតបទៅនឹងអតិផរណាមិនប្រក្រតីនៃថ្លៃម្ហូបអាហារ និងទំនិញប្រើប្រាស់មិនមែនអាហារ នៅលើទីផ្សារអន្តរជាតិ ដើម្បីទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឱ្យមានចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ ។ កម្ពុជាជាប្រទេសផលិតស្រូវលើសប្រមាណ ២លានតោន នៅឆ្នាំ២០០៨ ឬអាចចាត់ទុកថាជាប្រទេសផលិតស្រូវលើសនៅក្នុងតំបន់សំរាប់ការនាំចេញ ។ ទោះយ៉ាងនេះក្តី ការឡើងថ្លៃម្ហូបអាហារ និងទំនិញប្រើប្រាស់ចាំបាច់ផ្សេងៗ នាពេលថ្មីៗនេះ បានបណ្តាលឱ្យប្រជាពលរដ្ឋជាច្រើន ជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀង (វិបសអ ខែកក្កដា ឆ្នាំ២០០៨) ។ ក្នុងខណៈពេលដែលប្រជាជនកម្ពុជាមួយភាគធំ បាននឹងកំពុងខិតខំរកប្រាក់សំរាប់ទិញម្ហូបអាហារ មានតែប្រជាជនមួយចំនួនតូចដូចជា អ្នកមានដីធ្លីច្រើន អ្នកជំនួញ និងអាជីវករឬអ្នកជំនួញតូចតាច ដែលអាចទទួលបានផលចំនេញពីការឡើងថ្លៃម្ហូបអាហារនេះ ។ ការសិក្សាថ្មីៗមួយចំនួន ដែលទាក់ទងនឹងប្រធានបទនៃផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ បានបង្ហាញថា កសិករតូចតាចមួយចំនួនធំ បានក្លាយជាអ្នកទិញម្ហូបអាហារផងដែរនៅក្នុងតំបន់ដែលមានអតិរេកផលិតផលស្រូវ ។ ការឡើងថ្លៃម្ហូបអាហារ ក៏ជាកត្តាជំរុញការអភិវឌ្ឍន៍ប្រពលវប្បកម្ម និងចំរុះកម្មកសិកម្មផងដែរ ។ ប៉ុន្តែ កង្វះទុនសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងទីផ្សារកសិកម្មមានប្រសិទ្ធភាព គឺនៅតែជាឧបសគ្គចំបងចំពោះការអភិវឌ្ឍន៍កសិកម្ម ឬការគាំទ្រឱ្យកសិករមានដីតូចៗបន្តស្ថិតនៅក្នុងក្រុមអ្នកផលិត ។

ការឡើងថ្លៃទំនិញនាពេលថ្មីៗនេះ គឺបណ្តាលមកពីការប្រែប្រួលតំរូវការ និងក៏រិតថ្លៃនៃម្ហូបអាហារ និងប្រេងនៅលើទីផ្សារអន្តរជាតិ ។ចាប់ពីឆ្នាំ២០០៣មក ថ្លៃម្ហូបអាហារមានការប្រែប្រួលខ្លាំង ស្របនឹងការឡើងថ្លៃប្រេងឥន្ធនៈ ។ នៅចន្លោះឆ្នាំ២០០៧ និង ២០០៨ សន្ទុះនៃការឡើងថ្លៃនេះបានបន្តទៀត និងឡើងដល់ក៏រិត ២ខ្ទង់នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា (ADB 2008) ។ មូលហេតុចំបង នៃការឡើងថ្លៃទំនិញនៅចុងឆ្នាំ២០០៦ រួមមាន គ្រោះរាំងស្ងួតនៅតាមប្រទេសដែលផលិតគ្រាប់ធញ្ញជាតិ និងការឡើងថ្លៃប្រេងឥន្ធនៈ ដែលធ្វើឱ្យតំលៃ ជីកសិកម្ម ការដឹកជញ្ជូន និងផលិតកម្មកសិកម្មកើនឡើង ។ មូលហេតុផ្សេងទៀតនៃការឡើងថ្លៃទំនិញគឺ កំនើនការប្រើប្រាស់ជីវៈឥន្ធនៈនៅប្រទេសអភិវឌ្ឍន៍ ដើម្បីជំនួសការប្រើប្រាស់ឥន្ធនៈផូស៊ីល និងកំនើនតំរូវការរបបអាហារផ្សេងៗ (ជាពិសេស សាច់) ពីសំណាក់ប្រជាជនថ្នាក់កណ្តាលដែលកំពុងរីកដុះដាលខ្លាំងនៅតំបន់អាស៊ី ។ កត្តាខាងលើនេះ គួបផ្សំនឹងការថយចុះស្តុកស្បៀងអាហារបំរុងរបស់ពិភពលោក បានរួមចំណែកធ្វើឱ្យម្ហូបអហារឡើងថ្លៃយ៉ាងឆាប់រហ័ស ។ មូលហេតុ និងផលប៉ះពាល់នៃកំណើនថ្លៃទំនិញក្នុងរយៈពេលខ្លី និងមធ្យម ទៅលើការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍនៅតែជាប្រធានបទសំខាន់ ។ ផលប៉ះពាល់ទាំងនោះរួមមាន ការផ្លាស់ប្តូររចនាសម្ព័ន្ធខាងពាណិជ្ជកម្ម និងផលិតកម្មកសិកម្ម ការផ្តល់ឧបត្ថម្ភធន និងការទ្រទ្រង់ថ្លៃផលកសិកម្ម នៅក្នុងប្រទេសអភិវឌ្ឍន៍នានា ការបង្វែរកសិផលសំរាប់បរិភោគផ្ទាល់

---

១ លោក សូ សុវណ្ណារិទ្ធី ជាអ្នកស្រាវជ្រាវ និងជាអ្នកដឹកនាំក្រុមសិក្សាពីឌីណាមិកនៃភាពក្រីក្រនៅ វិបសអ

ទៅជាវត្ថុធាតុដើម ឬជាធាតុចូលនៃការផលិតអាហារដែលមានតំលៃខ្ពស់ជាង និងការផលិតឥន្ធនៈជីវៈឧស្ម័ន ការទិញស្តុកសំរាប់លក់យកចំនេញក្នុងទីផ្សារ និងបំលាស់ប្តូរអាកាសធាតុជាដើម ។

តើកម្ពុជាអាចនឹងទាញយកផលចំណេញពីបាតុភូតសាកលនៃការឡើងថ្លៃទំនិញនេះយ៉ាងដូចម្តេច ក្នុងការបង្កើនពិពិធកម្ម និងផលិតភាពកសិកម្មរបស់ខ្លួន? ការវិភាគនេះ នឹងផ្តោតសំខាន់ទៅលើ ផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃការឡើងថ្លៃទំនិញ ដែលអាចលើកយកមកបង្ហាញ និងបកស្រាយ តាមរយៈការប្រើប្រាស់នូវទិន្នន័យជាបរិមាណ និងគុណភាពនៃការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ។ ចំពោះផលអវិជ្ជមានក្នុងរយៈពេលខ្លី និងមធ្យមនេះ គេអាចនិយាយបានថា ការឡើងថ្លៃទំនិញប្រើប្រាស់ អាចធ្វើឱ្យមានការយឺតយ៉ាវដល់ដំណើរការកាត់បន្ថយភាពក្រីក្រ ដោយវាអាចធ្វើឱ្យចំនួនប្រជាជនគ្មានដីធ្លីនៅតាមទីជនបទកើនឡើង ។ ជនក្រីក្រដែលមិនមានដីធ្លីជាកម្មសិទ្ធ អាចនឹងជួបប្រទះអសន្តិសុខស្បៀង ព្រោះពួកគេចាំបាច់ត្រូវបង្កើនចំនាយលើម្ហូបអាហារ ម្លោះហើយប្រាក់ដែលត្រូវយកទៅចំណាយលើការសិក្សារបស់កូនៗត្រូវបានកាត់បន្ថយ ។ ក្នុងករណីនេះឱកាសដែលធ្វើអោយពួកគេអាចទទួលបានផលចំណេញ ដោយបង្កើនចំណូលអោយខ្ពស់ជាងអ្វីដែលត្រូវចំណាយទៅលើការឡើងថ្លៃនៃជីវភាពរបស់ពួកគេ គឺមិនអាចកើតឡើងបានទេ ឬអាចនិយាយម្យ៉ាងទៀតថា ករណីនេះមិនអាចអោយពួកគេចាកផុតពីភាពក្រីក្រឡើយ ។ ផ្តោតទៅលើផលវិជ្ជមានវិញ ប្រសិនបើថ្លៃទំនិញអាចស្ថិតនៅខ្ពស់ដូច្នេះរហូតក្នុងរយៈពេលមធ្យម វាជាឱកាសមាសសំរាប់ឱ្យប្រជាកសិករកម្ពុជាបង្កើនទិន្នផល និងពិពិធកម្មកសិកម្ម ហើយវាក៏ប្រហែលជាឱកាសមួយដែលអាចទាក់ទាញការវិនិយោគបន្ថែមលើវិស័យកសិកម្ម ដែលអាចបង្កើនការងារសំរាប់ជនក្រីក្រ និងប្រជាជននៅទីជនបទផងដែរ ។ កំណើនការវិនិយោគទុនទៅលើផលិតកម្ម និងពិពិធកម្មកសិកម្ម គួរតែអាចនាំឱ្យមានកំណើនតំរូវការ និងប្រាក់ឈ្នួលនៃកំលាំងពលកម្មក្នុងវិស័យកសិកម្ម ដែលនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ជនក្រីក្រដែលមិនមានដីជាកម្មសិទ្ធ តាមរយៈការចូលរួមរបស់ពួកគេនៅក្នុងទីផ្សារពលកម្ម ។ សមិទ្ធផលដែលបានពីកំណើនផលិតកម្មកសិកម្ម និងទំហំទីផ្សារ អាចជួយឱ្យកម្ពុជា សំរេចបាននូវកំណើន និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស ។

## ២. ការឆ្លើយតបពីសំណាក់អ្នកផ្តល់ជំនួយ និងរដ្ឋាភិបាល ចំពោះការឡើងថ្លៃម្ហូបអាហារ និងទំនិញចាំបាច់ផ្សេងៗ

រដ្ឋាភិបាលកម្ពុជា និងអ្នកផ្តល់ជំនួយនានា បាននិងកំពុងធ្វើការរួមគ្នា ដើម្បីដាក់ចេញនូវគោលនយោបាយបន្ទាន់មួយ ដើម្បីឆ្លើយតបទៅនឹងវិបត្តិម្ហូបអាហារ និងរក្សាបាននូវកំណើនដែលជាកត្តាសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ វិធានការណ៍នៃគោលនយោបាយនេះ រួមមាន (១) មូលនិធិពីរដ្ឋាភិបាល និងធនាគារអភិវឌ្ឍអាស៊ី ចំនួន ៣,៥លានដុល្លាសំរាប់រក្សាសន្តិសុខស្បៀង (២) សកម្មភាពជាបណ្តោះអាសន្នរបស់រដ្ឋាភិបាល ដើម្បីហាមឃាត់ការនាំចេញស្រូវ ក្នុងគោលដៅបង្កើនស្តុកស្រូវក្នុងស្រុក និងលក់ស្រូវទៅឱ្យប្រជាជនក្រីក្រក្នុងតំលៃថោក ក្នុងរយៈពេលមុនការបោះឆ្នោតជាតិឆ្នាំ២០០៨ ។ ដើម្បីធានានូវឱកាសការងារ និងជួយគាំទ្រដល់ការធ្វើអន្តោប្រវេសន៍ពលកម្ម រដ្ឋាភិបាលបានសំរេចចេញនូវលិខិតឆ្លងដែនដោយឥតគិតថ្លៃ ដល់ប្រជាជនកម្ពុជាដែលធ្វើចំណាកស្រុកទៅធ្វើការនៅតាមច្រកព្រំដែន និងបានលើកទឹកចិត្តដល់ក្រុមហ៊ុនជ្រើសរើសពលករ តាមរយៈការអនុញ្ញាតឱ្យបង់ថ្លៃទិដ្ឋាការសំរាប់ពលករចំណាកស្រុកជាឥណទាន នៅចុងឆ្នាំ២០០៨ ។ លើសពីនេះទៀត ប្រជាជនក្រីក្រអាចទទួលបានប្រយោជន៍ពីមូលនិធិសមធម៌សុខភាពដែលបង្កើតឡើងដើម្បីជំរុញអោយមានភាពប្រសើរឡើងនៃសេវាសុខភាពសំរាប់ជនក្រីក្រ ហើយថវិកានេះចាប់ផ្តើម

មានប្រសិទ្ធភាពនៅឆ្នាំ២០០៧ ។ ផលិតករកសិកម្មអាចអភិវឌ្ឍនូវរបៀបធ្វើកសិកម្ម និងផលិតភាពកសិកម្មរបស់ខ្លួន ដោយបាន ជំនួយគាំទ្រពីរដ្ឋាភិបាលតាមរយៈគោលនយោបាយផ្តល់ឧបត្ថម្ភធនលើការនាំចូលគ្រឿងចក្រផ្នែកកសិកម្ម និងការប្តេជ្ញាចិត្តក្នុងការធ្វើអោយវិស័យកសិកម្មរីកលូតលាស់ ដោយធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន និងដាក់អនុវត្តនូវយុទ្ធសាស្រ្តអភិវឌ្ឍផ្សេងៗ ។

## ៣. ការកើនឡើងនៃថ្លៃទំនិញនៅតំបន់ជនបទ

ថ្លៃទំនិញប្រើប្រាស់ទាំងផ្នែកអាហារ និងមិនមែនអាហារនៅតាមទីជនបទ មានកំរិតខ្ពស់ជាងថ្លៃទំនិញនៅថ្នាក់ជាតិ ដែលកំណត់ដោយសន្ទស្សន៍ថ្លៃនៅទីក្រុងភ្នំពេញ ហើយដែលផ្សព្វផ្សាយដោយរដ្ឋាភិបាល ។មធ្យមភាគនៃថ្លៃទំនិញប្រើប្រាស់ទូទៅនៅជនបទ កើនឡើង ៨៦% ដែលរឹតតែធ្ងន់ធ្ងរជាង អត្រា ៣៤% នៃសន្ទស្សន៍ថ្លៃនៅទីក្រុងភ្នំពេញ និងដែលមន្ត្រីរាជរដ្ឋាភិបាលបានប្រកាសថា ជាភាពមិនប្រក្រតីនៃការឡើងថ្លៃនៃទំនិញប្រើប្រាស់ សំរាប់រយៈពេល ៣ឆ្នាំចុងក្រោយនេះ (តារាង ៤.១) ។ការកើនឡើង ទាំងថ្លៃដោះដូរ និងថ្លៃដឹកជញ្ជូនទំនិញ និងសេវាកម្មទៅទីជនបទ អាចជាហេតុផលដ៏សំខាន់មួយសំរាប់ពន្យល់ពីភាពខុសគ្នាដ៏សំបើមនៃការកើនឡើងថ្លៃទំនិញរវាងទីក្រុង និងជនបទ ។

**តារាង ៤.១: អត្រាអតិផរណាធៀបនឹងខែតុលា ឆ្នាំ២០០៥ = ១០០**

| | ទំនិញអាហារ | | ទំនិញមិនមែនអាហារ | | ទំនិញគ្រប់មុខ | |
|---|---|---|---|---|---|---|
| | មីនា ២០០៨ | កញ្ញា ២០០៨ | មីនា ២០០៨ | កញ្ញា ២០០៨ | មីនា ២០០៨ | កញ្ញា ២០០៨ |
| អណ្តូងត្រាច | 56% | 79% | 38% | 67% | 50% | 75% |
| ក្រសាំង | 73% | 90% | 41% | 79% | 61% | 86% |
| ខ្សាច់ជីរស់ | 109% | 93% | 49% | 64% | 93% | 86% |
| កញ្ជរ | 109% | 114% | 44% | 66% | 90% | 100% |
| ព្រែកក្មេង | 77% | 81% | 68% | 96% | 74% | 86% |
| បាបោង | 90% | 96% | 69% | 95% | 81% | 95% |
| ដងក្តារ | 82% | 87% | 60% | 92% | 75% | 88% |
| ត្រពាំងប្រីយ | 81% | 87% | 43% | 80% | 67% | 84% |
| កំពង់ត្នោត | 61% | 74% | 47% | 76% | 56% | 74% |
| ភូមិទាំង៩ | 81% | 94% | 41% | 71% | 68% | 86% |

*ប្រភព: ការអង្កេតថ្លៃអាហារ របស់ វិបសអ*

នៅខែកញ្ញា ២០០៨ ទំនិញម្ហូបអាហារ និងមិនមែនម្ហូបអាហារ ជាមធ្យមឡើងថ្លៃ ៩៤% និង ៧១% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តារាង ៤.១) ហើយការឡើងថ្លៃនេះ ប្រែប្រួលខុសគ្នាតាមតំបន់ភូមិសាស្រ្ត ។ភូមិខ្សាច់ជីរស់ និងភូមិកញ្ជរដែលស្ថិតនៅតំបន់ដាច់ស្រយាល មានអត្រាអតិផរណាថ្លៃអាហារខ្ពស់បំផុតនៅកំឡុងពេល ៣ឆ្នាំកន្លងទៅ ដោយថ្លៃមធ្យមនៃអង្ករកើនឡើងមួយជាពីរ ។ ភូមិខ្សាច់ជីរស់ ជាភូមិនេសាទផង និងបង្កបង្កើនផលស្រូវផង (ទាំងរដូវប្រាំង និងរដូវវស្សា) ចំនែកឯភូមិកញ្ជរ ជាតំបន់ផ្អែកទៅលើព្រៃឈើ ហើយកំពុងធ្វើអន្តរកាលផ្លាស់ប្តូរពីទំលាប់ដាំដុះចល័ត ទៅជាធ្វើការដាំដុះជាអចិន្ត្រៃយ៍នូវដំណាំលក់យកប្រាក់វិញ ។ ការឡើងថ្លៃម្ហូបអាហារនៅក្នុងភូមិទាំងនេះ ក៏បណ្តាលមកពីកំណើនទំនាក់ទំនងជាមួយទីផ្សារនៅទីក្រុង និងការកសាងផ្លូវជនបទផងដែរ ។ដោយហេតុថា ភូមិដែល

បានសិក្សាស្ទើរតែទាំងអស់ សុទ្ធតែផលិតអាហារដោយខ្លួនឯង ដូច្នេះ ផលប៉ះពាល់ជាវិជ្ជមានបានពីការឡើងថ្លៃម្ហូបអាហារ ទំនងជាលុបលើផលប៉ះពាល់ជាអវិជ្ជមានទៅលើបំរែបំរួលភាពក្រីក្រ និងសុខមាលភាពរបស់សហគមន៍ទាំងនោះ ។ ទំហំអត្ថប្រយោជន៍ដែលក្រុមគ្រួសារនៅជនបទ អាចទទួលបានពីបាតុភូតខុសប្រក្រតីបែបនេះ គឺផ្អែកលើលទ្ធភាព និងសមត្ថភាពផលិតរបស់ពួកគេ ក្នុងការឆក់យកឱកាសសេដ្ឋកិច្ចដែលផុសចេញពីការឡើងថ្លៃទំនិញនេះ ។ ក្រុមគ្រួសារចំនួន៥០% ក្នុងភូមិទាំង៩នៃការសិក្សា មិនមានដីធ្វើកសិកម្មឡើយនៅឆ្នាំ២០០៨ ហើយពួកគេត្រូវបានចាត់ចូលទៅក្នុងប្រភេទ អ្នកទិញម្ហូបអាហារសុទ្ធ បើទោះជាមានអ្នកខ្លះអាចស្វែងរកបានដីសំរាប់ធ្វើស្រែចំការតាមរយៈការជួល ឬការអនុញ្ញាតពីម្ចាស់ដីក៏ដោយ ។

## ៤. ផលប៉ះពាល់នៃការឡើងថ្លៃទំនិញ ទៅលើសុខមាលភាពក្រុមផ្សេងៗ និងការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ

នៅក្នុងប្រទេសកម្ពុជា ក្នុងកំឡុងឆ្នាំ២០០៨ នេះ មានក្រុមគ្រួសារប្រមាណ ២៥% ត្រូវបានចាត់ទុកជាគ្រួសារក្រីក្រ ហើយប្រមាណ ៩២% នៃពួកគេទាំងនោះ រស់នៅតាមទីជនបទ ។ សុខមាលភាព និងសន្តិសុខស្បៀងរបស់ពួកគេអាចងាយទទួលរងផលប៉ះពាល់ណាស់ ។ ជាទូទៅ គ្រួសារក្រីក្រ មិនមានដីជាកម្មសិទ្ធ ឬមានដីកម្មសិទ្ធតូច មិនលើសពីមួយហិកតាទេ ដែលមិនអាចឱ្យពួកគេទទួលបានផលស្រូវគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងគ្រួសារឡើយ (តាមការអង្កេតរបស់ វិបសអ ឆ្នាំ២០០៨ និង Fitzgerald and So., 2007) ។ មានតែគ្រួសារដែលមានដីពី ២ ទៅ ៣ហិកតាប៉ុណ្ណោះ ដែលអាចផលិតស្រូវលើសសំរាប់ទុកលក់ ។ ក្នុងចំណោម ១០០៩គ្រួសារនៃការសិក្សាពីឌីណាមិកនៃភាពក្រីក្រ មានតែ ២៤% ប៉ុណ្ណោះ ដែលមានដី ២ហិកតា ឬច្រើនជាង សំរាប់ដាំស្រូវ ឬអាចផលិតស្រូវបានលើស សំរាប់ទុកលក់ ។ ទោះជាយ៉ាងនេះក្តី កសិករទាំងនេះភាគច្រើន បានលក់ស្រូវរបស់ពួកគេ បន្ទាប់ពីពេលច្រូតកាត់ ឬមុនពេលដែលអង្ករឡើងថ្លៃនៅក្រោយខែមករា ២០០៨ ។ ក្នុងភូមិដែលយើងធ្វើការសិក្សា មានតែកសិករធ្វើស្រែប្រាំងប៉ុណ្ណោះ ដែលអាចទទួលបានប្រយោជន៍ពីការឡើងថ្លៃអង្ករក្នុងពេលថ្មីៗនេះ ។

គ្រួសារ ៤៦% នៅក្នុងភូមិដែលបានសិក្សា ជាគ្រួសារក្រីក្រ ។ ទំនិញឡើងថ្លៃ មានផលប៉ះពាល់ខ្លាំងចំពោះប្រជាជនក្រីក្រដែលជាអ្នកទិញអាហារពីគេសុទ្ធ ប្រសិនបើចំណូលរបស់ពួកគាត់ មិនអាចឡើងទាន់អត្រាអតិផរណា ។ មួយវិញទៀត ផលប៉ះពាល់ទៅលើការរកចំណូល និងការចិញ្ចឹមជីវិតរបស់ក្រុមផ្សេងៗអាចកើតឡើង ដោយសារការឡើងថ្លៃសេវាដឹកជញ្ជូន និងសេវាទំនាក់ទំនងផ្សេងៗ ។ម្យ៉ាងវិញទៀត ការថែទាំផ្ទះសំបែង និងការប្រើប្រាស់ផ្សេងៗបានឡើងថ្លៃរហូតដល់ ២៦% និង ១២% ក្នុងរយៈពេល ១ឆ្នាំចុងក្រោយ ។ ទាំងនេះគ្រាន់តែជាការលើកឡើងមួយផ្នែកតូចនៃការសិក្សាដែលបង្ហាញពីកំណើននៃជនក្រីក្រ ដោយសារតែវិបត្តិអាហារនេះ ។ ផលប៉ះពាល់ដែលកាន់តែធ្ងន់ធ្ងរគឺការចុះក្រកាន់តែខ្លាំងរបស់ប្រជាជន ព្រមទាំង ឥទ្ធិពលរយៈពេលវែងផ្សេងៗ ទៅលើបញ្ហាសុខភាព ការអប់រំរបស់ពួកគេការបាត់បង់ទ្រព្យសម្បត្តិសំរាប់ចូលរួមក្នុងផលិតកម្ម ការជំពាក់បំណុលគេ ពលកម្មកុមារ និងការធ្វើចំណាកស្រុក ។

### ៤.១. ផលប៉ះពាល់ទៅលើក្រុមក្រីក្ររ៉ាំរ៉ៃ និងយុទ្ធសាស្ត្រដោះស្រាយ

អ្នកដែលជាជនក្រីក្រតាំងពីមុនពេលទំនិញឡើងថ្លៃ បានសំរេចចិត្តកាត់បន្ថយអាហារ និងដាក់កំហិតលើការប្រើប្រាស់សេវាសុខភាព និងសេវាអប់រំ ។ នៅឆ្នាំ២០០៨ នៅក្នុងភូមិដែលបានសិក្សា មានប្រជាជន ៣៥% ជាគ្រួសារក្រីក្រ

និង ១១% ជាគ្រួសារក្រីក្រខ្លាំង ។ ពួកគេទាំងនោះ មិនមាន ឬមានដីអាចដាំដំណាំបានយ៉ាងធំបំផុតត្រឹម ១ហិកតា ហើយទំហំនេះមិនអាចឱ្យពួកគេផលិតអាហារបានគ្រប់គ្រាន់ ទុកសំរាប់ប្រើប្រាស់ពេញមួយឆ្នាំបានឡើយ ។

គ្រួសារក្រីក្រ ៤១% និងមិនមែនក្រីក្រ ៥៥%ប៉ុណ្ណោះដែលអាចផលិតអាហារបានគ្រប់គ្រាន់ ឬលើសបន្តិចបន្តួច និងមានគ្រួសារក្រីក្រលើសពី ២៦% និងគ្រួសារមិនមែនក្រីក្រ ២២%ទៀត ត្រូវទិញអង្ករពីអ្នកដទៃស្ទើរពេញមួយឆ្នាំ ។ នៅខែឧសភា និងតុលា ២០០៨ ថ្លៃអាហារកើនឡើងមួយជាពីរ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខស្បៀងរបស់គ្រួសារក្រីក្រយ៉ាងតិច ៤៣% និងគ្រួសារមិនមែនក្រីក្រ ៣២% ។ ពួកគេស្ទើរតែគ្រប់គ្នា ជាអ្នកទិញអាហារទាំងស្រុងពីអ្នកដទៃ ហើយត្រូវប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីដោះស្រាយហានិភ័យ ឬតំរូវការចាំបាច់ក្នុងគ្រួសារ ។ ទោះបីជាតំលៃពលកម្ម កើនឡើងមួយជាពីរ ឬមួយជាបី ធៀបនឹងកាលពី ២-៣បីឆ្នាំមុនក្តី ក៏តំរូវការនូវពលកម្មនេះ វាមានតាមរដូវកាល និងមិនទៀងទាត់ឡើយ ។ ជនក្រីក្រពិបាករកបានការងារដែលឋិតថេរជាប់លាប់ពេញមួយឆ្នាំណាស់ ។

គ្រួសារមួយចំនួន លែងបានទទួលបានប្រាក់បញ្ញើពីសមាជិកដែលធ្វើចំណាកស្រុកទៅធ្វើការខាងក្រៅដូចមុនទៀត ដោយសារតែបញ្ហាទំនិញឡើងថ្លៃនេះ ។ នៅពេលមិនមានការងារគ្រប់គ្រាន់ និងមុនពេលខ្ចីបុលបានពីសាច់ញាតិ ឬស្ថាប័នហិរញ្ញវត្ថុតូចតាច គ្រួសារក្រីក្រខ្លាំង ត្រូវតែកាត់បន្ថយការបរិភោគអាហារក្នុងពេលដែលអង្ករឡើងថ្លៃមួយជាពីរបែបនេះ ។ កុមារក្រីក្រតែងតែមិនមានអាហារបរិភោគគ្រប់គ្រាន់ ហើយត្រូវបញ្ឈប់ការសិក្សាភ្លាមៗ ដើម្បីទៅជួយរកប្រាក់ជាមួយគ្រួសាររបស់ពួកគេ ។ យុទ្ធសាស្ត្រប្រឈមបែបនេះ តែងត្រូវបានលើកឡើងដោយកម្មករដែលធ្វើការរកប្រាក់កំរៃប្រចាំថ្ងៃ ដូចជា កម្មករសំណង់ និងកម្មករស៊ីឈ្នួល តាមកសិដ្ឋានជាដើម ។ លើសពីនេះ ការឡើងថ្លៃម្ហូបអាហារ បានជំរុញឱ្យអ្នកក្រីក្រត្រូវស្វែងរក និងប្រើប្រាស់ប្រាក់កំចីសំរាប់ទិញម្ហូបអាហារ ហើយគ្រួសារក្រីក្រខ្លាំងដែលជារឿយៗត្រូវចូលទៅរកស្ថាប័នហិរញ្ញវត្ថុតូចតាចទាំងនោះ ត្រូវទិញអង្ករដោយឥណទាន ហើយសន្យាសងវិញជាពលកម្ម ។ អ្នកចូលរួមក្នុងការពិភាក្សាតាមក្រុមស្នូល បានឱ្យដឹងថា ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ កំណើនសេវាស្ថាប័នប្រាក់កំចីតូចតាច ដែលគិតអត្រាការប្រាក់ត្រឹម ៣% បានជួយដោះស្រាយការលំបាករបស់ពួកគេជាច្រើននៅពេលពួកគេកំពុងប្រឈមមុខនឹងការឡើងថ្លៃម្ហូបអាហារ ជាពិសេសនៅពេលពួកគេមិនមានចំណូល ឬមិនមានការងារធ្វើ ។ ក្នុងការពិភាក្សាតាមក្រុមស្នូលជាមួយនឹងក្រុមជនក្រីក្រ និងគ្រួសារដែលមាននារីជាមេគ្រួសារ មិនមានអ្នកចូលរួមណាម្នាក់ដែលសប្បាយចិត្តនឹងការឡើងថ្លៃអង្ករនេះឡើយ ។ ពួកគេទាំងអស់គ្នាចង់ឱ្យអង្ករ និងប្រេងចុះថ្លៃវិញ ។

## ៤.២. *ផលប៉ះពាល់ទៅលើគ្រួសារមិនក្រីក្រ និងយុទ្ធសាស្ត្រដោះស្រាយ*

នៅក្នុងភូមិសិក្សាទាំងប្រាំបួន ក្នុងចំណោម ១៣៥០គ្រួសារដែលបានចូលរួមក្នុងការធ្វើចំណាត់ថ្នាក់អ្នកធូរធារ និងអ្នកក្រ មាន ១៥% អាចទាញផលប្រយោជន៍ពីការឡើងថ្លៃទំនិញ ។ ពួកគេទាំងនោះភាគច្រើនជាកសិករមានដីធំៗ អ្នកជំនួញ ឬអ្នកចងការប្រាក់ ហើយត្រូវបានចាត់ជាគ្រួសារមានជីវភាពធូរធារ ។ "គ្រួសារអ្នកមធ្យម" មានដីសំរាប់ធ្វើស្រែជាមធ្យម ១,៥ហិកតា ហើយពួកគេតែងលក់ផលស្រូវមួយចំនួនបន្ទាប់ពីការច្រូតកាត់ ដើម្បីសងបំណុល ឬផ្គត់ផ្គង់គ្រួសារ ។ ស្រូវដែលនៅសល់ពីលក់ គឺគ្រប់គ្រាន់សំរាប់ពួកគេបរិភោគ តែក្នុងរយៈពេល ៤-៥ខែប៉ុណ្ណោះ ។ អ្នកមធ្យមទាំងនោះក៏ក្លាយជាអ្នកទិញអាហារនៅចន្លោះពីខែឧសភា ដល់ វិច្ឆិកា ឆ្នាំ២០០៨ គឺចំពេលដែលទំនិញឡើងថ្លៃដល់កំរិតខ្ពស់បំផុត ។ ប្រការនេះ គួបផ្សំនឹងវិបត្តិគ្រួសារផ្សេងៗ បានធ្វើឱ្យគ្រួសារអ្នកមធ្យមប្រហែល ១០% មានជីវភាពយ៉ាប់យ៉ឺនជាងមុន ហើយនឹងធ្លាក់ខ្លួនក្រ ប្រសិនបើថ្លៃម្ហូបអាហារនៅតែមានកំរិតខ្ពស់ យោងតាមការបញ្ជាក់របស់អ្នកដឹកនាំ

មូលដ្ឋាន ។ទោះបីគ្រួសារអ្នកមធ្យម ប្រមាណ១២% អាចរក្សាជីវភាពឱ្យនៅថេរក៏ដោយ មានគ្រួសារមួយចំនួនបានក្លាយជាអ្នកអត់ដីស្រែដោយសារការលក់ដីនិងការផ្ទេរដីឱ្យកូនដែលទើបរៀបការថ្មីថ្មោង ។ពួកគេត្រូវពឹងលើចំណូលមិនទៀងទាត់ពីការលក់ពលកម្ម ។

## ៥. ផលប៉ះពាល់នៃអត្រាឡើងថ្លៃ នៅលើពិពិធកម្ម និងផលិតកម្មកសិកម្ម

តំលៃផលិតផលកសិកម្មនៅកម្ពុជា កើនឡើងចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៥ ។ តំរូវការ និងតំលៃកសិផលមានការប្រែប្រួលខ្លាំង មួយចំណែកបណ្តាលឡើងដោយបាតុភូតសកលភាវូបនីយ៍កម្មសេដ្ឋកិច្ច ។ ព្រឹត្តិការណ៍ទំនិញឡើងថ្លៃនេះ ផ្តល់ឱកាស និងក៏ជាឧបសគ្គនៃការអភិវឌ្ឍន៍កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា ។ស្ថិតិជាតិប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៦ បានបង្ហាញថា ទាំងផលិតកម្មគ្រាប់ធញ្ញជាតិ ដំណាំ និងការចិញ្ចឹមសត្វ បានកើនឡើងគួរឱ្យកត់សំគាល់ចាប់តាំងពីឆ្នាំ២០០០ មក ។ ជាលទ្ធផល ប្រទេសកម្ពុជាបានផលិតស្រូវលើស សំរាប់នាំចេញប្រហែលជាង ២លានតោន នៅឆ្នាំ២០០៧ និង ២០០៨ ។

### *ផលប៉ះពាល់នៅលើផលិតកម្មកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ នៅភូមិដែលបានជ្រើសរើសសំរាប់ការសិក្សាឌីណាមិកនៃភាពក្រីក្រ*

ភូមិសិក្សាទទួលលទ្ធផលផ្សេងគ្នាពីការឡើងថ្លៃនៃទំនិញ ក្នុងការលើកស្ទួយការអភិវឌ្ឍនិងចំរុះកម្មកសិកម្ម ។ យ៉ាងហោចណាស់ ភូមិបីក្នុងចំណោមភូមិដែលធ្វើការសិក្សា អាចក្តោបយកឱកាសល្អអំពីកំណើនតំរូវការ និងការឡើងថ្លៃកសិផល ដើម្បីបង្កើនផលិតកម្មកសិកម្ម ។ ភូមិទាំងនេះ រួមមាន ភូមិដែលពឹងពាក់លើព្រៃឈើ ដូចជាភូមិកញ្ជរ និងភូមិដងក្តារ និងភូមិខ្សាច់ជីរស់ដែលជាសហគមន៍នេសាទ ដោយសារលទ្ធភាពពង្រីកដីដាំដុះ ។ការឡើងថ្លៃទំនិញនេះ បានជំរុញឱ្យមានកំនើនការដាំដំណាំកសិឧស្សាហកម្ម ឬដំណាំសំរាប់លក់ ។ រីឯបសុវប្បកម្មនៅតែត្រូវប្រឈមនឹងការប្រកួតប្រជែងអំពីផលិតផលបសុសត្វនាំចូលពីប្រទេសជិតខាង ។

### *ការជំរុញផលិតកម្មដំណាំលក់យកប្រាក់*

នៅភូមិកញ្ជរ និងភូមិដងក្តារ ផលិតកម្មដំណាំលក់យកប្រាក់ ដូចជា ដំឡូងឈើ សណ្តែក និងពោត បានកើនឡើងគួរឱ្យកត់សំគាល់ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ បើទោះជាផលិតកម្មនេះ នៅមិនទាន់ឈានដល់ដំណាក់កាលនៃការលូតលាស់ពេញលេញក្តី ។ ផលិតកម្មដំណាំលក់យកប្រាក់នៅតំបន់នេះ បានចាប់ផ្តើមធ្វើឡើងលើកដំបូងនៅឆ្នាំ២០០៦ ដោយអ្នកមកពីតំបន់ខាងក្រៅ ដែលភាគច្រើនមកពីខេត្តកំពង់ចាម និងព្រៃវែង ។ ដោយក្តាប់បានព័ត៌មានក្រុមគ្រួសារដែលមកពីខាងក្រៅទាំងនោះ បានចូលមកចាប់យក ឬទិញ និងកាប់ឆ្ការដីព្រៃពី ២-៥ហិកតាក្នុងមួយគ្រួសារ ដើម្បីធ្វើចំការ ។ ពួកគេអាចរកប្រាក់ចំណេញបានប្រហែលពី ៨០០-១០០០ដុល្លារក្នុងមួយឆ្នាំ ពីការដាំដំឡូងឈើ និងរកបាន ២០០-៣០០ដុល្លារបន្ថែមទៀត ពីការប្រមូលផលសណ្តែកសៀងលើផ្ទៃដី ១ហិកតា ។ ម្ចាស់ស្រុកជាបណ្តើរៗបានចូលរួមក្នុងចលនានេះដែរ ដោយប្តូរពីការធ្វើកសិកម្មពនេរចរ ទៅធ្វើកសិកម្មអចិន្ត្រៃយ៍ ដាំដំណាំសំរាប់លក់យកប្រាក់វិញ ។

ក្នុងពេលដែលនិន្នាការនេះ បាននាំមកនូវការរីកចំរើនជីវភាព និងទ្រព្យធនរបស់អ្នកចំណូលស្រុក និងអ្នកស្រុកដើម ក្រុមហ៊ុនធំៗ និងអ្នកមានអំណាច ក៏បានចូលមកតំបន់នេះ ហើយធ្វើការប្រកួតប្រជែងជាមួយពួកកសិករដាំដុះបាន

មួយរស់ ក្នុងការកែច្នៃដីព្រៃទៅជាចំការកៅស៊ូ ឬចំការដំឡូងឈើ ជាទ្រង់ទ្រាយកសិពាណិជ្ជកម្មធំៗ ។ រឿងនេះ បានធ្វើឱ្យមានការកើនឡើងនូវតំរូវការ និងថ្លៃឈ្នួលពលកម្ម ចាប់ពី ៥០០០រៀលនៅឆ្នាំ២០០៥ រហូតដល់ ១៥.០០០រៀល/ថ្ងៃ នៅឆ្នាំ២០០៨ ។ ដូចនេះ ប្រជាជនក្រីក្រដែលមិនមានលទ្ធភាពឆ្ការដីព្រៃ ដើម្បីធ្វើកសិកម្មដោយខ្លួនឯង ក៏អាចទទួលបានចំណេញផងដែរ ពីការធ្វើការងារឱ្យពួកទាំងនោះ ។

ជំលោះស្តីពីសិទ្ធិប្រើប្រាស់ និងកាន់កាប់ដី សំរាប់ទ្រទ្រង់គ្រួសារ និងធ្វើកសិពាណិជ្ជកម្ម ក៏កើតមានឡើង និងមិនទាន់ដោះស្រាយឱ្យបានត្រឹមត្រូវរួចរាល់នៅឡើយទេ ហើយបញ្ហានេះបានក្លាយជាឧបសគ្គដល់ការរីកចំរើនផលិតកម្មដំណាំលក់យកប្រាក់ក្នុងតំបន់ ។ ជំលោះនេះមានភាពកាន់តែធ្ងន់ធ្ងរនៅភូមិដងក្តារ ដោយពាក់ព័ន្ធដល់ប្រជាជនទូទាំងឃុំក្រយាដងក្តារ និងក្រុមហ៊ុនវៀតណាមដែលទទួលបានសម្បទានសេដ្ឋកិច្ច-កសិកម្មពីរដ្ឋាភិបាល ។

## ការជំរុញផលិតកម្មស្រូវប្រាំង

នៅភូមិខ្សាច់ជីរស់ ចាប់ពីឆ្នាំ២០០៥ មក កំណើនតំរូវការ និងថ្លៃអង្ករ បានធ្វើឱ្យប្រជាជនផ្លាស់ប្តូរពីការដាំដុះស្រូវលិចទឹក ទៅធ្វើស្រូវប្រាំងដែលផ្តល់ទិន្នផល និងចំណូលខ្ពស់ជាង ដល់ ៣-៤តោន/ហិកតា គឺលើសពីការធ្វើស្រូវឡើងទឹកដល់ទៅមួយជាពីរជាមធ្យម ។ ចាប់តាំងពីឆ្នាំ២០០៥ ការកាប់ឆ្ការដីព្រៃលិចទឹកមានសភាពខ្លាំងខ្លា ជាពិសេសក្នុងរវាង២-៣ឆ្នាំមុនការបោះឆ្នោតជាតិ នៅខែកក្កដា២០០៨ ។នៅពេលនោះ ជំលោះពីបញ្ហាទឹក ក៏កើតមានឡើងរវាងកសិករជាម្ចាស់ឡូតិ៍នេសាទក្នុងតំបន់ និងជនចំណូលថ្មីដែលបានកសាងទំនប់ទឹកដ៏ធំសំរាប់យកទឹកប្រើប្រាស់ ហើយជំលោះនេះមិនទាន់បានដោះស្រាយនៅឡើយទេ ។ ដីដែលត្រូវបានកែច្នៃស្ទើរតែទាំងអស់ បានប្រើប្រាស់សំរាប់ដាំស្រូវផ្តល់ទិន្នផលខ្ពស់ប្រភេទ IR 66 ។ ជាលទ្ធផល ភូមិខ្សាច់ជីរស់ បានក្លាយជាតំបន់ដាំស្រូវប្រាំងដ៏សកម្មមួយ និងជាភូមិផលិតស្រូវលើសពីសេចក្តីត្រូវការចាប់តាំងពីឆ្នាំ២០០៥ មក ។

**តារាង ៤.២: មធ្យមភាគសរុបនៃផលិតកម្ម និងទិន្នផលស្រូវប្រាំងវស្សានៃក្រុមម្ចាស់ដីផ្សេងៗ ២០០៤_០៨**

| ទំហំដីស្រែ | ចំនួនគ្រួ | មធ្យមភាគសរុបនៃផលិតកម្មស្រូវឆ្នាំ២០០៨ (kg/hh) | ទិន្នផលស្រូវជាមធ្យមនៅក្នុងឆ្នាំដាំដុះ ២០០៧-២០០៨ (kg/ha) | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ស្រូវប្រាំង | | | ស្រូវវស្សា | | |
| | | | 2004-05* | NHH-08 | 2007-08 | 2004-05* | NHH-08 | 2007-08 |
| មិនទាន់ច្រូតកាត់ | 302 | 0 | | | | | | |
| <0.5 ha | 125 | 662 | 3,564 | 49 | 3,281 | 1,721 | 97 | 2,099 |
| 0.5-0.99 ha | 182 | 1,221 | 3,006 | 70 | 2,893 | 1,462 | 138 | 1,582 |
| 1-1.99 ha | 196 | 2,726 | 3,163 | 75 | 3,319 | 1,573 | 131 | 1,475 |
| 2-2.99 ha | 96 | 5,560 | 3,161 | 39 | 3,871 | 1,123 | 61 | 1,505 |
| >=3 ha | 108 | 12,323 | - | 52 | 3,825 | - | 51 | 1,906 |
| សរុប | 1009 | 2,680 | 3,281 | 285 | 3,376 | 1,535 | 478 | 1,682 |

*សំគាល់: *តួលេខនេះបានមកពីការអង្កេតគ្រួសារលើ ៨៩០គ្រួសារ នៅឆ្នាំ២០០៤-៥*

រឿងនេះត្រូវបានគេចាត់ទុកថា ជាប្រភពនៃការប្រកបរបរចិញ្ចឹមជីវិតមួយថ្មី និងការវិវត្តន៍ល្អប្រសើរមួយ ។ មិនមែននៅគ្រប់ភូមិដាំដុះស្រូវ សុទ្ធតែមានសំណាងល្អដូចភូមិខ្សាច់ជីរស់ដែលអាចបង្កើនទិន្នផលស្រូវ ដើម្បីទាញយក

ប្រយោជន៍ពីការឡើងថ្លៃម្ហូបអាហារនោះទេ ។ បើទោះជាដំណាំស្រូវក៏ជាប្រភពនៃការចិញ្ចឹមជីវិត និងប្រភពចំណូលចំបងនៅភូមិឯទៀតៗដែរ ប៉ុន្តែផលិតភាពស្រូវនៅភូមិទាំងនោះទំនងជាមានស្ថិរភាពជាង ដោយសារលក្ខខណ្ឌអាកាសធាតុអំណោយផលក្នុងកំឡុងពេលបីឆ្នាំចុងក្រោយនេះ ។តារាង២ បង្ហាញថា ទិន្នផលស្រូវជាមធ្យមនៅឆ្នាំ២០០៨គឺខ្ពស់ជាងទិន្នផលកាលពីឆ្នាំ២០០៤-០៥ បន្តិច ។ ពត៌មាននេះ មានការគាំទ្រនៅក្នុងការពិភាក្សាតាមក្រុមស្នូល ដោយពួកគេបញ្ជាក់ថា ទិន្នផលនេះបានមកពីទឹកភ្លៀងអំណោយផល ហើយនៅភូមិបាបោង និងខ្សាច់ជីរស់ អ្នកភូមិលើកថាមានការកែលំអប្រព័ន្ធធារាសាស្ត្រ ។កសិករនៅក្នុងភូមិទាំងពីរនេះ អាចបង្កើនទិន្នផលស្រូវប្រាំងបាន ១៦% និង ២១% រៀងគ្នា ។ ទោះយ៉ាងនេះ ការឡើងថ្លៃធាតុចូលដូចជា ជីគីមី និងប្រេងឥន្ធនៈសំរាប់បូមទឹក បានដាក់កំហិតលើសមត្ថភាពកសិករតូចតាចក្នុងការបង្កើនផលិតភាពដាំដុះស្រូវ ។ ផ្ទុយទៅវិញ កសិករដែលមានដីស្រែធំៗ បែរជាអាចបង្កើនទិន្នផលស្រូវយ៉ាងច្រើន ។

ដោយមិនអាចប្រឈមមុខនឹងការឡើងថ្លៃធាតុចូលកសិកម្មដូចជា ជីគីមី ថ្នាំសំលាប់សត្វល្អិត និងប្រេងឥន្ធនៈក៏ដូចជាកង្វះប្រព័ន្ធធារាសាស្ត្រនោះ ប្រជាជននៅភូមិត្រពាំងប្រីយ និងភូមិព្រៃកក្អេង ដែលជាតំបន់ទទួលរងឥទ្ធិពលខ្លាំងពីការកកើតទីប្រជុំជន និងការឆក់ឱកាសកេងចំណេញពីការលក់-ទិញដីធ្លី កាលពី ២-៣ឆ្នាំកន្លងទៅ នៅមុនការបោះឆ្នោតជាតិ ។ ជាសំណាងល្អ ដោយមានការអនុញ្ញាតឱ្យប្រើប្រាស់ដីពីសំណាក់ម្ចាស់ដីថ្មីនោះ ប្រជាជនភូមិជាច្រើនបានយកប្រាក់ខ្លះៗ ទៅវិនិយោគក្នុងការដាំស្រូវដើម្បីចិញ្ចឹមជីវិត ។ អង្កេតគ្រួសារ បានឱ្យដឹងថា គិតជាមធ្យមភាគលើភូមិទាំងអស់ មានគ្រួសារអ្នកគ្មានដីធ្លីប្រហែល ១៥% ឬ រហូតដល់ ៥០% ក្នុងភូមិខ្សាច់ជីរស់ និង ៣៦% ក្នុងភូមិកញ្ជរដែលអាចជួលដីស្រែដើម្បីដាំស្រូវយកផលប្រើប្រាស់ក្នុងគ្រួសារ ។

### ***ផលិតកម្មសត្វចិញ្ចឹម***

ស្របពេលដែលតំរូវការ និងករិតថ្លៃសត្វចិញ្ចឹមកំពុងកើនលើង ប្រជាជនក្នុងភូមិសិក្សាទាំង៩ ក៏បានប្រឹងប្រែងបង្កើនសកម្មភាពចិញ្ចឹមមាន់ទា និងជ្រូក សំរាប់ទុកលក់ដែរ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០៥ មក មានតែប្រជាជនអ្នកមានដើមទុនគ្រប់គ្រាន់មួយចំនួនតូចប៉ុណ្ណោះ ដែលអាចមានលទ្ធភាពដោះស្រាយចំណាយលើការចិញ្ចឹមសត្វសំរាប់លក់បែបនេះ ។ ផលិតកម្មចិញ្ចឹមសត្វសំរាប់លក់នៅក្នុងភូមិសិក្សាទាំងនេះ ត្រូវប្រឈមនឹងការប្រកួតប្រជែងយ៉ាងខ្លាំង អំពីការនាំចូលសត្វចិញ្ចឹមពីប្រទេសជិតខាង ។ ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វនៅតែរាយការណ៍ថា បានទទួលផលចំនេញតែតិចតួចពីអាជីវកម្មនេះ ហើយពួកគេបានចាត់ទុកការចិញ្ចឹមសត្វនេះ ជាមធ្យោបាយសន្សំទ្រព្យធនរបស់ពួកគេ ។ ទោះការចិញ្ចឹមជ្រូកសំរាប់យកកូន ធ្លាប់ផ្តល់ប្រាក់ចំណូលល្អប្រសើរ ដល់ម្ចាស់អាជីវកម្មនៅកំឡុងឆ្នាំ ២០០៥ និង២០០៧ ក្តី ក៏មានប្រជាជនជាច្រើននៅភូមិកំពង់ត្នោត បានសំរេចចិត្តឈប់ធ្វើអាជីវកម្មនេះ ព្រោះពួកគេមិនមានលទ្ធភាពដោះស្រាយការឡើងថ្លៃធាតុចូល ក្នុងកំឡុងពេលមានការឡើងថ្លៃម្ហូបអាហារយ៉ាងខ្លាំងនៅឆ្នាំ២០០៨ ។ សរុបមក ក្នុងរយៈពេល ៣ឆ្នាំកន្លងទៅនេះ ផលិតកម្មសត្វចិញ្ចឹមមិនមានការផ្លាស់ប្តូរខ្លាំងក្លាប៉ុន្មានទេ សូម្បីតែក្នុងពេលដែលទំនិញកសិកម្មមានថ្លៃខ្ពស់ខ្លាំងក៏ដោយ ។ ក្រៅពីមិនអាចប្រកួតប្រជែងជាមួយផលិតផលដែលមានតំលៃថោកមកពីប្រទេសជិតខាងនោះ ការចិញ្ចឹមសត្វសំរាប់លក់ក៏នៅជួបបញ្ហាបន្តប្រើប្រាស់មធ្យោបាយចិញ្ចឹមសត្វបែបបុរាណ ដែលមានហានិភ័យខ្ពស់នៃការងាប់សត្វ ដោយសារកង្វះចំណេះដឹងអំពីវិធីគ្រប់គ្រងការពារជំងឺសត្វ ។ដូច្នេះមានអ្នកចិញ្ចឹមជ្រូកតិចនាក់ណាស់ដែលអាចរកចំណូលបានច្រើនពីការលក់ជ្រូកបានថ្លៃខ្ពស់ ។

### *ផលវិបាកនៃការឡើងថ្លៃធាតុចូលកសិកម្ម នៅលើគ្រួសារគ្មានដីធ្លីនៅក្នុងភូមិសិក្សាទាំង ៩*

កសិករតូចតាច នៅតែទទួលបានផលប្រយោជន៍តិចតួចណាស់ពីការធ្វើកសិកម្មរបស់ខ្លួន ។ ជាមួយនឹងការឡើងថ្លៃធាតុចូលកសិកម្មនាពេលថ្មីៗនេះ ផលិតភាពនៃដីធ្លីរបស់ម្ចាស់ដីតូចតាច (តិចជាង 0,៥ហិកតា) អាចថយចុះថែមទៀត (តារាង ៤.២) ។ ដោយសារអវត្តមានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដ៏សក្តិសិទ្ធិ កសិករតូចតាចតែងគិតថា ការបន្តរក្សាដីកម្មសិទ្ធិដ៏តូចនេះផ្តល់ផលចំនេញតិចតួចពេក ហើយនៅទីបំផុតក៏សំរេចចិត្តលក់ដីនោះទៅ ។ ហេតុនេះ ចំនួនគ្រួសារអ្នកគ្មានដីធ្លី បានកើនឡើងយ៉ាងឆាប់រហ័ស ក្នុងចន្លោះឆ្នាំ ២00៥ និង ២00៨ (តារាង ៤.៣) ។ តាមមើលទៅការកេងយកចំនេញពីការលក់-ទិញដីធ្លីនាពេលថ្មីៗ និងថ្លៃទំនិញដ៏ខ្ពស់ ទំនងជាមូលហេតុដែលសំខាន់ជាង ហេតុផលនៃផលចំណេញតិចតួចនៃការបន្តរក្សាទុកដីកម្មសិទ្ធិ ដែលយើងទទួលបានពីការពិភាក្សាតាមក្រុមស្នូល ។ កំណើនយ៉ាងរហ័សនៃចំនួនគ្រួសារគ្មានដីធ្លី បង្ហាញពីការអនុវត្តមិនបានសក្តិសិទ្ធិល្អនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល ព្រមទាំងកំណែទំរង់ដីធ្លី ដែលសំដៅជួយទ្រទ្រង់ដល់កសិករតូចតាច ។ ភាគរយនៃគ្រួសារដែលសំរេចចិត្តលក់ដីដ៏តូចរបស់ខ្លួន មានកំរិតខ្ពស់នៅភូមិត្រពាំងប្រីយ (៥២%) ភូមិព្រែកក្មេង (៤៦%) និងភូមិដងក្តារ (២៤%) ។

**តារាង ៤.៣: ភាគរយគ្រួសារគ្មានដីធ្លីនៅឆ្នាំ២00៥ និង ២00៨ និងភាគរយគ្រួសារមិនធ្វើស្រែចំការ នៅឆ្នាំដាំដុះ ២00៧_0៨**

| ភូមិ | ២00៥ | ២00៨ | %បំលាស់ប្តូរ ២00៥-0៨ | គ្រួសារមិនធ្វើស្រែចំការ |
|---|---|---|---|---|
| ក្រសាំង | 37 | 41 | 3 | 33 |
| អណ្តូងត្រាច | 39 | 70 | 31 | 41 |
| ត្រពាំងប្រីយ | 10 | 57 | 47 | 17 |
| ខ្សាច់ជីរស់ | 4 | 16 | 12 | 40 |
| ដងក្តារ | 3 | 66 | 63 | 27 |
| កំពង់ត្នោត | 7 | 50 | 43 | 10 |
| ព្រែកក្មេង | 30 | 72 | 42 | 80 |
| កញ្ជរ | 20 | 65 | 45 | 64 |
| បាបោង | 8 | 12 | 5 | 94 |
| សរុប | 17 | 49 | 32 | 50 |

តាមសំដីអ្នកឆ្លើយសំភាសន៍ មូលហេតុញឹកញាប់នៃការលក់ដីស្រែ គឺការបង្កើតមុខរបរថ្មី និងការយកប្រាក់ទិញស្បៀងអាហារ ដែលមានកំរិត ៣៨% ដូចគ្នា ។ ធាតុចូលកសិកម្ម ដូចជា ជី ថ្នាំសំលាប់សត្វល្អិត និងប្រេងឥន្ទនៈឡើងថ្លៃមួយជាពីរ ធៀបកាលពី២-៣ឆ្នាំកន្លងទៅ ។ ការឡើងថ្លៃនេះ ដែលបានបង្កើនចំណាយផលិតកម្ម ព្រមទាំងកង្វះលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មមានគុណភាពល្អ និងទាន់ពេល ជាឧបសគ្គចំបងដែលកាត់បន្ថយលទ្ធភាពរបស់កសិករក្នុងការបង្កើន និងធ្វើចំរុះកម្មនូវសកម្មភាពកសិកម្មរបស់ខ្លួន ។ ដោយសារខ្វះខាតដីកសិកម្មផង ការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬឆ្លងកាត់ព្រំដែន បានកើនឡើងនៅក្នុងភូមិទាំងនោះ ។ កង្វះលទ្ធភាពដោះស្រាយការឡើងថ្លៃធាតុចូលកសិកម្ម និងការសំរេចចិត្តលក់ដីធ្លី ទំនងមានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំង ។ កសិករតូចតាចមានសង្ឃឹមតិចតួចណាស់ នឹងទទួលបានផលចំណេញច្រើនពីការធ្វើកសិកម្ម ទោះបីអង្ករបានឡើងថ្លៃមួយជាពីរ ហើយផលិតផល

កសិកម្មឯទៀតក៏មានថ្លៃល្អក្តី ។ ពួកគេទទួលបានផលចំនេញតិចតួច ឬមិនបានផលចំនេញអ្វីសោះ ពីការងារសិកម្មរបស់ខ្លួន ដូច្នេះហើយក៏មានប្រាក់សន្សំតិចតួចណាស់សំរាប់រដូវដាំដុះលើកក្រោយ ។ កសិករតូចតាចជារឿយៗទៅខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុតូចតាច ឬសាច់ញាតិរបស់គេ ដើម្បីធ្វើស្រែចំការ ហើយប្រាក់កំចីនេះបានបង្កើនចំណាយផលិតកម្មថែមទៀត ។ ដោយសារកង្វះព័តិមានទីផ្សារ កសិករមានជំរើសតិចតួចលើមុខដំណាំត្រូវដាំដុះ និងមានកំលាំងខ្សោយក្នុងការតថ្លៃជាមួយឈ្មួញដើម្បីទទួលបានថ្លៃល្អសំរាប់ផលិតផល ។ កន្លងមក បញ្ហានេះជាមូលហេតុចំបងនៃការសំរេចចិត្តលក់ដីធ្លីនៅក្នុងភូមិដែលបានសិក្សា ។ទោះយ៉ាងនេះក្តី ការសិក្សាពីឱណាមិកនៃភាពក្រីក្រ បានសំណូមពរយ៉ាងខ្លាំងក្លាឱ្យមានការប្តេជ្ញាចិត្ត និងកិច្ចប្រឹងប្រែងកាន់តែខ្លាំង ជួយទ្រទ្រង់ឱ្យកសិករតូចតាចអាចជំនះបញ្ហាប្រឈមនានា ដើម្បីឱ្យពួកគេអាចស្ថិតនៅក្នុងក្រុមអ្នកផលិត និងមានស្ថានភាពកាន់តែប្រសើរដើម្បីចាប់យកផលប្រយោជន៍ពីផលិតកម្មរបស់ខ្លួន ព្រមទាំងអាចទប់ទល់បានកាន់តែប្រសើរដល់ការប្រែប្រួលខុសធម្មតាផ្សេងៗក្នុងប្រទេស តំបន់ និងសាកលលោក ។

## ៦. ជំនួយពីខាងក្រៅមានតិចតួច សំរាប់ដោះស្រាយការឡើងថ្លៃទំនិញ

នៅតាមភូមិសិក្សា មានគ្រួសារជាច្រើនបានទទួលសេវាជាមូលដ្ឋានមួយចំនួន ក្នុងចន្លោះពេលពីខែមីនា ២០០៥ ដល់ មីនា/មេសា ២០០៨ ។ សេវាកម្មទាំងនេះភាគច្រើនជាជំនួយសំរាប់អភិវឌ្ឍន៍ ជាជាងការឆ្លើយតបនឹងវិបត្តិទំនិញឡើងថ្លៃ ។ ទោះជាណា នៅចុងឆ្នាំ២០០៧ និងដើមឆ្នាំ២០០៨ មានគ្រួសារឆ្លើយសំភាសន៍ចំនួន ១៧% បានទទួលជំនួយអង្ករនិង៣៦% បានទទួលជំនួយគ្រាប់ធញ្ញជាតិ/ប៊ីចេង/ស្ករ/ប្រេងឆា ដែលភាគច្រើនបានមកពីគណបក្សនយោបាយ ។ ចំពោះអង្ករគ្រួសារនីមួយៗទទួលបាន ៥០គីឡូក្រាម ដែលគ្រប់គ្រាន់សំរាប់ឱ្យគ្រួសារមានសមាជិក ៥នាក់ ប្រើប្រាស់ក្នុងរយៈពេល ១ខែ ។ យោងតាមការពិភាក្សាតាមក្រុមស្នូល ការបែងចែកអាហារគឺផ្តល់ឱ្យតែអ្នកណាដែលមានវត្តមាននៅពេលបែងចែកប៉ុណ្ណោះ ។ ជនក្រីក្រខ្លាំងជារឿយៗមិនបានទទួលជំនួយនេះទេ ពីព្រោះពួកគេជាកម្មករចល័ត ។ ទោះយ៉ាងណា ក្រុមជនក្រីក្របានឆ្លើយសម្ភាសន៍ប្រាប់ពីការត្រេកអរដែលពួកគេទទួលបានប័ណ្ណអាទិភាព ដើម្បីទទួលយកសេវាថែទាំសុខភាពដោយឥតគិតថ្លៃ នៅតាមមណ្ឌលសុខភាពឃុំ ឬមន្ទីរពេទ្យ ចាប់តាំងពីដើមឆ្នាំ២០០៨ មក ។ គួបផ្សំនឹងការចាក់ថ្នាំបង្ការដល់កុមារ និងមាតា នៅមណ្ឌលសុខភាពក្នុងសហគមន៍ ជនក្រីក្រមានពេលវេលាច្រើនជាងមុនក្នុងការរកប្រាក់ចិញ្ចឹមជីវិត ។ រឿងនេះបានជួយដល់ពួកគេច្រើនណាស់ ជាពិសេសនៅពេលដែលអាហារឡើងថ្លៃ ពីព្រោះពួកគេត្រូវរឹតតែយ៉ាប់យ៉ឺនខ្លាំងទៀតបើសិនជាពួកគេមានជំងឺ ។ ជារឿយៗសេវាទាំងនេះ មានបង់ប្រាក់ខ្លះក៏ពិតមែន ប៉ុន្តែវាក៏មានតំលៃថោកបន្តិចដែរនៅពេលពួកគេបង្ហាញប័ណ្ណអាទិភាពសុខភាព ។ ប្រជាជនជាង ៨៥% បានពេញចិត្តចំពោះការកែលំអផ្លូវថ្នល់នៅក្នុងភូមិ និងនៅក្នុងតំបន់ជិតខាងដែលជួយសំរួលឱ្យធ្វើដំណើរ និងដឹកជញ្ជូនទំនិញបានលឿនជាងមុន ។ ទាក់ទិននឹងបញ្ហានេះ ក្រុមនារីនៅភូមិកញ្ជរ (ភូមិពឹងផ្អែកលើព្រៃឈើ) បានឆ្លើយសំភាសន៍ថា *"ប្រាក់ចំណូលរបស់ពួកយើងអាចបានប្រសើរជាងមុន ហើយយើងអាចជួបនឹងអសន្តិសុខស្បៀង ប្រសិនបើផ្លូវថ្នល់ស្ថានភាពអាក្រក់ដូចកាលពីដើមទសវត្សរ៍១៩៩០ ។ យ៉ាងហោចណាស់ ឥឡូវនេះ យើងអាចធ្វើដំណើរបានរហ័សជាងមុនទៅកាន់តំបន់ដែលយើងអាចរកប្រាក់កំរៃបាន ឬទៅទិញអាហារ ពីព្រោះថ្លៃអាហារនៅទីនេះ ខ្ពស់ខ្លាំងណាស់សំរាប់ពួកយើង ។ ពួកយើងប្រហែលត្រូវស្លាប់ ប្រសិនបើយើងរង់ចាំឱ្យព្រះចុះមកជួយ ឬរង់ចាំពួកអ្នកដែលចុះមកចែកអង្ករ ។យើងអរគុណណាស់ បើរដ្ឋាភិបាលអនុញ្ញាតឱ្យពួកយើងប្រើប្រាស់ដីព្រៃ ឬដីបុព្វបុរស ដើម្បីដាំដុះដំឡូងឈើ ឬសណ្តែកសៀង "* ។

## ៧. សេចក្ដីសន្និដ្ឋាន

ទំនិញជាអាហារ និងមិនមែនអាហារនៅឆ្នាំ២០០៨ ឡើងថ្លៃខ្ពស់ជាខ្លាំងជាងកាលពី ២-៣ឆ្នាំកន្លងទៅ ។ អតិផរណាសរុបនៅតំបន់ជនបទ មានកំរិតខ្ពស់ជាងនៅតំបន់ទីក្រុង ។ ការឡើងថ្លៃម្ហូបអាហារ និងទំនិញសំរាប់ផលិត បានប៉ះពាល់ប្រជាជនក្រីក្រខ្លាំងជាងគេ ។ ដើម្បីទប់ទល់បញ្ហានេះ អ្នកក្របានកាត់បន្ថយគុណភាព និងបរិមាណអាហារ និងទំនិញមិនមែនអាហារ ដែលពួកគេប្រើប្រាស់ជាធម្មតា ។ ផលប៉ះពាល់កាន់តែអាក្រក់ជាងនេះទៀត គឺប្រជាជនដែលក្រីក្រស្រាប់ ត្រូវធ្លាក់ខ្លួនក្រកាំតែខ្លាំថថែមទៀត ។ ផលវិបាកមួយទៀតនៃការឡើងថ្លៃកន្លងមក គឺការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនគ្រួសារគ្មានដីធ្លី ។

ប្រហែលពាក់កណ្ដាលនៃគ្រួសាររស់នៅក្នុងភូមិដែលបានសិក្សាទាំង៩ គឺជាអ្នកទិញអង្ករចូល និងទិញអាហារចាំបាច់ផ្សេងៗទៀត ។ នៅតំបន់ជនបទ មានតែប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលអាចរកចំណូលបានប្រសើរពីការឡើងថ្លៃម្ហូបអាហារ គឺមានម្ចាស់ដីធំៗ អ្នកជំនួញ អ្នកដាំដំណាំលក់យកប្រាក់ និងអ្នកធ្វើស្រូវប្រាំង ។ តំរូវការកំលាំងពលកម្មក៏កើនឡើងដែរ ប៉ុន្តែការងារដែលអាចរកបានមានលក្ខណៈរដូវកាល និងមិនឋិតថេរទៀងទាត់ទេ ។ ការឡើងថ្លៃផលិតផលកសិកម្ម ច្រើនតែមានរយៈពេលខ្លី បើធៀបនឹងរយៈពេលដែលវាចុះថ្លៃ ។ កង្វះលទ្ធភាពក្នុងការចាប់យកឱកាសដើម្បីបង្កើនប្រភពចំណូល បានដាក់សំពាធកាន់តែធ្ងន់ ធនធានទ្រព្យរួម ដូចជា ការប្រមូលផលហួសកំរិតពីព្រៃឈើនៅតាមភូមិពឹងផ្អែកលើព្រៃឈើ និងការហិនហោចស្តុកត្រីហួសពីកំរិតដែលវាអាចពងកូនកើនចំនួនឡើងវិញបាន ។

ទោះបីមានកិច្ចប្រឹងប្រែងច្រើនណាស់ជួយឱ្យជនក្រីក្រមានសន្តិសុខស្បៀងប្រសើរឡើង ក្នុងពេលដែលម្ហូបអាហារកំពុងឡើងថ្លៃនេះក្តី ក៏អន្តរាគមន៍ទាំងនេះមិនបានជួយឱ្យដល់ជនក្រីក្រនៅក្នុងភូមិដែលបានសិក្សាទាំង៩ នោះទេ ។ អន្តរាគមន៍ដែលមានកន្លងមក ច្រើនតែជាការចែកអង្ករដើម្បីបំរើការងារនយោបាយក្នុងកំឡុងពេលឃោសនាបោះឆ្នោត ឬការចែកអង្ករនៅក្នុងមូលនិធិសមធម៌សុខភាព ។ ការកសាងសំណាញ់សុវត្ថិភាពសង្គមមានសារៈសំខាន់បំផុត ហើយវាកាន់តែទាន់ពេល និងមានប្រសិទ្ធភាពល្អ ប្រសិនបើវាអនុវត្តឡើងតាមរយៈអាជ្ញាធរមូលដ្ឋាន ឬក៏គេអាចកសាងសមត្ថភាពក្រុមប្រឹក្សាឃុំសង្កាត់ ឱ្យអនុវត្តគោលនយោបាយជាតិបានសំរេច ។

ត្រូវមានកិច្ចប្រឹងប្រែង និងការប្តេជ្ញាចិត្តខ្លាំងថែមទៀតពីសំណាក់រដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងវិស័យឯកជនដើម្បីជួយដល់កសិករតូចតាច ។ សម្បទានសង្គមកិច្ច និងការធានាឱ្យកសិករតូចតាចមានលទ្ធភាពប្រើប្រាស់ដីធ្លី និងទ្រព្យផលិតកម្ម គឺជាកត្តាចាំបាច់ ប្រសិនបើគេចង់លុបបំបាត់នូវកំហិតខាងផលិតកម្មមួយចំនួនរបស់កសិករតូចតាច ។ ការសិក្សានេះក៏លើកជាអនុសាសន៍សុំឱ្យមានការកំណត់ព្រំប្រទល់ និងការចុះបញ្ជីដីធ្លី ឱ្យបានឆាប់រហ័សសំរាប់សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច នៅក្នុងតំបន់នានាដែលគេបានកែប្រែផ្ទៃដីអស់មួយភាគធំរួចទៅហើយ ។

## ជំពូក ៥
## វិបត្តិហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់នៅក្នុងតំបន់ និងនៅប្រទេសកម្ពុជា

*ដោយលោកបណ្ឌិត Jayant Menon ជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI*

### ១. សេចក្តីផ្តើម

ពិភពលោកកំពុងស្ថិតនៅក្នុងវិបត្តិហិរញ្ញវត្ថុដ៏ធំដែលមិនធ្លាប់មានពីមុនមក ។ ស្ទើរតែរៀងរាល់ថ្ងៃ សារព័ត៌មានជួយដាស់អារម្មណ៍ថា វិបត្តិនេះធ្ងន់ធ្ងរបំផុតនៅក្រោយការធ្លាក់ចុះសេដ្ឋកិច្ចដ៏ធំ (Great Depression) ហើយមានអ្នកខ្លះព្យាករណ៍ថា វានឹងធ្ងន់ធ្ងរជាងនេះទៀតក្នុងពេលដ៏ខ្លីខាងមុខ ។ យើងបានឃើញរួចហើយនូវការដួលរលំ ឬស្ទើរតែដួលរលំនៃស្ថាប័នហិរញ្ញវត្ថុធំៗមួយចំនួន ការចុះខ្សោយប្រព័ន្ធហិរញ្ញវត្ថុដោយសារកំណើនការខាតបង់នៃទ្រព្យសកម្មមានបញ្ហាកំណើនភាពមិនប្រាកដប្រជាទាក់ទងនឹងវត្ថុមានមូលនិធិ និងចំណាយលើមូលនិធិ ព្រមទាំងការខូចគុណភាពកាន់តែខ្លាំងនៃសំណុំទ្រព្យសកម្មជាកម្ចី (IMF 2009b) ។ វិបត្តិនេះមិនត្រឹមតែផ្ទុះឡើងនៅសហរដ្ឋអាមេរិកប៉ុណ្ណោះទេ ប៉ុន្តែវាមានឫសគល់ផ្សារភ្ជាប់ទៅនឹងសេចក្តីសំរេចចិត្តរបស់ភ្នាក់ងារនានានៅអាមេរិក ដែលជាប់ទាក់ទិននឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ។ តើវិបត្តិនេះបានកើតឡើងយ៉ាងដូចម្តេច?

វិបត្តិបានចាប់ផ្តើមនៅក្នុងទីផ្សារកម្ចីលេខពីរ (កម្ចីមានអ៊ីប៉ូតែក) នៅសហរដ្ឋអាមេរិក[១] ។ កង្វះបទប្បញ្ញត្តិ និងការត្រួតពិនិត្យពីគោលការណ៍ប្រុងប្រយ័ត្នលើកម្ចីអ៊ីប៉ូតែក បានបង្កតិរិយាបថប្រថុយហានិភ័យកំរិតខ្ពស់ ដែលនាំឱ្យកើតមានកម្ចីខូចគុណភាពជាច្រើន ។ នៅពេលកំសួលរីកដុះដាលវិស័យអចលនទ្រព្យនៅ សហរដ្ឋអាមេរិកត្រូវបាក់ស្រុត ការបញ្ចុះតំលៃទ្រព្យធ្វើអ៊ីប៉ូតែកយ៉ាងលឿន បានបណ្តាលឱ្យមានការកត់ត្រា បញ្ចុះតំលៃច្រើនៗនូវទ្រព្យសកម្មក្នុងតារាងតុល្យការរបស់ស្ថាប័នហិរញ្ញវត្ថុ ហើយមូលដ្ឋានមូលធននៃស្ថាប័នទាំងនេះ ក៏ត្រូវបាត់តំលៃស្ទើរតែមួយរំពេច ។ កំណើនលើទ្រព្យខូច ឬទ្រព្យមិនអាចប្តូរជាប្រាក់បាន មុនដំបូងប៉ះពាល់ដល់មូលនិធិកម្ចីវិនិយោគ ហើយការដួលរលំនៃមូលនិធិ Bear Stearns ទាំងពីរនៅខែមិថុនា ២០០៧ គឺជាការចាប់ផ្តើមរឿងកំសត់នៃកម្ចីលេខពីរ ។ វិបត្តិនេះ បានវិវត្តអាក្រក់ខ្លាំងមួយជាន់ទៀតកាលពីខែកញ្ញា ២០០៨ នៅពេលដែលក្រុមហ៊ុន Lehman Brothers បានពាក្យសុំប្រកាសក្ស័យធន ធនាគារអាមេរិក (Bank of America) បានទិញយកក្រុមហ៊ុន Merrill Lynch ហើយក្រុមហ៊ុន American International Group (AIG) បានទទួលកញ្ចប់ថវិកាសង្គ្រោះពីធនាគារកណ្តាលសហរដ្ឋអាមេរិកតែក្នុងប៉ុន្មានថ្ងៃបន្តបន្ទាប់គ្នា ។ ស្ថាប័នហិរញ្ញវត្ថុធំៗមួយចំនួនត្រូវអស់ទុនបង្វិល ហើយការផ្តល់ទុនសង្គ្រោះ បាននាំឱ្យមានការផ្លាស់ប្តូរ

---

១ កំចីគុណភាពលេខពីរ (subprime lending) ជាឥណទានដែលស្ថាប័នហិរញ្ញវត្ថុផ្តល់ទៅឱ្យអ្នកខ្ចីដែលមិនបំពេញបានតាមសេចក្តីណែនាំលើការធានាគុណភាពលេខមួយ (prime underwriting guidelines) ។ គេសម្គាល់អ្នកខ្ចីគុណភាពលេខពីរថា មានហានិភ័យមិនសងប្រាក់កំរិតខ្ពស់ជាង ដូចជា អ្នកធ្លាប់មានប្រវត្តិល្មើសច្បាប់កំចី ធ្លាប់មិនសងប្រាក់ ធ្លាប់មានធនក្ស័យ ឬមានបទពិសោធន៍តិចក្នុងការគ្រប់គ្រងប្រាក់ជំពាក់គេ ។ ពុំមាននិយមន័យស្តង់ដារទេ ប៉ុន្តែ កំចីគុណភាពលេខពីររបស់អាមេរិក (US subprime loan) តាមធម្មតាសំដៅដល់កំចីផ្តល់ឱ្យអ្នកដែលមានពិន្ទុ FICO (Fair Isaac Corporation) ទាបជាង ៦៨០ ។

យ៉ាងខ្លាំង ក្នុងប្រព័ន្ធហិរញ្ញវត្ថុសាកល ដែលជំរុញឱ្យមានអន្តរាគមន៍ខាងគោលនយោបាយមិនធ្លាប់មានពីមុន ដើម្បីបញ្ឈប់ចលាចលដែលកំពុងរីករាលដាល ។ មកដល់ពេលនេះ ប្រព័ន្ធធនាគារធំៗនៅទូទាំងពិភពលោក បានកត់ត្រាបញ្ចុះតំលៃកម្ចីលេខពីរដែលជួបការខាតបង់នេះ អស់ជិតដល់ប្រហែលមួយលានលានដុល្លារ (a trillion US dollars) តាំងពីខែកក្កដា ២០០៧ មក ។ ការខូចខាតដល់ចំណាត់ថ្នាក់គុណភាពឥណទានអ៊ីប៉ូតែកលេខពីរ បានរាលដាលយ៉ាងលឿនដល់ទ្រព្យច្រើនប្រភេទទៀតដែលកាន់កាប់ដោយក្រុមអ្នកវិនិយោគផ្សេងៗ នៅទូទាំងសាកលលោក ។ បច្ចុប្បន្ននេះ ផលអាក្រក់បានរីករាលដាលយ៉ាងលឿន និងគ្រប់ទិសទី ហើយរឿងវិបត្តិនេះ*ផុសឡើងពីទីណាមក* វាហាក់ដូចលែងសួរសំខាន់ហើយ ប៉ុន្តែ*រឿងហេតុអ្វី* វាផុសឡើង គឺជាមេរៀនយ៉ាងសំខាន់សំរាប់យើងទាំងអស់គ្នា ដើម្បីជៀសវាងកុំឱ្យវាកើតម្តងទៀត ។ សព្វថ្ងៃប្រទេសឧស្សាហកម្មធំៗ កំពុងធ្លាក់ចុះសេដ្ឋកិច្ច ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF 2009a) បានគន់គូរថា ផសស សំរាប់បណ្តាប្រទេសអភិវឌ្ឍន៍ នឹងមានអត្រាកំណើន -០,៣% នៅឆ្នាំ២០០៩ ធៀបនឹងកំណើនប៉ាន់ស្មាន ១,៤% នៅឆ្នាំ២០០៨ ។ ក្នុងសម័យក្រោយសង្គ្រាមលោកលើកទីពីរ ព្រឹត្តិការណ៍នេះអាចជាការរួមចុះសេដ្ឋកិច្ចប្រចាំឆ្នាំលើកទីមួយ សំរាប់បណ្តាប្រទេសអភិវឌ្ឍន៍ ហើយក៏ជា លើកទីមួយដែលយើងទាំងអស់គ្នាបានឃើញ មហាអំណាចសេដ្ឋកិច្ចទាំង៣ (G3) គឺសហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន ត្រូវរួមចុះសេដ្ឋកិច្ចព្រមៗគ្នាដែរ ។ វិបត្តិហិរញ្ញវត្ថុដែលកំពុងបន្តទៅមុខ បានពង្រីកឥទ្ធិពលរបស់វាទៅលើទីផ្សាររូបិយវត្ថុ និងឥណទានសាកល ព្រមទាំងបានរាំងស្ទះឥណទានសំរាប់វិស័យឯកជនទៀតផង ។ ដោយសារការធ្លាក់ចុះវិស័យហិរញ្ញវត្ថុនៅតែបន្ត ឥទ្ធិពលជាបន្តបន្ទាប់ទៅលើគ្រួសារដែលកំពុងខ្វះខាតសាច់ប្រាក់ និងលើសេដ្ឋកិច្ចជាទូទៅ នឹងកើនឡើងគួរកត់សំគាល់ ។ ថ្វីបើវិធានការដែលអាជ្ញាធរទូទាំងសាកលលោក បានចាត់ចេញមកទល់ពេលនេះ គួរអាចជួយសំរាលក៏វិតធ្ងន់ធ្ងរ និងរយៈពេលនៃវិបត្តិនេះបាន ប៉ុន្តែការខូចខាតចំពោះលក្ខខណ្ឌឥណទានជាសាកលគឺ ធំធេងណាស់ ហើយការរើបសេដ្ឋកិច្ចឡើងវិញ ត្រូវការពេលវេលាច្រើន និងមិនអាចមើលឃើញលទ្ធផលច្បាស់ទេ ។

**ក្រាហ្វិក ៥.១: ការលក់ផ្ទះ និងកំរិតថ្លៃ នៅសហរដ្ឋអាមេរិក**




*ប្រភព: CEIC*

ក្នុងអត្ថបទនេះ យើងព្យាយាមវាយតំលៃពីឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសាកល ដែលទំនងកើតមាននៅតំបន់អាស៊ាន+៣ និងប្រទេសពាក់ព័ន្ធខ្លះទៀត ដូចជា ជប៉ុន និងចិន ។ យើងក៏ពិចារណាទៅលើអនុក្រុម CLV (Cambodia, Lao, Vietnam) ដែលរួមមាន កម្ពុជា និងប្រទេសមានសេដ្ឋកិច្ចអន្តរកាលនៅជិតខាងគឺ ឡាវ និងវៀតណាម ព្រមទាំងប្រទេសឯទៀតនៅអនុក្រុមអាស៊ាន+៣ ដែលរួមមានប្រទេសឧស្សាហកម្មថ្មីៗ (NIEs) គឺកូរ៉េខាងត្បូង ហុងកុង និងសិង្ហបុរី ព្រមទាំងប្រទេសអាស៊ានមានចំណូលកំរិតមធ្យមចំនួន៤ ឬហៅថា អាស៊ាន៤ (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថៃ) ។ ផ្នែកបន្ទាប់ គឺជាការប្រមើលសំរាប់សហរដ្ឋអាមេរិក តំបន់អឺរ៉ូ ពាណិជ្ជកម្មពិភពលោក និងថ្លៃទំនិញប្រើប្រាស់ ។ ផ្នែកទី៣ ពិនិត្យពីផលប៉ះពាល់ដែលអាចកើតមានលើប្រទេសជប៉ុន និងចិន ។ ផ្នែកទី៤ ផ្តោតទៅលើក្រុមប្រទេសឧស្សាហកម្មថ្មី ហើយផ្នែកទី៥ ពិចារណាលើប្រទេសអាស៊ាន ៤ ។ ក្នុងផ្នែកទី៦ យើងពិនិត្យពីស្ថានភាពក្នុងប្រទេសដៃគូសេដ្ឋកិច្ចជាយុទ្ធសាស្ត្រទាំងពីររបស់កម្ពុជា គឺឡាវ និងវៀតណាម មុនផ្តោតទៅលើប្រទេសកម្ពុជានៅក្នុងផ្នែកទី៧ ។ ផ្នែកបញ្ចប់ គឺជាការបូកសរុប ។

## ២. បរិស្ថានខាងក្រៅ: សហរដ្ឋអាមេរិក តំបន់អឺរ៉ូ ពាណិជ្ជកម្មពិភពលោក និងថ្លៃទំនិញប្រើប្រាស់

ចក្ខុវិស័យសេដ្ឋកិច្ចសហរដ្ឋអាមេរិក ទំនងជាមានសភាពកាន់តែដុនដាបយោងតាមព័ត៌មាន ឬទិន្នន័យថ្មីៗ ដែលបានផ្សព្វផ្សាយ ហើយព័ត៌មានថ្មីបំផុត គឺអត្រាអត់ការងារដ៏ខ្ពស់ដែលមិនធ្លាប់ជួបប្រទះ ។ នៅត្រីមាសទី៣ សេដ្ឋកិច្ចសហរដ្ឋអាមេរិក បានរួមចុះពីត្រីមាសមួយទៅត្រីមាសមួយ តាមអត្រាប្រចាំឆ្នាំ ០,៣% ហើយគេរំពឹងថា នឹងបន្តធ្លាក់ចុះនៅត្រីមាសទីមួយក្នុងឆ្នាំនេះទៀត ។ តាំងពីខែមិថុនា ដល់ កញ្ញា ចំណាយប្រើប្រាស់របស់ឯកជន ធ្លាក់ចុះ ៣,១% ដោយសារអ្នកប្រើប្រាស់កាត់បន្ថយចំណាយ ក្នុងស្ថានភាពមានការបន្តធ្លាក់ចុះការលក់ទិញផ្ទះ កំណើនការបាត់បង់ការងារ និងកង្វះខាតឥណទានកាន់តែខ្លាំង ។ នៅខែមករា ២០០៩ IMF (2009a) មានព្យាករណ៍ឡើងវិញថា ផសស ឆ្នាំ២០០៩ នឹងរួមចុះ ១,៦% ធៀបនឹងការរួមចុះ ០,៧% ដែលបានព្យាករណ៍កាលពីខែវិច្ឆិកា ២០០៨ (IMF 2008b) ។ ទោះជាយ៉ាងណា គេរំពឹងថា ផសស នឹងមានកំណើន ១,៦% វិញនៅឆ្នាំ២០១០ ។ ផ្ទះដែលបន្តធ្លាក់ថ្លៃ ដោយសារមានផ្ទះសល់ច្រើន និងតំរូវការធ្លាក់ចុះ កំពុងតែជះឥទ្ធិពលយ៉ាងលឿនទៅក្នុងសកម្មភាពពាណិជ្ជកម្ម (ក្រាហ្វិក ៥.១) ។

យោងទៅតាមការិយាល័យស្ថិតិពលកម្ម អត្រាអត់ការងារធ្វើកើនដល់ ៦,៥% នៅខែតុលា ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈ ១៤ឆ្នាំចុងក្រោយ (ក្រាហ្វិក ៥.២) ហើយស្ថានភាពនេះកំពុងតែយ៉ាប់យឺនថែមទៀត ។ អត្រាអត់ការងារធ្វើ កើនដល់ ៦,៨% នៅខែវិច្ឆិកា ២០០៨ និង ៧,២% នៅខែធ្នូ ២០០៨ ។ ពីខែវិច្ឆិកា ដល់ ធ្នូ ចំនួនអ្នកគ្មានការងារធ្វើកើនពី ៦៣២.០០០នាក់ ដល់ ១១,១លាននាក់ ។ ក្នុងខែធ្នូតែមួយនេះ ចំនួនអ្នកធ្វើការ មានឈ្មោះក្នុងបញ្ជីបើកប្រាក់ បានធ្លាក់ចុះអស់ ៥២៤.០០០នាក់ និងធ្លាក់ចុះ ១,៩លាននាក់ក្នុងរយៈពេល៤ខែ នៅចុងឆ្នាំ២០០៨ ។ តាំងពីចាប់ផ្តើមមានវិបត្តិសេដ្ឋកិច្ចនៅខែធ្នូ ២០០៧ មក ចំនួនអ្នកអត់ការងារធ្វើ កើនដល់ ៣,៦លាននាក់ ហើយអត្រាអត់ការងារធ្វើ កើនលើសពីមុន ២,៣ តួលេខភាគរយថែមទៀត ។

**ក្រាហ្វិក ៥.២: បំរែបំរួលនៅក្នុងការងារមិនមែនកសិកម្ម (គិតជាពាន់ការងារ)**




*ប្រភព: ការគណនារបស់បុគ្គលិកនៃ OREI ផ្អែកតាមទិន្នន័យរបស់ការិយាល័យស្ថិតិការងារនៃក្រសួងការងារ US*

លើកនេះ ជាការធ្លាក់ចុះពិបាកស្តារមួយដែលរហូតមកដល់ពេលនេះ នៅរឹងកំព្រឹស ទោះបីមានគោលនយោបាយធំៗខាងហិរញ្ញវត្ថុ និងរូបិយវត្ថុ ដើម្បីជំរុញសេដ្ឋកិច្ចក្តី ។ សូចនាករសំខាន់ៗក៏បានបង្ហាញថា ការធ្លាក់ចុះនេះទំនងជាបន្តយូរពេល ទោះបីជាមានអន្តរាគមន៍ទាំងនេះក្តី ។ នៅក្នុងគោលនយោបាយរូបិយវត្ថុ ធនាគារកណ្តាលសហរដ្ឋអាមេរិក បានកាត់បន្ថយអត្រាការប្រាក់ (target policy rate) អស់ ៥០ចំនុចគោល (basis points) មកត្រឹម ១% នៅថ្ងៃទី២៩ តុលា និងអស់ ៧៥ចំនុចគោលទៀត មកត្រឹម ០,២៥% នៅថ្ងៃទី១៦ ធ្នូ ២០០៨ ។ ការកាត់បន្ថយចុងក្រោយនេះ គឺជាការកាត់បន្ថយជាបន្តបន្ទាប់លើកទី១០ តាំងពីខែកញ្ញា ២០០៧ មក ហើយវាក៏ជាអត្រាកំរិតទាបបំផុតក្នុងប្រវត្តិនៃគោលនយោបាយរូបិយវត្ថុបច្ចុប្បន្ន ។ ជាការពិតណាស់ ការកាត់បន្ថយអត្រាការប្រាក់នៅខែតុលាមិនអាចជំរុញឱ្យមានការផ្តល់កម្ចីស្របតាមបំណងរបស់អ្នកកសាងគោលនយោបាយ និងបទប្បញ្ញត្តិនោះទេ ។ ខាងផ្នែកហិរញ្ញវត្ថុ កញ្ចប់ជំនួយជំរុញសេដ្ឋកិច្ចលើកទីពីរមួយទៀត កំពុងយកមកពិនិត្យពិភាក្សាបន្ទាប់ពីការអនុម័តកញ្ចប់ជំនួយហិរញ្ញវត្ថុចំនួន ១៥០ពាន់លានដុល្លារ កាលពីខែកុម្ភៈ ២០០៨ ។ ជំនួយនេះ គឺផ្តល់បន្ថែមលើច្បាប់ផ្តល់ជំនួយសង្គ្រោះហិរញ្ញវត្ថុចំនួន ៧០០ពាន់លានដុល្លារ ដែលបានអនុម័តកាលពីខែកញ្ញា ២០០៨ ។ សកម្មភាពសេដ្ឋកិច្ចដែលធ្លាក់ល្បឿន បានជួយទប់សម្ពាធថ្លៃ ដោយបញ្ចុះអតិផរណាមកត្រឹម ៣,៧% នៅខែតុលា ២០០៨ ធៀបនឹងកំរិតខ្ពស់បំផុតកាលពីខែមិថុនា រហូតដល់ ៥,៦% ។

តំបន់អឺរ៉ូ ក៏ត្រូវធ្លាក់ចុះសេដ្ឋកិច្ចដែរ បន្ទាប់ពីស្ថាប័នហិរញ្ញវត្ថុជាច្រើន បានរងគ្រោះដោយផ្ទាល់ពីវិបត្តិហិរញ្ញវត្ថុ ផលិតកម្មឧស្សាហកម្មធ្លាក់ចុះ និងការលក់រាយថយចុះ ។ ប្រព័ន្ធហិរញ្ញវត្ថុត្រូវរង្គោះរង្គើយ៉ាងច្បាស់ បន្ទាប់ពីមានវិបត្តិធ្ងន់ធ្ងរតាំងពីពាក់កណ្តាលខែកញ្ញាមក ពីព្រោះធនាគារអឺរ៉ុបជាច្រើនបានជួបនឹងស្ថានភាពមានតារាងតុល្យការ ត្រូវខូចខាតធ្ងន់ធ្ងរ ។ ប្រទេសបែលហ្ស៊ិក បារាំង អាឡឺម៉ង់ លុចសំបួ ហូឡង់ និងអង់គ្លេស បានចាត់វិធានការពិសេសៗបំផុតដើម្បីសង្គ្រោះប្រព័ន្ធធនាគារថ្នាក់ជាតិ ហើយប្រទេសដាណឺម៉ាក និងអៀរឡង់ បានប្រកាសនូវការធានាជាទូទៅដល់ប្រាក់បញ្ញើ និងបំណុល សំរាប់ប្រព័ន្ធធនាគារនៅប្រទេសគេ ។ ប៉ុន្តែ ដំណើរការកាត់បន្ថយការប្រើកំចីមានការប្រាក់

ថេរទៅរកសុី ដើម្បីបានចំណេញលើសពីការប្រាក់ (financial deleveraging) នៅតែបន្តជះឥទ្ធិពលទៅលើសេដ្ឋកិច្ច ដោយសារធនាគារកាត់បន្ថយការផ្តល់កម្ចី និងរឹតបណ្តឹងលក្ខខណ្ឌផ្តល់ឥណទាន ។ សកម្មភាពសេដ្ឋកិច្ចទំនងបន្តចុះខ្សោយ ដោយសារទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងអាជីវកម្ម បានធ្លាក់យ៉ាងខ្លាំង ។ IMF រំពឹងថា នៅឆ្នាំ២០០៩ តំបន់អឺរ៉ូ នឹងរួមចុះសេដ្ឋកិច្ចអស់ ២% ហើយរើបឡើងវិញបាន 0,២% នៅឆ្នាំ២០១០ (IMF 2009a) ។

**ក្រាហ្វិក ៥.៣: សន្ទស្សន៍ថ្លៃផលិតផលសំខាន់ៗ (មករា ២០០៥ = ១០០)**




*ថាមពល : ប្រេងឆៅ ឧស្ម័នធម្មជាតិ ធ្យូងថ្ម*

*លោហ: : ទង់ដែង អាលុយមីញ៉ូម រ៉ែដែក សំណប៉ាហាំង នីកែល ស័ង្កសី សំណ អ៊ុយរ៉ាញ៉ូម*

*អាហារ និងភេសជ្ជៈ : ធញ្ញជាតិ ប្រេងរុក្ខជាតិ សាច់ ម្ហូបសមុទ្រ ស្ករ ចេក ក្រូច កាហ្វេ តែ កាកាវ*

*សំភារៈកសិកម្ម : ឈើអារ កប្បាស ឡៃន កៅស៊ូ ស្បែក*

*ប្រភព: ការគណនារបស់បុគ្គលិកនៃ OREI ផ្អែកតាមទិន្នន័យថ្លៃបំរើបំរាស់ដើមរបស់ IMF*

ដោយសារតំរូវការពីប្រទេសឧស្សាហកម្មធំៗថយចុះ កំណើនពាណិជ្ជកម្មពិភពលោកកំពុងធ្លាក់ចុះយ៉ាងខ្លាំង ហើយក៏កាត់បន្ថយដល់ផលិតកម្មសំរាប់នាំចេញនៃបណ្តាប្រទេសមានសេដ្ឋកិច្ចទីផ្សារដែលកំពុងផុសឡើង ។ ការធ្លាក់ចុះព្រមៗគ្នានៃប្រទេសមានសេដ្ឋកិច្ចជឿនលឿន បានគាបសង្កត់ទៅលើពាណិជ្ជកម្មពិភពលោក ។ ផលិតកម្មឧស្សាហកម្មសាកលបានធ្លាក់ចុះ ដោយសារកំណើនតំរូវការនាំចូលនៃប្រទេស G3 បានធ្លាក់ចុះយ៉ាងលឿន ។ កំណើនពាណិជ្ជកម្មពិភពលោកក៏ធ្លាក់ចុះ ហើយធនាគារពិភពលោកបានព្យាករណ៍ថា ក្នុងឆ្នាំ២០០៩ ទំហំពាណិជ្ជកម្មនឹងរួមចុះអស់ ២,៥% ធៀបនឹងកំណើនប៉ាន់ស្មាន ៥,៨% សំរាប់ឆ្នាំ២០០៨ ។

នៅចំពោះមុខគ្រោះថ្នាក់នៃវិបត្តិសេដ្ឋកិច្ចសាកល និងការឡើងថ្លៃប្រាក់ដុល្លារ ប្រេង និងផលិតផលផ្សេងៗទៀតនៅទីផ្សារអន្តរជាតិបានធ្លាក់ថ្លៃយ៉ាងខ្លាំង ដោយមានខ្លះធ្លាក់ចុះពីកំរិតថ្លៃដ៏ខ្ពស់មិនធ្លាប់ឃើញ ។ ប្រេងឆៅធ្លាក់ថ្លៃ មកក្រោម ៦០ដុល្លារ/ធុង ឬធ្លាក់ថ្លៃ ៦០% ធៀបនឹងកំរិតខ្ពស់បំផុតដល់ ១៥០ដុល្លារ/ធុង កាលពីពាក់កណ្តាលខែមិថុនា ២០០៨ ។ ទីផ្សារលក់ទំនិញអនាគត បានបង្ហាញថា ថ្លៃប្រេងឆៅ ទំនងនៅទាប ដោយអាចរើបឡើងដល់ ៧០ដុល្លារ/ធុង រហូតដល់ឆ្នាំ២០០៩ ឯណោះ រីឯផលិតផលមិនមែនប្រេង ក៏ធ្លាក់ថ្លៃខ្លាំងដែរ ដោយសារតំរូវការថយចុះ

(ក្រាហ្វិក ៥.៣) ។ ការថយចុះតម្រូវការនាំចូលរបស់ប្រទេសចិន គួបផ្សំនឹងលទ្ធភាពថយចុះតម្រូវការពិភពលោក វាបន្តសង្កត់ចុះថ្លៃកសិផលជាវត្ថុធាតុដើម និងលោហៈសំខាន់ៗ យ៉ាងហោចណាស់ក៏ក្នុងរយៈពេលខ្លីដែរ ។

## ៣. ប្រទេសជប៉ុន និងចិន

ដោយសារតម្រូវការអន្តរជាតិធ្លាក់ចុះ និងការប្រើប្រាស់ក្នុងស្រុកនៅស្ពឹក សេដ្ឋកិច្ចជប៉ុនបានធ្លាក់ចុះ ដោយ ផសស រំពឹងថានឹងរួមចុះ 0,២% ក្នុងឆ្នាំ២00៩ ។ សេដ្ឋកិច្ចជប៉ុនបានរួមចុះតាមអត្រាប្រចាំឆ្នាំកែតម្រូវតាមរដូវកាល 0,៤% នៅត្រីមាសទី៣ ឆ្នាំ២00៨ បន្ទាប់ពីការធ្លាក់ចុះ ៣,៧% នៅត្រីមាសមុន ។ គេរំពឹងថា ការនាំចេញនឹងបន្តធ្លាក់ចុះ ដោយសារការធ្លាក់ចុះជាសាកល ។ ការធ្លាក់ចុះប្រាក់ចំណេញរបស់សហគ្រាស និងប្រាក់ចំណូលគ្រួសារ បានធ្វើឱ្យធ្លាក់ចុះទំនុកចិត្តរបស់អាជីវកម្ម និងអ្នកប្រើប្រាស់ ដូច្នេះហើយតម្រូវការក្នុងស្រុក ទំនងជានៅខ្សោយបន្តទៀត ។ ការឡើងថ្លៃប្រាក់យ៉េនជប៉ុន និងការធ្លាក់ថ្លៃភាគហ៊ុនជប៉ុនដល់កំរិតទាបបំផុតក្នុងរយៈ ២៦ឆ្នាំចុងក្រោយ ក៏នាំឱ្យលទ្ធផលសេដ្ឋកិច្ចអាប់អួរដែរ ។

នៅថ្ងៃទី៣១ តុលា ធនាគារជាតិជប៉ុន បានបញ្ចុះអត្រាជាគោលនយោបាយមកត្រឹម 0,៣% បន្ទាប់ពីបានរក្សាអត្រានេះនៅថេរតាំងពីខែកុម្ភៈមក ហើយទង្វើនេះឆ្លុះបញ្ចាំងពីសកម្មភាពសេដ្ឋកិច្ចថយចុះ និងជំហរប្រុងប្រយ័ត្នចំពោះភាពមិនទៀងទាត់នៃទីផ្សារហិរញ្ញវត្ថុនាពេលថ្មីៗ ។ រដ្ឋាភិបាល បានផ្តល់កញ្ចប់ជំរុញសេដ្ឋកិច្ចមួយទៀតចំនួន ២៧លានលានយ៉េន (២៧៥,៧ពាន់លានដុល្លារ) ដែលមានទាំងការផ្តល់ឥណទានបន្ថែម សំរាប់ពាណិជ្ជកម្មធុនតូច និងការផ្តល់សាច់ប្រាក់សំរាប់គ្រួសារ ចំនួន ២លានលានយ៉េន (២0,៤ពាន់លានដុល្លារ) នៅខែតុលា បន្ទាប់ពីបានអនុម័តកញ្ចប់ជំរុញសេដ្ឋកិច្ច ១១,៧លានលាយ៉េន (១0៧,៤ពាន់លានដុល្លារ) កាលពីខែសីហា ។

បន្ទាប់ពីមានកំណើន ផសស លេខពីរខ្ទង់បាន ៥ឆ្នាំ សេដ្ឋកិច្ចចិន ក៏ថយកំណើនមកត្រឹមអត្រាកំណើនរំពឹងទុក ៩,0% នៅឆ្នាំ២00៨ និងត្រឹមតែ ៦,៧% នៅឆ្នាំ២00៩ (IMF 2009a) ដោយសារការចុះខ្សោយនៅក្រៅប្រទេសដែលបណ្តាលមកពីចលាចលក្នុងហិរញ្ញវត្ថុសាកល ។ តាមសេចក្តីប្រកាសរបស់រដ្ឋាភិបាល ប្រទេសចិនអាចកាន់តែពិបាកបើសិនគ្មានកម្មវិធីជំរុញសេដ្ឋកិច្ចទំហំ ៤0លានលានប្រាក់យ៉ុនចិន (4 trillion) ។ កំណើន ផសស បានថយចុះក្នុង ៥ត្រីមាសបន្តបន្ទាប់ មកត្រឹម ៩,0% នៅត្រីមាសទី៣ ឆ្នាំ២00៨ ដោយសារជាសំខាន់ វិធានការរឹតបន្តឹងដែលដាក់អនុវត្តពីឆ្នាំ២00៧ មកដល់ចុងខែមិថុនា ២00៨ ដើម្បីគ្រប់គ្រងអតិផរណា និងបន្ធូរសន្ទុះសេដ្ឋកិច្ចដែល ហាក់ដូចជាមានដំណើរការក្តៅគគុកពេក ។ តំហយការបញ្ជាទិញទំនិញនាំចេញ ការថយចុះតម្រូវការទុនវិនិយោគ និងការបិទរោងចក្រនៅអំឡុងពេលកម្មវិធីកីឡាអូឡាំពិកនារដូវក្តៅ គឺជាកត្តាគន្លឹះនៃការធ្លាក់ចុះ ។

បច្ចុប្បន្ននេះ គោលនយោបាយម៉ាក្រូ បានបង្វែរទិសដៅទៅជំរុញតម្រូវការក្នុងស្រុក ដើម្បីប៉ះប៉ូវការធ្លាក់ចុះដែលរំពឹងទុកសំរាប់ការនាំចេញ និងកំណើនវិនិយោគឯកជន ។ វិធានការខាងរូបិយវត្ថុដែលអនុម័តរួច រួមមានការកាត់បន្ថយអត្រាការប្រាក់ និងធនបំរុងតាមការតំរូវ ព្រមទាំងការលប់កូតាប្រាក់កម្ចីសំរាប់ធនាគារ ។ ក្រៅពីកម្មវិធីដ៏ធំខាងហិរញ្ញវត្ថុ (ដែលផ្តោតជាសំខាន់លើហេដ្ឋារចនាសម្ព័ន្ធ និងចំណាយសង្គម) រដ្ឋាភិបាលបានកាត់បន្ថយពន្ធ បង្កើនឧបត្ថម្ភធនសំរាប់កសិកម្ម និងបង្កើនល្បឿនចំណាយ ។

## ៤. ប្រទេសឧស្សាហកម្មថ្មី: កូរ៉េខាងត្បូង ហុងកុង និងសិង្ហបុរី

ដោយសារមានការពឹងផ្អែកខ្លាំងលើពាណិជ្ជកម្មប្រទេសឧស្សាហកម្មថ្មី (NIEs) ត្រូវប៉ះពាល់លឿនណាស់ ដោយសារការប្រែប្រួលនៃបរិយាកាសសេដ្ឋកិច្ចសាកល ។ គេព្យាករណ៍ថា ផសស របស់ក្រុមប្រទេសទាំងនេះ អាចរួមចុះ ៣,៩% ក្នុងឆ្នាំ២០០៩ ធៀបនឹងអត្រា២,១% ក្នុងឆ្នាំ២០០៨ដែលជាលទ្ធផលនៃការធ្លាក់ចុះការនាំចេញ(IMF 2009a) ។ ក្នុងប៉ុន្មានខែថ្មីៗនេះ ភាគហ៊ុនធ្លាក់ថ្លៃ និងប្រាក់វ៉ុនកូរ៉េធ្លាក់ថ្លៃ បានរាំងស្ទះដល់ការរីកលូតលាស់សេដ្ឋកិច្ចនៅកូរ៉េខាងត្បូង ។

អាជ្ញាធរ បានចាត់វិធានការជាច្រើន ដើម្បីកាត់បន្ថយសម្ពាធខាងហិរញ្ញវត្ថុ និងជំរុញតំរូវការ ប៉ុន្តែទទួលបានផលតិចតួចណាស់ ។ វិធានការដែលដាក់អនុវត្ត រួមមាន ការធានាលើកម្ចីពីបរទេសរបស់ធនាគារក្នុងស្រុកចំនួន ១០០ពាន់លានដុល្លារ និងកញ្ចប់ជំរុញវិស័យហិរញ្ញវត្ថុចំនួន ១១ពាន់លានដុល្លារ ។ សេដ្ឋកិច្ចហុងកុង បានរួមចុះម្តងទៀតនៅត្រីមាសទី៣ ហើយរំពឹងថា នឹងនៅតែទន់ខ្សោយក្នុងឆ្នាំនេះ ដោយសារហុងកុងមានចំណងទាក់ទងយ៉ាងច្រើនខាងពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយបណ្តាប្រទេសឧស្សាហកម្ម ។ សិង្ហបុរីដែលបានជួបវិបត្តិរួចជាស្រេច ក៏មានអនាគតមិនសូវភ្លឺស្វាងដែរ ដោយគេបានព្យាករណ៍ថា កំណើនមានត្រឹមតែ ២% នៅឆ្នាំ២០០៩ ធៀបនឹង ៣,០% ដែលបានរំពឹងទុកនៅឆ្នាំ២០០៨ ។ ដោយសារទីផ្សារឥណទានសាកល បានផ្អាកសកម្មភាពចាប់តាំងពីពាក់កណ្តាលខែកញ្ញា រូបិយវត្ថុភាគច្រើនក្នុងតំបន់ បានធ្លាក់ថ្លៃយ៉ាងខ្លាំងទល់នឹងប្រាក់ដុល្លារ ។ ប្រាក់វ៉ុនកូរ៉េ ធ្លាក់ថ្លៃខ្លាំងជាងគេ អស់ជាង ៣០% តាំងពីខែមិថុនា ២០០៨ មក ដោយសារកំណើនឱនភាពគណនីចរន្ត និងការដកចេញយ៉ាងលឿននៃវិនិយោគបរទេសលើភាគហ៊ុន ។

## ៥. អាស៊ាន ៤: ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថៃ

ប្រទេសសមាជិកអាស៊ានចំនួន ៤ ដែលមានប្រាក់ចំណូលកម្រិតមធ្យម គឺមានកំណើនខ្លាំងនៅឆមាសទីមួយឆ្នាំ២០០៨ ប៉ុន្តែកំណើននេះត្រូវធ្លាក់ចុះមក ២,៧% វិញនៅឆ្នាំ២០០៩ ដោយសារការធ្លាក់ចុះជាសាកល ក្នុងនោះម៉ាឡេស៊ី (៣,៥%) ធ្លាក់ចុះខ្លាំងជាងឥណ្ឌូនេស៊ី (៥%) ហ្វីលីពីន (៣,៥%) និងថៃ (៣,៥%) (IMF 2009a) ។ តំរូវការក្នុងស្រុក ទំនងជាធ្វើឱ្យប្រទេសអាស៊ាន ៤ រក្សាស្ថានភាពបានល្អ ទោះបីបរិយាកាសខាងក្រៅកំពុងធ្លាក់ចុះក្តី ។ អតិរេកគណនីចរន្តនៃប្រទេសអាស៊ាន ៤ គិតជាភាគរយនៃ ផសស ធ្លាក់ចុះដល់ ៤,០% នៅឆមាសទីមួយ ឆ្នាំ២០០៨ ធៀបនឹង ៥,៩% នៅឆ្នាំ២០០៧ ។ ទីផ្សារភាគហ៊ុននៅប្រទេសអាស៊ាន ៤ បន្តនិន្នាការធ្លាក់ចុះក្នុង ឆ្នាំ២០០៨ ដោយសារការខ្លាចហានិភ័យ និងការប្រមើលឃើញមិនល្អអំពីដំណើរការសេដ្ឋកិច្ចសាកល ។ ក្នុងចំណោមប្រទេសអាស៊ាន ៤ ប្រាក់រូពីយ៉ារបស់ឥណ្ឌូនេស៊ី ត្រូវវិបត្តិប៉ះពាល់ខ្លាំងជាងគេ ដោយបានធ្លាក់ថ្លៃ ២៥% បន្ទាប់មកគឺ ប្រាក់រីងជីតរបស់ម៉ាឡេស៊ី និងប្រាក់ប៉េសូរបស់ហ្វីលីពីន ដែលបានធ្លាក់ថ្លៃប្រហែល ១០% ប៉ុន្តែប្រាក់បាតថៃនៅរឹងប៉ឹងគួរឱ្យភ្ញាក់ផ្អើល ដោយធ្លាក់ថ្លៃតិចជាង ១០% ។

## ៦. តំបន់មូលដ្ឋាន: ប្រទេសឡាវ និងវៀតណាម

នៅក្នុងបរិយាកាសសាកលលោកដ៏លំបាកនេះ ឡាវ និងវៀតណាម ក៏ដូចជាប្រទេសឯទៀតទាំងអស់នៅក្នុងតំបន់ ត្រូវធ្លាក់ចុះសេដ្ឋកិច្ច ។ បន្ទាប់ពីកំណើនស្ទុះឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ គេព្យាករណ៍ថា កំណើន

ផសស នៅវៀតណាមនឹងថយចុះដល់ ៦,៣% នៅឆ្នាំ២០០៨ និង ៥% នៅឆ្នាំ២០០៩ ដោយសារការថយកំណើនសកម្មភាពឧស្សាហកម្ម និងវិនិយោគ ។ តំរូវការក្នុងស្រុកធ្លាក់ចុះ ហើយទំនងជាបន្តធ្លាក់ចុះថែមទៀតនៅឆ្នាំ២០០៩ ។ នៅចំពោះមុខស្ថានភាពនេះ រដ្ឋាភិបាលនាពេលថ្មីៗបានប្រកាសពីកញ្ចប់ជំរុញសេដ្ឋកិច្ចមានទឹកប្រាក់ ១ពាន់លាន ក្នុងនេះប្រហែលពាក់កណ្តាលត្រូវចំណាយទៅលើគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ហើយក៏បានលើកសំណើកាត់បន្ថយពន្ធផងដែរ ។ វិធានការខាងហិរញ្ញវត្ថុនេះ ហាក់ដូចមិនទាន់គ្រប់គ្រាន់ដើម្បីជួយឱ្យរដ្ឋាភិបាល សំរេចបានកំណើន ផសស តាមគោលដៅ ៦,៥% សំរាប់ឆ្នាំ២០០៩ នោះឡើយ ។

ក្នុងរយៈពេលចុងក្រោយនេះ សេដ្ឋកិច្ចឡាវបានទទួលប្រយោជន៍ពីកំណើនថ្លៃថាមពល និងវត្ថុធាតុដើម ។ ប៉ុន្តែជាមួយនឹងថ្លៃទំនិញធ្លាក់ចុះ កំណើនសេដ្ឋកិច្ចរំពឹងថានឹងថយចុះមកត្រឹម ៦,៥% នៅឆ្នាំ២០០៩ ធៀបនឹង ៧,៥% ដែលរំពឹងទុកនៅឆ្នាំ២០០៨ ។ ទោះបីលំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេស ១ធឌីប ទំនងត្រូវប៉ះពាល់ក្តី ប៉ុន្តែការធ្លាក់កំណើនជាបណ្តើរៗមិនគំហុក វាបង្ហាញថា ប្រទេសឡាវអាចឆ្លងផុតពីវិបត្តិសេដ្ឋកិច្ចនេះដោយគ្មានរងគ្រោះអ្វីច្រើនទេ ។ យោងតាមស្ថាប័នពហុភាគីភាគច្រើនដែលរំពឹងថា ប្រទេសឡាវមានអត្រាកំណើនប្រហែល ៦,៥% នៅឆ្នាំ២០០៩ ដូច្នេះឡាវទំនងជាប្រទេសមួយដែលនៅមានកំណើនសេដ្ឋកិច្ចលឿនបំផុតលើសាកលលោក ។

## ៧. សេដ្ឋកិច្ចមូលដ្ឋានៈ ប្រទេសកម្ពុជា

គេប៉ាន់ស្មានថា សេដ្ឋកិច្ចកម្ពុជានឹងកើនឡើង ៦,៥% ក្នុងឆ្នាំ២០០៨ ។ នេះជាការធ្លាក់ចុះយ៉ាងខ្លាំងធៀបនឹងកំណើន ១០,១% ដែលសំរេចបាននៅឆ្នាំ២០០៧ ក៏ដូចជាកំណើនលេខពីរខ្ទង់ដែលកម្ពុជាទទួលបានក្នុងរយៈពេលបីឆ្នាំមុននោះទៀត ។ គេរំពឹងថា នៅឆ្នាំ២០០៩ និងឆ្នាំ២០១០ កំណើននឹងបន្តធ្លាក់ចុះ ហើយទំហំនៃការធ្លាក់ចុះ វាអាស្រ័យជាចំបងទៅលើស្ថានភាពនៃតំរូវការក្នុងពិភពលោក ។ បន្ទាប់ពីការចេញផ្សាយ របាយការណ៍ចក្ខុវិស័យសេដ្ឋកិច្ចពិភពលោកនៅខែតុលា ២០០៨ ដែលមានចុះការព្យាករណ៍របស់ IMF សំរាប់សេដ្ឋកិច្ចពិភពលោក កំណើនដែលព្យាករណ៍សំរាប់សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០៨ ស្ថិតនៅចន្លោះពី ៦% (IMF 2008a) ទៅ ៦,៤% (EIU 2008a) ឬ ៧% (ADB 2008a) ។ បន្ទាប់មក ក្នុងខែវិច្ឆិកា ២០០៨ IMF បានចេញ ផ្សាយរបាយការណ៍ចក្ខុវិស័យសេដ្ឋកិច្ចពិភពលោកកែសំរួល ដោយបានបញ្ចុះអត្រាកំណើនដែលព្យាករណ៍សំរាប់សេដ្ឋកិច្ចពិភពលោក ។ ជាមួយគ្នានឹងការបញ្ចុះនេះ តួលេខព្យាករណ៍សំរាប់សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០៩ ក៏បានបញ្ចុះមកត្រឹម ៣,0% (EIU 2008a) និង ៤,៧% (ADB 2008b) ។ EIU បង្ហាញពីការព្យាករណ៍សំរាប់ឆ្នាំ២០១០ ហើយរំពឹងថា កំណើននៅមានកំរិតទាបដដែលត្រឹម ៣,៦% ។ ការបញ្ចុះថែមទៀតក្នុងខែមករានូវអត្រាកំណើនក្នុងពិភពលោករបស់ IMF (2009a) ក៏អាចមានឥទ្ធិពលទៅលើការព្យាករណ៍កំណើនសំរាប់កម្ពុជាផងដែរ ប៉ុន្តែតួលេខទាំងនេះមិនទាន់បានដាក់បញ្ចូលគ្នានៅឡើយទេ ។ ដូច្នេះ អត្រាកំណើនសំរាប់កម្ពុជា អាចខិតទៅជិតតួលេខព្យាករណ៍ដែលទាបជាងគេ ឬក៏ទាបជាងនោះទៀត ដោយសារពាណិជ្ជកម្មកម្ពុជា ត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើកំណើនក្នុងប្រទេសឧស្សាហកម្មនានា ។

ការព្យាករណ៍ភាគច្រើន បង្ហាញពីការធ្លាក់កំណើនការនាំចេញសំលៀកបំពាក់ក្នុងឆ្នាំ២០០៨-០៩ ដែលជាកត្តាចំបងធ្វើឱ្យកំណើនសរុបធ្លាក់ចុះ (Menon 2009) ។ គំរោងលុបបំបាត់ការដាក់កំហិតលើការនាំចេញសំលៀកបំពាក់ពីប្រទេសចិនទៅកាន់សហរដ្ឋអាមេរិកនិងសហគមន៍អឺរ៉ុប ទំនងជាជះឥទ្ធិពលយ៉ាងខ្លាំងមកលើការនាំចេញសំលៀកបំពាក់របស់កម្ពុជា ។ កំណើនការប្រកួតប្រជែងនេះ វាកើតឡើងចំពេលសេដ្ឋកិច្ចពិភពលោក កំពុងធ្លាក់ចុះដែលធ្វើឱ្យថយចុះ

តំរូវការពីទីផ្សារចំបងៗ ។ វិស័យសេវាកម្មបន្តរីកចំរើនដែលជំរុញឱ្យមានកំណើនតទៅមុខទៀត ព្រមទាំងកំណើនជាបន្តបន្ទាប់ក្នុងវិស័យហិរញ្ញវត្ថុ ពាណិជ្ជកម្ម ហើយនិងវិស័យទេសចរណ៍ក្នុងកំរិតណាមួយ (ទេសចរណ៍មានសញ្ញាធ្លាក់ចុះខ្លះហើយ ដោយសារការធ្លាក់ចុះយ៉ាងខ្លាំងនូវចំនួនភ្ញៀវមកពីកូរ៉េ ដែលជាប្រភពភ្ញៀវចំបងសំរាប់កម្ពុជា) ។

ក្រាហ្វិក ៥.៤: អត្រាការប្រាក់ចារិក អតិផរណា CPI* និងអត្រាប្តូរប្រាក់ (ជាដុល្លារ/រូបិយប័ណ្ណក្នុងស្រុក)**




** មធ្យមភាគនៃអត្រាលើកំចីជារូបិយវត្ថុបរទេស ទៅឱ្យសហគ្រាសឯកជន*

** មករា ២០០៦ = ១០០*

*ប្រភព: ការគណនារបស់បុគ្គលិកនៃ OREI ផ្អែកតាមទិន្នន័យបានពី Bloomberg, CEIC និង IMF IFC.*

យោងតាមតួលេខថ្មីៗ ថ្លៃទំនិញប្រើប្រាស់មានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ២២,៣% នៅខែកក្កដា ២០០៨ ក្នុងនេះអត្រាកំណើនសំរាប់ម្ហូបអាហារគឺ ៣៦,៨% ។ បន្ទាប់ពីនោះមក វាចាប់ផ្តើមធ្លាក់ចុះវិញ មកដល់ ២០,២៧% នៅខែកញ្ញា ២០០៨ និង ១៨,១២% នៅខែតុលា ២០០៨ ។ EIU (2008b) ប៉ាន់ប្រមាណថា អតិផរណាប្រចាំឆ្នាំ មានប្រហែល ២០% នៅឆ្នាំ២០០៨ ដែលជាអត្រាខ្ពស់បំផុតចាប់ពីឆ្នាំ១៩៩៥ មក ។ អង្ករ ឡើងថ្លៃ ដោយសារការផ្គត់ផ្គង់ក្នុងស្រុកមិនគ្រប់គ្រាន់ ហើយម្ហូបអាហារផ្សេងទៀតក៏ឡើងថ្លៃដែរ ជាពិសេស សាច់ (សាច់ជ្រូក និងសាច់មាន់) ។ រឿងនេះឆ្លុះបញ្ចាំងពីកំណើនថ្លៃជាសាកល ហើយក៏ជាលទ្ធផលនៃកំណើន ការប្រើប្រាស់ក្នុងស្រុក និងការហាមឃាត់ការនាំចូលសាច់ពីវៀតណាមដើម្បីទប់ស្កាត់ការឆ្លងរាលដាលជម្ងឺសត្វ ។ ក្រៅពីការឡើងថ្លៃប្រេងឥន្ធនៈក្នុងពិភពលោក ការធ្លាក់ថ្លៃប្រាក់ដុល្លារ US ដែលគេប្រើជារូបិយវត្ថុចរាចរយ៉ាងទូលាយនៅកម្ពុជា ក៏បានជួយបង្កើនសម្ពាធអតិផរណាដែរ ។

ដុល្លារូបនីយកម្ម ក៏បានកាត់បន្ថយសមត្ថភាពរបស់អាជ្ញាធររូបិយវត្ថុក្នុងការអនុវត្តនយោបាយរូបិយវត្ថុ ដោយឯករាជ្យ ឬសក្តិសិទ្ធិ ពីព្រោះលំហូរចូល ឬលំហូរចេញនៃមូលធន វាផ្លាស់ប្តូរដល់ការផ្គត់ផ្គង់រូបិយវត្ថុ ជាស្វ័យប្រវត្តិ នៅពេលមានរូបិយប័ណ្ណបរទេសណាមួយត្រូវបានប្រើប្រាស់ជំនួសរូបិយវត្ថុក្នុងស្រុក (សូមអាន Salvatore et al, 2004; Watanabe 2006; Menon 2008a; b) ។ លំហូរចេញរូបិយវត្ថុបរទេសធ្វើឱ្យរួមចុះការផ្គត់ផ្គង់រូបិយវត្ថុ រីឯលំហូរចូលរូបិយវត្ថុបរទេស វាពង្រីកការផ្គត់ផ្គង់រូបិយវត្ថុ ។ លំហូរចេញរូបិយវត្ថុបរទេសអាចបង្កបរិត្តផរណា រីឯលំហូរចូល

រូបិយវត្ថុបរទេស អាចបង្កអតិផរណា ។ ឥទ្ធិពលនៃចលនាមូលធនទៅលើការផ្គត់ផ្គង់រូបិយវត្ថុនិងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក គឺអាចកាត់បន្ថយបាន ប្រសិនបើធនាគារជាតិនៃកម្ពុជាអាចអនុវត្ត ដូចជា ប្រតិបត្តិការទីផ្សារចំហ (open market operations) ជាដើម ។ កង្វះឧបករណ៍ខាងរូបិយវត្ថុក្នុងទំរង់ជា ទ្រព្យមានការប្រាក់ជាប្រាក់រៀល បានរារាំងធនាគារទាំងនេះក្នុងការអនុវត្តប្រតិបត្តិការទីផ្សារចំហ ។ ទោះបីជាពួកគេអាចបោះផ្សាយនូវទ្រព្យដែលមានការប្រាក់ជារៀលក្តី ប៉ុន្តែកង្វះទំនុកចិត្តលើទ្រព្យទាំងនេះ អាចដាក់កំហិតដល់ការជាវទ្រព្យនេះ ។ ចំពោះឧបករណ៍រូបិយវត្ថុដទៃទៀត ដូចជា ការផ្លាស់ប្តូរក្នុងធនបំរុងជាកាតព្វកិច្ចជាដើម វាច្រើនមិនសូវមុតស្រួចទេ ពីព្រោះដុល្លារូបនីយកម្មធ្វើឱ្យលំហូរចូលមូលធនក្លាយជាចំណែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុ ដោយរំលងចោលនូវប្រព័ន្ធហិរញ្ញវត្ថុតែម្តង ។ ដូច្នេះ សមត្ថភាពក្នុងការរក្សានយោបាយរូបិយវត្ថុឯករាជ្យ ត្រូវជាប់ពាក់ព័ន្ធនឹងដំណោះស្រាយបញ្ហាដុល្លារូបនីយកម្ម និងការកែលំអប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងប្រទេស ហើយការងារទាំងនេះសុទ្ធតែប្រើរយៈពេលវែង ។

ដោយសារដុល្លារូបនីយកម្មបានកាត់បន្ថយចំនួនឧបករណ៍នៃនយោបាយម៉ាក្រូ ដូច្នេះអតិផរណាក៏ក្លាយជាបញ្ហាមួយយ៉ាងធំដែលគ្មានដំណោះស្រាយក្នុងស្រុក ។ ប៉ុន្តែនេះជាស្ថានភាពនៅមុនពេលមានវិបត្តិសាកល ។ រឿងល្អមួយដែលផុសចេញពីការថយចុះកំណើន និងការចុះថ្លៃប្រេងឥន្ធនៈ និងផលិតផលផ្សេងៗ គឺការថយចុះសម្ពាធអតិផរណានៅកម្ពុជា ។ អតិផរណាក្នុងឆ្នាំ២០០៩ រំពឹងថានឹងថយចុះថែមទៀត ពីព្រោះថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ បានធ្លាក់ចុះ ទោះបីវាអាចស្ថិតនៅកំរិតមួយយ៉ាងខ្ពស់ក្តី ហើយកំណើនរូបិយវត្ថុក៏នៅតែ រឹងប៉ឹងដោយមានកំរិត ៤០% ក្នុងខែមិថុនា២០០៨ (ក្រាហ្វិក៥.៤) ។ប៉ុន្តែការរឹតបន្តឹងឥណទានក្នុងពេល សេដ្ឋកិច្ចពិភពលោកធ្លាក់ចុះនេះ អាចកាត់បន្ថយលំហូរចូលវិនិយោគផ្ទាល់ពីបរទេសដែលធ្លាប់តែខ្លាំងក្លា ហើយប៉ះពាល់កាន់តែធ្ងន់ធ្ងរដល់ស្ថានភាពឥណទានក្នុងស្រុក ។ ដោយយោងតាមការថយចុះសម្ពាធអតិផរណា របាយការណ៍ស្តីពីកម្ពុជាដែលចេញផ្សាយដោយ EIU ក្នុងខែធ្នូ ២០០៨ (2008b) បានកាត់បន្ថយការព្យាករណ៍អតិផរណាសំរាប់ឆ្នាំ២០០៩ ពី ៩,៣% មកត្រឹម ៤,៨% ។

## ៨. ការសម្លឹងទៅមុខ និងសេចក្តីសន្និដ្ឋាន

ទោះបីអាជ្ញាធររូបិយវត្ថុនៅជុំវិញពិភពលោក បានដាក់បញ្ចូលសាច់ប្រាក់យ៉ាងច្រើនៗទៅក្នុងសេដ្ឋកិច្ចក្តី ក៏ទីផ្សាររូបិយវត្ថុ និងស្ថានភាពហិរញ្ញវត្ថុជាទូទៅ នៅតែតឹងតែង ហើយការរើបឡើងវិញអាចកើតឡើងសន្សឹមៗប៉ុណ្ណោះ ។ តាំងពីពាក់កណ្តាលខែកញ្ញា ២០០៨ មក ធនាគារកណ្តាលសំខាន់ៗក្នុងពិភពលោក បានចាត់វិធានការខ្លាំងៗ និងធំទូលាយមិនធ្លាប់មាន រួមទាំងការផ្តល់សាច់ប្រាក់យ៉ាងច្រើនសំបើមដល់ស្ថាប័ននានា និងទីផ្សារ ព្រមទាំងពង្រីកកិច្ចព្រមព្រៀងស្តីពីការដោះដូររូបិយវត្ថុបរទេស ដើម្បីបញ្ឈប់វិបត្តិ និងកសាងទំនុកចិត្តសាធារណៈឡើងវិញ ។ ប៉ុន្តែភាពផុយស្រួយនៃទីផ្សារនៅមានកំរិតខ្ពស់ ហើយទីផ្សារសំរាប់ផ្តល់ទុនឱ្យធនាគារនៅតែតឹងតែងជាខ្លាំង ។ ប្រសិនបើស្ថានភាពហិរញ្ញវត្ថុសាកលតឹងតែងថែមទៀត ការរឹតបន្តឹងឥណទានក្នុងស្រុកទៅលើ សកម្មភាពសេដ្ឋកិច្ចជាទូទៅនឹងប៉ះពាល់កាន់តែខ្លាំងដល់តំបន់អាស៊ីខាងកើតដែលទើបតែអភិវឌ្ឍឡើង និងដែលនៅទីនោះសហគ្រាសនានាត្រូវពឹងផ្អែកយ៉ាងខ្លាំងលើទុនបានពីធនាគារ ។

មកដល់ពេលនេះ តំបន់អាស៊ាន + ៣ ព្រមទាំងបណ្ដាប្រទេស និងអនុតំបន់ដែលរួមផ្សំ (គឺមាន ជប៉ុន ចិន បណ្ដាប្រទេសឧស្សាហកម្មថ្មី អាស៊ាន៤ ឡាវ វៀតណាម និងកម្ពុជា) បានឆ្លងកាត់ភាពរីកវរបានប្រសើរជាងតំបន់ឯទៀតក្នុងពិភពលោក ។ IMF បានព្យាករណ៍ថ្មីៗនេះថា សំរាប់ឆ្នាំ២០០៩ សហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ នឹងរួមចុះសេដ្ឋកិច្ច ១,៦% និង ២,០% ចំណែកឯតំបន់អាស៊ីដែលកំពុងអភិវឌ្ឍនឹងមានកំណើន ៥,៥% ។

គេប៉ាន់ស្មានថា នៅឆ្នាំ២០០៨ សេដ្ឋកិច្ចកម្ពុជាកើនឡើង ៦,៥% ដែលជាការធ្លាក់ចុះយ៉ាងខ្លាំង ធៀបនឹងកំណើន ១០,១% ក្នុងឆ្នាំ២០០៧ ក៏ដូចជា កំណើនលេខពីរខ្ទង់ក្នុងរយៈពេលបីឆ្នាំមុននោះទៀត ។ កំណើនទំនងជា ស្ថិតនៅចន្លោះពី ៣-៤% សំរាប់ឆ្នាំនេះ និងឆ្នាំក្រោយ ។ ប៉ុន្ដែ ការព្យាករណ៍កំណើននេះ មិនបានគិតបញ្ចូលនូវ ការព្យាករណ៍បញ្ចុះតួលេខកំណើនសេដ្ឋកិច្ចពិភពលោក ដោយ IMF កាលពីខែមករានោះទេ ។ ដូច្នេះ កំណើននៅកម្ពុជា អាចធ្លាក់ដល់តួលេខខាងទាបបំផុតនៃការព្យាករណ៍ ឬក៏ទាបជាងនោះទៀត ដោយសារពាណិជ្ជកម្មកម្ពុជា ត្រូវពឹងផ្អែកលើកំណើននៃប្រទេសឧស្សាហកម្ម ។ ប៉ុន្ដែរឿងល្អមួយផុសចេញពីការធ្លាក់ចុះកំណើន គួបផ្សំនឹងការចុះថ្លៃប្រេងឥន្ធនៈ និងផលិតផលផ្សេងៗ គឺការថយចុះសម្ពាធអតិផរណានៅកម្ពុជា ។ អតិផរណាបានលេចឡើងជាបញ្ហាសំខាន់មួយរួចទៅហើយ នៅពាក់កណ្ដាលឆ្នាំ២០០៨ នៅមុនពេលមានវិបត្ដិពិភពលោក ។

ការព្យាករណ៍ឱ្យបានច្បាស់លាស់ គឺជាការងារដ៏លំបាក ហើយនៅពេលនេះវាប្រហែលជារឹតតែលំបាកជាងពេលមានវិបត្ដិសាកលលោកលើកមុនៗទៅទៀត ។ យន្ដការផ្ទេរផលប៉ះពាល់ដែលជាប់ទាក់ទងនឹងវិបត្ដិហិរញ្ញវត្ថុនេះ គេលំបាកនឹងតាមដាន វាស់វែង និងព្យាករណ៍ឱ្យបានពេញលេញណាស់ ។ គេក៏មិនប្រាកដដែរថា ទៅអនាគតនឹងមានការដាក់អនុវត្តវិធានការថ្មីអ្វីខ្លះទៀត ។ ការព្យាករណ៍នៅពេលនេះ ឈរលើការសន្មតថា នឹងគ្មានអន្ដរាគមន៍អ្វីថ្មីទៀតឡើយ ដោយសារដំណើរការ ឬទំហំនៃសកម្មភាពណាមួយនាពេលអនាគត គេមិនអាចទស្សន៍ទាយវាបានច្បាស់ទេ ។ ប៉ុន្ដែរឿងមួយដែលច្បាស់គួរសម គឺលក្ខខណ្ឌហិរញ្ញវត្ថុទំនងបន្ដប្រែប្រួលយ៉ាប់យ៉ឺនថែម ជាជាងធូរស្រាលវិញ ដូច្នេះ ការព្យាករណ៍នេះទំនងជាខិតទៅជិតសេណារីយ៉ូសុទិដ្ឋិនិយម ជាជាងសេណារីយ៉ូទុទិដ្ឋិនិយម ។ នេះជារឿងមិនល្អមួយ ប៉ុន្ដែវាជារឿងពិត ។

# ជំពូក ៦
# ការដឹកនាំនៅថ្នាក់ភូមិ/ឃុំក្នុងឃុំបីនៃប្រទេសកម្ពុជា

*ដោយកញ្ញា ធន់ វិមាលា ជាអ្នកស្រាវជ្រាវនៅ វិបសអ*

*"ទោះជាមានការផ្លាស់ប្តូរជាច្រើនក្នុងវិស័យនយោបាយក៏ដោយ ក៏មកទល់ពេលនេះប្រជាជនជាច្រើននៅប្រទេសកម្ពុជានៅតែប្រកាន់ចង់បានអ្នកដឹកនាំចាស់ដដែល។" ។*

ដោយសារភាពក្រីក្រ និងប្រព័ន្ធរដ្ឋបាលមិនទាន់រឹងមាំរួមទាំងការផ្លាស់ប្តូររបបនយោបាយក្នុងប្រទេសកន្លងមក ប្រជាជនកម្ពុជានៅមិនទាន់មានការទុកចិត្តទៅលើរដ្ឋាភិបាលនៅឡើយ ។ នេះជាដើមហេតុធ្វើឱ្យមានគម្លាតដ៏ធំរវាងអ្នកដឹកនាំនិងប្រជាជន បើទោះជាមានការបោះឆ្នោតឃុំ-សង្កាត់ពីរលើកកន្លងមកហើយក្តី ។ អត្ថបទនេះសិក្សាអំពីភាពជាអ្នកដឹកនាំផ្សេងៗនៅថ្នាក់មូលដ្ឋាន ដោយផ្តោតសំខាន់ទៅលើតួនាទីរបស់ពួកគាត់ក្នុងការជួយបង្រួមគម្លាតរវាងប្រជាពលរដ្ឋ និងអ្នកដឹកនាំ ។ ការសិក្សានេះផ្តោតលើសំនួរសំខាន់ៗ ៤ ដូចខាងក្រោម:

១. តើមានអ្នកដឹកនាំប្រភេទណាខ្លះនៅថ្នាក់មូលដ្ឋាន?

២. តើសិទ្ធិអំណាច និងការទទួលស្គាល់សិទ្ធិអំណាចរបស់ពួកគាត់ពឹងផ្អែកលើកត្តាអ្វីខ្លះ?

៣. តើពួកគាត់សកម្មលើការងារអ្វីខ្លះ ហើយជួបនឹងផលវិបាកអ្វីខ្លះក្នុងការបំពេញតួនាទីទាំងនោះ?

៤. តើស្ត្រីមានឱកាសប៉ុណ្ណា និងជួបការលំបាកអ្វីខ្លះក្នុងការក្លាយជាអ្នកដឹកនាំ?

ការសិក្សានេះបានជ្រើសរើសយកឃុំបី ក្នុងខេត្តចំនួនបី ក្នុងប្រទេសកម្ពុជា ដើម្បីស្រាវជ្រាវ ដោយចាប់ផ្តើមពីការសម្ភាសប្រជាជនមុននឹងសម្ភាសអ្នកដឹកនាំថ្នាក់ភូមិ-ឃុំ ។ ក្នុងចំណោមឃុំទាំងបីនេះ មានឃុំមួយសំបូរទៅដោយព្រៃភ្នំ ឃុំមួយទៀតសំបូរទៅដោយវាលស្រែនិងបឹង និងឃុំចុងក្រោយមានផ្សារធំមួយ ។ ប្រជាជនក្នុងខេត្តទាំងបីនេះប្រកបរបរធ្វើស្រែចំការជាចំបង និងរបរតូចផ្សេងៗទៀតទៅតាមលក្ខណៈធនធានដែលមានក្នុងឃុំនីមួយៗ ។

## តើអ្នកណាខ្លះជាអ្នកដឹកនាំ?

*មេភូមិ និងថ្នាក់ដឹកនាំភូមិ:* ប្រជាជនតែងតែសំដៅទៅរកអាជ្ញាធរភូមិ ជាពិសេសមេភូមិ នៅពេលពួកគាត់ជួបនឹងបញ្ហាផ្សេងៗ ឬមានធុរៈចាំបាច់នានា ។ ក្នុងករណីខ្លះ អ្នកភូមិហៅមេភូមិថាឪ ដែលនេះបង្ហាញពីការគោរពស្រលាញ់ចំពោះភាពស្លូតបូត និងស្មោះត្រង់របស់គាត់ ។

*ក្រុមប្រឹក្សាឃុំ និងមេឃុំ:* នៅពេលមានបញ្ហាអ្វីមួយដែលមេភូមិមិនអាចដោះស្រាយបាន ប្រជាជនក៏បន្តទៅរកក្រុមប្រឹក្សាឃុំ ។ អ្នកភូមិប្រើពាក្យផ្សេងៗដើម្បីហៅក្រុមប្រឹក្សាឃុំដូចជា អាជ្ញាធរឃុំ ក្រុមប្រឹក្សាឃុំ និងមេឃុំ ។ ប្រជាជនតែងតែរំពឹងថា អាជ្ញាធរឃុំនឹងដើរតួនាទីជាម៉ែឪដែលជួយដោះទុក្ខធុរៈ ចេះយកអាសារកូនចៅ និងស្រលាញ់កូនចៅស្មើៗគ្នា ។ ពួកគាត់នឹងបាត់បង់ការទុកចិត្តលើក្រុមប្រឹក្សាឃុំ បើសិនក្រុមប្រឹក្សាឃុំ មិនបំពេញតួនាទីទាំងនេះបានទេ ។

*ចាស់ទុំ និងអាចារ្យ:* ចាស់ទុំដើរតួនាទីសំខាន់ក្នុងភូមិ ដោយសារអ្នកភូមិ និងអ្នកដឹកនាំភូមិ-ឃុំ តែងតែពឹងពាក់ពួកគាត់ដើម្បីសុំយោបល់ និងសុំការចូលរួម ជាពិសេសលើរឿងជម្លោះក្នុងគ្រួសារ ។ ដោយឡែកនៅភូមិដែលសំបូរទៅដោយអ្នកចំណូលថ្មី និងពិសេសចំពោះភូមិ/ឃុំដែលសំបូរទៅដោយព្រៃឈើ ប្រជាជនមិនសូវជាផ្តល់តម្លៃដល់ចាស់ទុំប៉ុន្មានទេ ដោយសារការមិនសូវស្គាល់គ្នា ។ ចំណែកឯអាចារ្យវិញ ពួកគាត់ដើរតួសំខាន់ក្នុងការប្រមូលថវិកានៅពេលមានបុណ្យទាន ។

*អ្នកមានទ្រព្យសម្បត្តិ:* ពួកគាត់ភាគច្រើនជាថៅកែប្រកបរបរផ្សេងៗនៅក្នុងឃុំ ដែលជួយផ្តល់ជំនួយជាថវិកា ស្រូវ ឬរបស់របរផ្សេងៗដល់ភូមិ និងឃុំ ។ អ្នកដឹកនាំប្រភេទនេះ ចែកចេញជាពីរប្រភេទដែលប្រភេទទីមួយជាអ្នកមានខ្លាំង ហើយមិនដាក់ខ្លួនជិតដិតជាមួយអ្នកភូមិ ឬអាជ្ញាធរទេ ក៏ប៉ុន្តែពួកគាត់តែងតែផ្តល់ជំនួយដូចជាការសាងសង់ផ្លូវថ្នល់វិញ ។ រីឯប្រភេទទីពីរ គឺជាអ្នកមានទ្រព្យសមល្មម ហើយមានទំនាក់ទំនងជិតដិតគ្រាន់បើជាមួយអ្នកភូមិ ដោយសារគាត់ដើរតួនាទីជាអ្នកឱ្យខ្ចីលុយ ឬជួលរោងបុណ្យ និងឧបករណ៍បំពងសម្លេង (ធុងបាស) ជាដើម ។ ពួកគាត់តែងតែត្រូវបានគណបក្សនយោបាយនានាអូសទាញឱ្យចូលឈរឈ្មោះក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ ។

*គ្រូបង្រៀន និងអង្គការ ឬសហគមន៍ផ្សេងៗ:* អង្គការមានសារៈសំខាន់ក្នុងការផ្តល់ជំនួយជាសំភារៈ ប៉ុន្តែពួកគាត់មិនដើរតួនាទីសំខាន់ក្នុងការតំណាង ឬជួយដោះស្រាយផ្ទាល់នូវបញ្ហាផ្សេងៗដល់ប្រជាជននោះទេ ដូច្នេះចំពោះពួកគាត់ អង្គការមិនមែនជាអ្នកដឹកនាំទេ ។

*ស្ត្រី:* ចំនួនស្ត្រីក្នុងក្រុមប្រឹក្សាឃុំជាពិសេសចំនួនស្ត្រីដែលជាមេឃុំនៅមានចំនួនតិចនៅឡើយ បើទោះជាស្ត្រីក្រុមប្រឹក្សាឃុំ/សង្កាត់កើនពី ៨,៥% ទៅ ១៤,៦% ក្នុងកំឡុងឆ្នាំ២០០២ ដល់ ២០០៧ ក៏ដោយ ។ តាមការសង្កេតនារីបង្គោលឃុំនៅក្នុងឃុំទាំងបីមិនសូវសកម្ម និងមិនមានតួនាទីការងារច្បាស់លាស់ទេ ។ ចំណែកឯនៅថ្នាក់ភូមិវិញ ឃើញមានការបញ្ចូលសមាជិកម្នាក់ជាស្ត្រីក្នុងថ្នាក់ដឹកនាំភូមិទាំងបី ប៉ុន្តែមេភូមិជាស្ត្រីនៅមិនទាន់មាននៅឡើយទេនៅក្នុងភូមិទាំងប្រាំមួយក្នុងឃុំទាំងបីនេះ ។

## តើអ្នកដឹកនាំមានលក្ខណៈអ្វីខ្លះ?

*ចំណេះដឹង:* ក្នុងឃុំទាំងបីនេះ ក្រុមប្រឹក្សាឃុំដែលបានទទួលការអប់រំជាផ្លូវការត្រឹមបឋមសិក្សាមានចំនួន ៤០% និង ៦០% ទៀតបានដល់មធ្យមសិក្សា ។ ចំណែកឯថ្នាក់ដឹកនាំភូមិវិញ អ្នកដែលរៀនបានដល់មធ្យមសិក្សាមានត្រឹមតែ ២៩% ប៉ុណ្ណោះហើយ ៧១% ទៀតបានត្រឹមបឋមសិក្សា ។ អ្នកដឹកនាំជាស្ត្រីច្រើនតែបានទទួលការសិក្សាបានខ្ពស់គ្រាន់បើ ។ សំរាប់ចាស់ទុំនិងអាចារ្យវិញ ពួកគាត់ភាគច្រើនសិក្សាតែនៅវត្ត ។ រីឯថៅកែនៅក្នុងឃុំវិញ ថ្វីត្បិតតែពួកគាត់ជាអ្នករកស៊ី ប៉ុន្តែពួកគាត់មានចំណេះដឹងជាមធ្យមខ្ពស់ជាងក្រុមប្រឹក្សាឃុំ ។

*អាយុ និងបទពិសោធន៍:* ច្បាប់ឃុំ/សង្កាត់កំណត់ថា ប្រជាពលរដ្ឋខ្មែរដែលមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅអាចឈរឈ្មោះជាបេក្ខជនសំរាប់ក្រុមប្រឹក្សាឃុំ/សង្កាត់បាន ប៉ុន្តែការសិក្សានេះរកឃើញថា ថ្នាក់ដឹកនាំក្រុមប្រឹក្សាឃុំ/សង្កាត់ និងភូមិចំនួន ៧៦% មានអាយុចាស់ជាង ៤៩ឆ្នាំ ហើយភាគច្រើនពួកគាត់ធ្លាប់មានតួនាទីក្នុងការងាររដ្ឋបាលដឹកនាំភូមិឃុំពីមុនមក (ពីឆ្នាំ១៩៧៩ ឬមុននោះទៅទៀត) ។ ចំណែកឯអ្នកដឹកនាំជាស្ត្រីវិញ ចំនួន ៥០% មានអាយុតិចជាង ៤៩ឆ្នាំ ចំពោះថៅកែវិញច្រើនតែមានអាយុជាង ៤០ឆ្នាំ ហើយមានអ្នកខ្លះធ្លាប់ធ្វើការនៅតាមថ្នាក់ស្រុក ខេត្ត ឬថ្នាក់ជាតិក៏មាន ។

## តើអ្នកដឹកនាំមានខ្សែរយៈអ្វីខ្លះ?

អាជ្ញាធរភូមិ/ឃុំភាគច្រើន សុទ្ធសឹងតែជាសមាជិកគណបក្សប្រជាជនកម្ពុជា ។ ទិន្នន័យលើលទ្ធផលបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០០៧ នៅប្រទេសកម្ពុជាបង្ហាញថា ៩៨,៦% នៃចំនួនមេឃុំទាំងអស់ជាសមាជិកគណបក្សប្រជាជន ។ ចំណែកឯអ្នកដឹកនាំជាស្ត្រីវិញ គណបក្សនានាជាពិសេសខាងគណបក្សប្រជាជនកំពុងតែទាក់ទាញពួកគាត់ឱ្យចូលរួមក្នុងថ្នាក់ដឹកនាំភូមិ/ឃុំ ។ រីឯស្ត្រីខ្លះទៀត ចូលរួមដោយសារស្វាមីគាត់មានតួនាទីដឹកនាំក្នុងភូមិ/ឃុំស្រាប់ ។ ចំពោះចាស់ទុំ និងអាចារ្យ ជាទូទៅពួកគាត់មានទំនាក់ទំនងល្អជាមួយអ្នកភូមិ ថ្នាក់ដឹកនាំក្នុងភូមិឃុំ វត្ត និងអ្នកមកពីក្រៅដូចជាអ្នកនយោបាយថ្នាក់ជាតិជាដើម ។ ស្រដៀងគ្នានេះដែរ ថៅកែធំច្រើនតែមានទំនាក់ទំនងល្អជាមួយអាជ្ញាធរធំៗ ឬអ្នកនយោបាយថ្នាក់ជាតិមួយចំនួនដែលជាកត្តាធ្វើឱ្យពួកគាត់មិនសូវស្តាប់ ឬគោរពអាជ្ញាធរភូមិ/ឃុំទេ ។

## តើកត្តាអ្វីខ្លះដែលជំរុញឱ្យពួកគាត់ក្លាយជាអ្នកដឹកនាំ?

អាជ្ញាធរភូមិ-ឃុំទទួលប្រាក់បៀវត្សរ៍មិនគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គាត់ទេ ដូច្នេះការចូលរួមក្នុងថ្នាក់ដឹកនាំភូមិ/ឃុំរបស់គាត់ គឺមានកត្តាជំរុញផ្សេងទៀត ។ ការធ្វើបទសម្ភាសន៍ជាមួយពួកគាត់បានឱ្យឃើញថា កត្តាដទៃៗទៀតដែលជំរុញឱ្យពួកគាត់ចូលរួមការងារជាអាជ្ញាធរភូមិឃុំមានដូចជា មុខមាត់ ការបន្តការងារពីបុព្វជន ឱកាសសំរាប់ទទួលប្រយោជន៍ផ្សេងៗដូចជាប្រាក់កម្រៃក្រៅផ្លូវការ និងអាហារូបករណ៍សំរាប់កូនៗគាត់ និងថវិកាឧបត្ថម្ភផ្សេងៗរបស់គណបក្ស ការដឹងគុណគណបក្ស និងការស្រឡាញ់និងទឹកចិត្តចង់បម្រើជាតិ និងប្រជាជន ។ សំរាប់ចាស់ទុំ និងអាចារ្យវិញ ការជួយប្រជាជននិងបំពេញតួនាទីរបស់ពួកគាត់គឺភាគច្រើនមកពីការស្រឡាញ់ និងមានទឹកចិត្តចង់ជួយភូមិឃុំរបស់ពួកគាត់ និងការចង់សាងគុណធម៌ដែលទាំងនេះគាត់គិតថា វាក៏ជាកាតព្វកិច្ចរបស់គាត់ដែរ ។ ការជួយឧបត្ថម្ភដល់សហគមន៍ គឺជាកាតព្វកិច្ចមួយរបស់ថៅកែដែលជាអ្នកមានក្នុងភូមិ/ឃុំ ។ នៅពេលជាមួយគ្នានេះដែរ ការជួយទំនុកបំរុងសហគមន៍ក៏អាចជួយឱ្យថៅកែទាំងនេះមានអំណាចនៅក្នុងភូមិឃុំផងដែរ ។ ប្រការនេះជួយឱ្យការរកស៊ីរបស់ពួកគាត់មានភាពរលូនដោយមិនចាំបាច់ខ្លាចអំណាចអាជ្ញាធរភូមិឃុំ ។

## តួនាទី និងសកម្មភាពរបស់អ្នកដឹកនាំ

ក្រុមប្រឹក្សាឃុំកំពុងតែប្រឈមមុខនឹងតួនាទី និងការងារដ៏ច្រើនដែលពួកគាត់មិនមានធនធាន ឬសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញការងារ ។ដូច្នេះភាគច្រើនគាត់បានត្រឹមតែធ្វើការងាររដ្ឋបាលតូចតាច ជួយសម្រួលជម្លោះផ្សេងៗដល់ប្រជាជន និងធ្វើគម្រោងការអភិវឌ្ឍឃុំ ។ ក្នុងការប្រមូលប្រាក់ឧបត្ថម្ភពីប្រជាជន និងប្រមូលប្រជាជនឱ្យចូលរួមប្រជុំ ឬធ្វើការផ្សេងៗ អាជ្ញាធរឃុំតែងតែពឹងលើជំនួយរបស់អាជ្ញាធរភូមិ ។ ចំណែកឯការធ្វើគម្រោងអភិវឌ្ឍន៍ឃុំវិញ ពួកគាត់នៅមិនទាន់យល់ច្បាស់ និងមានបទពិសោធន៍គ្រប់គ្រាន់នៅឡើយ ហើយប្រជាជនក៏នៅមិនមានទម្លាប់ចូលរួមប្រជុំកុះករ ឬចូលរួមយោបល់នៅឡើយ ។ ពួកគាត់ចូលចិត្តតែចូលរួមការប្រជុំរបស់គណបក្ស ដែលក្នុងនោះពួកគាត់តែងតែទទួលបានក្រមា សារុង ឬរបស់ឧបត្ថម្ភផ្សេងៗទៀត ។ អាជ្ញាធរឃុំមិនទាន់មានសិទ្ធិអំណាចគ្រប់គ្រាន់ ក្នុងការដោះស្រាយជម្លោះ ជាពិសេសលើបញ្ហាធនធានធម្មជាតិទេ ។ ពួកគាត់បានត្រឹមតែជួយសម្រួលដោះស្រាយជម្លោះក្នុងគ្រួសារ និងដីធ្លីតូចតាចប៉ុណ្ណោះ ។ ក្នុងពេលជាមួយគ្នានោះដែរ អាជ្ញាធរឃុំក៏កំពុងតែមមាញឹកនឹងការធ្វើប្លង់ដីធ្លី ការផ្តល់លិខិតស្នាម លក់ដីទិញដី និងលិខិតអនុញ្ញាតឱ្យខ្ចីលុយពីស្ថាប័នមីក្រូហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋ ។ ជាង

នេះទៅទៀត ពួកគាត់មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញការងារ ដោយសារមានប្រជុំ និងវគ្គបណ្តុះបណ្តាលផ្សេងៗច្រើនពេក ។ ក្រៅពីការប្រជុំម្តងម្កាលអំពីអំពើហឹង្សាក្នុងគ្រួសារ ក្រសួងកិច្ចការនារីនៅក្នុងឃុំទាំងបីនេះគ្មានសកម្មភាពអ្វីដែលទាក់ទិននឹងការងារយេនឌ័រទេ ។ បែរមកមើលពីតួនាទី និងសកម្មភាពចំបងរបស់ចាស់ទុំវិញ ពួកគាត់តែងជួយកេណ្ឌកម្លាំងសំរាប់សកម្មភាពសាងសង់ផ្សេងៗក្នុងភូមិឃុំ និងជួយការងារគណៈកម្មការវត្ត ។ ចំណែកឯអាចារ្យវិញ គាត់ដើរតួសំខាន់ក្នុងការប្រមូលធានធាន និងរៃអង្គាសថវិកាសំរាប់វត្ត ។ ប៉ុន្តែនាពេលសព្វថ្ងៃ ដើម្បីធ្វើការនេះបាន វត្តនិងអាចារ្យវត្ត ត្រូវតែមានទំនាក់ទំនងល្អជាមួយនឹងគណបក្ស ឬអ្នកនយោបាយសំខាន់ៗណាមួយ ។ ចំពោះថៅកែធំៗវិញ របររកស៊ីរបស់ពួកគាត់បាននាំឱ្យគាត់មានទ្រព្យស្តុកស្តម្ភ មានអំណាចនិងឥទ្ធិពលក្នុងឃុំ ប៉ុន្តែរបររបស់ពួកគាត់ ក៏មានតួនាទីក្នុងការផ្តល់ការងារដល់អ្នកភូមិផងដែរ ។ ក្រៅពីនេះ គាត់ក៏ជួយឧបត្ថម្ភដល់ការសាងសង់ផ្លូវថ្នល់ វត្តអារាម ដែលជាការងារផ្សេងៗរបស់គណបក្សពួកគាត់ និងដល់គម្រោងផ្សេងៗរបស់ឃុំ ។ តែទោះជាយ៉ាងណា ការជួយទាំងនេះ គឺធ្វើឡើងដើម្បីផលប្រយោជន៍រកស៊ី (ជាពិសេសការលួចពន្ធការកាប់ឈើ ឬការរកស៊ីខុសច្បាប់) របស់ពួកគាត់ជាជាងជំនួយឥតលក្ខខណ្ឌ ។ ចំពោះថៅកែ តូចតាចដែលជិតដិតជាមួយប្រជាជន ពួកគាត់ជួយផ្តល់ជាប្រាក់កម្ចីដល់ប្រជាជន និងអាចជួយដោះស្រាយ ឬសម្រួលជម្លោះក្នុងគ្រួសារដោយសារពួកគាត់មានទឹកមាត់ប្រៃ ។ ចំពោះអ្នកមានចំណេះដឹងក្នុងភូមិឃុំវិញ ពួកគាត់គ្មានសមត្ថភាពដឹកនាំអ្វីជាទូទៅទេ គឺពួកគាត់គ្រាន់តែចេញមុខតំណាងឱ្យប្រជាជនម្តងម្កាលនៅពេលដែលមានជម្លោះលើធនធានណាដែលប៉ះពាល់ដល់កម្មសិទ្ធិរបស់គាត់ ។ រីឯអង្គការសហគមន៍ផ្សេងៗ ដូចជាសហគមន៍នេសាទ និងព្រៃឈើវិញ ក៏មិនសកម្មអ្វីដែរ ពីព្រោះពួកគាត់គ្មានសិទ្ធិ និងជំនួយគ្រប់គ្រាន់ក្នុងការការពារធនធានទាំងនេះអំពីបទល្មើសនិងជនល្មើសឡើយ ។

## ការលំបាកផ្សេងៗដែលអ្នកដឹកនាំជួបប្រទះ

អាជ្ញាធរភូមិ/ឃុំស្ថិតនៅក្រោមសម្ពាធជាច្រើន ក្នុងនេះ ទីមួយគឺសម្ពាធគ្រួសារដោយសារពួកគាត់មានកូន និងប្រពន្ធក្នុងបន្ទុក ហើយប្រាក់ខែរបស់ពួកគាត់មានតិចតួចមិនអាចជួយសម្រួលដល់បន្ទុកគ្រួសាររបស់គាត់បាន ។ ដូច្នេះដើម្បីចិញ្ចឹមកូននិងប្រពន្ធ គាត់ត្រូវប្រព្រឹត្តអំពើពុករលួយតូចតាចផ្សេងៗដូចជា ការតម្លើងប្រាក់កំរៃក្រៅផ្លូវការជាដើម ។ ទីពីរគឺសម្ពាធពីគណបក្សនយោបាយនិងថ្នាក់លើ ដោយអ្នកទាំងនេះតម្រូវឱ្យអាជ្ញាធរភូមិ/ឃុំធ្វើតាមនិងបំពេញគោលការណ៍របស់គេ ។ ទីបីគឺ សម្ពាធពីសំណាក់អ្នកបោះឆ្នោតដែលរំពឹងឱ្យអាជ្ញាធរភូមិ/ឃុំ មានការឆ្លើយតបនិងទទួលខុសត្រូវចំពោះការងារបម្រើប្រជាជន ហើយនៅពេលជាមួយគ្នានោះដែរ ប្រជាពលរដ្ឋមិនសូវចូលរួមក្នុងការប្រជុំ ឬចូលរួមប្រាក់ឧបត្ថម្ភដល់ការងារឃុំឡើយ ។ ចំពោះស្ត្រីអ្នកដឹកនាំវិញ ពួកគាត់មានសម្ពាធបន្ថែមពីលើនេះទៀតគឺ ការមិនគាំទ្រពីសំណាក់ស្វាមីនិងអ្នកដឹកនាំបុរស និងត្រូវរ៉ាប់រងការងារមេផ្ទះដែលជាបន្ទុករបស់គាត់តែម្នាក់ឯង ។ ដូចជាក្នុងករណីឃុំមួយនោះ មេឃុំជាស្ត្រីបានបង្ខំចិត្តលែងលះស្វាមីដើម្បីចូលរួមឈរឈ្មោះបោះឆ្នោត ដោយសារស្វាមីគាត់មិនគាំទ្រ និងមិនអនុញ្ញាត ។ ចំពោះចាស់ទុំនិងអាចារ្យវិញ ការងារដឹកនាំរបស់ពួកគាត់ភាគច្រើនជាប់ទាក់ទងទៅនឹងការងារសង្គម និងសាសនា ហើយពួកគាត់ជួយដោយការស្ម័គ្រចិត្តដើម្បីសាងបុណ្យ ដូច្នេះមិនសូវជាមានការគាបសង្កត់ពីសំណាក់អ្នកភូមិ និងអ្នកដទៃទៀតប៉ុន្មានទេ ។ ប៉ុន្តែសព្វថ្ងៃនេះគេឃើញថា អាចារ្យក៏កំពុងទទួលការគាបសង្កត់ផ្នែកនយោបាយច្រើនដែរ ។ ទាំងប្រជាជន ទាំងគណៈកម្មការវត្ត និងទាំងអាជ្ញាធរមូលដ្ឋានពួកគាត់តែងតែរំពឹងជំនួយជាពិសេសផ្នែកថវិកាពីសំណាក់ថៅកែនានាក្នុងភូមិ ហើយថៅកែទាំងនេះតែងផ្តល់ឱ្យជា

ញឹកញាប់ រីឯថៅកែតូចៗដែលជាអ្នកសកម្មក្នុងភូមិ កំពុងជួបប្រទះនឹងការបញ្ចុះបញ្ចូលឱ្យចូលប្រឡូកក្នុងនយោបាយថ្នាក់ភូមិ/ឃុំ ដែលសម្រាប់គាត់វាជាឱកាសល្អក្នុងការជួយភូមិ/ឃុំរបស់គាត់ ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសិក្សានេះបានឱ្យឃើញថា ការដឹកនាំនៅថ្នាក់មូលដ្ឋានមានការផ្លាស់ប្តូរខ្លះៗទៅតាមគោលការណ៍វិមជ្ឈការរបស់រដ្ឋាភិបាល ដែលនៅតាមភូមិឃុំនានាមានការអភិវឌ្ឍជាពិសេសទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ។ ចំណែកឯប្រជាពលរដ្ឋវិញ ក៏មានការយល់ដឹងច្រើនជាងមុនពីសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំឃុំ ។ ប៉ុន្តែនៅមានការបញ្ហាប្រឈមផ្សេងៗទៀតដែលបណ្តាលឱ្យដំណើរការឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ និងវិមជ្ឈការមានភាពយឺតយ៉ាវ ។ឧបសគ្គទាំងនោះមានដូចជា ចំណេះដឹងរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលនៅមានកម្រិតទាបនៅឡើយ ការប្រើប្រាស់អំណាច និងឥទ្ធិពលរបស់ថៅកែលើវិស័យនយោបាយ វគ្គបណ្តុះបណ្តាលផ្សេងៗដែលគ្មានភាពរលូន ឬការសហការគ្នាល្អ នយោបាយនៃថវិកាឧបត្ថម្ភរបស់គណបក្ស គួបផ្សំនឹងមូលនិធិឃុំដ៏តិចតួច ដែលធ្វើឱ្យក្រុមប្រឹក្សាឃុំមានភាពលំបាកក្នុងការឆ្លើយតបនឹងប្រជាជន វត្តមានអ្នកដឹកនាំចាស់ដដែលៗ និងការវិបាកផ្សេងៗដែលអ្នកដឹកនាំជាស្ត្រីត្រូវជួបប្រទះ ។

ជាអនុសាសន៍ រដ្ឋាភិបាល និងសង្គមស៊ីវិល គួររៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកដឹកនាំមូលដ្ឋានឱ្យមានភាពស៊ីសង្វាក់គ្នា និងមានការបែងចែកពេលវេលាទៀងទាត់ ដើម្បីបង្កើនប្រសិទ្ធិភាព និងប្រតិបត្តិការ ។ ជាងនេះទៅទៀតសិទ្ធិអំណាចរបស់ឃុំ ជាពិសេសទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ តម្រូវឱ្យមានការផ្ទេរជូនក្រុមប្រឹក្សាឃុំ/សង្កាត់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យគាត់អាចចូលរួមចំណែកការពារធនធានទាំងនេះទៅតាមច្បាប់ការងាររបស់ឃុំ ។ គុណភាពនៃការងារនេះ ត្រូវពឹងផ្អែកលើគុណភាពនៃការអនុវត្តកំណែទំរង់វិសហមជ្ឈការ ដែលនឹងចាប់ផ្តើមអនុវត្តជាផ្លូវការនៅខែឧសភា ឆ្នាំ២០០៩ ខាងមុខ ។ ម្យ៉ាងទៀត ថវិកាឃុំ/សង្កាត់មិនមានចំនួនគ្រប់គ្រាន់ទេសម្រាប់ការងារឃុំ ដូច្នេះគួរតែឱ្យឃុំមានឱកាស និងសិទ្ធិប្រមូលពន្ធដារ និងរកចំណូលជាផ្លូវការផ្សេងៗ ដើម្បីទ្រទ្រង់គម្រោងអភិវឌ្ឍន៍ឃុំ ដោយមិនពឹងផ្អែកទាំងស្រុងទៅលើប្រាក់ឧបត្ថម្ភរបស់គណបក្ស និងអ្នកនយោបាយ ។ ជាអនុសាសន៍ចុងក្រោយបង្អស់ គឺការផ្តោតទៅលើស្ត្រីនិងយែនឌ័រ ។ កត្តាជីវភាព គឺជាកត្តាចំបងដែលជាឧបសគ្គដល់ការចូលរួមក្នុងការដឹកនាំភូមិឃុំ ដូចជាបញ្ហាអនាម័យ សុខភាព និងសេដ្ឋកិច្ចគ្រួសារជាដើម ។ នៅថ្នាក់មូលដ្ឋាន បញ្ហាទាំងនេះនៅមិនទាន់ទទួលបានចំណាប់អារម្មណ៍គ្រប់គ្រាន់នៅឡើយ ដែលធ្វើឱ្យស្ត្រីនៅតែមិនអាចមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីចូលរួមជាដៃគូស្មើភាពគ្នាក្នុងការដឹកនាំភូមិឃុំជាមួយបុរស ។ ដូច្នេះ ជាជាងផ្តោតការយកចិត្តដាក់តែទៅលើការបណ្តុះបណ្តាលស្ត្រីដែលជាអ្នកដឹកនាំ រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានាក៏គួរផ្តល់អាទិភាពផងដែរ ទៅលើការលើកកម្ពស់ជីវភាព និងការរស់នៅរបស់ស្ត្រី ដែលទាំងនេះនឹងជួយលើកទឹកចិត្តនិងជំរុញឱ្យពួកគាត់ មានភាពអង់អាចក្លាហាន និងមានឱកាសបានទទួលការសិក្សាអប់រំ និងចូលរួមក្នុងការដឹកនាំភូមិ/ឃុំ បានប្រសើរជាងមុន ។

# ជំពូក ៧

# ការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជាៈ តើត្រូវចំណាយប៉ុណ្ណា?

*ដោយលោក យ៉ែម ដារារដ្ឋ អ្នកសំរបសំរួលកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន*

## ១. សេចក្តីផ្តើម

អត្ថបទនេះ វិភាគពីផលដោះដូរគ្នា (trade-off) ទាក់ទងនឹងការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា ដោយឈរលើមូលដ្ឋាននៃការវិភាគចំណាយ និងផលចំណេញ ។ ការសិក្សានេះ ក៏បានប្រៀបធៀបតំលៃដោយផ្ទាល់ និងដោយប្រយោលនៃការប្រើប្រាស់ដីកាលពីមុន ជាមួយនឹងតម្លៃនៃចំការកៅស៊ូ ដោយប្រើប្រាស់ផលចំណេញ ប៉ាន់ស្មាននៃចំការកៅស៊ូដែលមានអាយុខុសៗគ្នានៅខេត្តកំពង់ចាម និងកំពង់ធំ ។ ការសិក្សានេះ ក៏មានពិភាក្សាពីគោលនយោបាយបច្ចុប្បន្នលើដីសម្បទានសេដ្ឋកិច្ចដោយពិចារណាថា តើគោលនយោបាយកែប្រែព្រៃឈើធម្មជាតិ អាចអនុវត្តបានជាលក្ខណៈសេដ្ឋកិច្ចដែរឬទេ ។

ការសិក្សានេះរំពឹងថា នឹងអាចផ្តល់ជាព័ត៌មានស្តីពីទស្សនៈរបស់ប្រជាពលរដ្ឋមូលដ្ឋានទាក់ទងនឹងការអភិវឌ្ឍដីធ្លីដែលរដ្ឋាភិបាលកំពុងជំរុញ និងឥទ្ធិពលនៃការកែប្រែព្រៃឈើធម្មជាតិ ជាចំការកៅស៊ូ ទៅលើសហគមន៍មូលដ្ឋាន ។ ការសិក្សាក៏ផ្តល់ផងដែរនូវទិន្នន័យស្តីពីតម្លៃខាងសេដ្ឋកិច្ចនៃប្រភេទប្រើប្រាស់ដីខុសៗគ្នា ចំណាយនិងផលចំណេញនៃបំលាស់ប្តូរការប្រើប្រាស់ដី និងសេណារីយ៉ូទៅអនាគត ទាក់ទិននឹងថ្លៃជ័រកៅស៊ូ ចំការកៅស៊ូ និងដីព្រៃ ។

ការកាប់ឆ្ការព្រៃ គឺជាបញ្ហាបរិស្ថានដ៏ធំបំផុតមួយក្នុងពិភពលោក ។ ជាទូទៅ គេចាត់ទុកការអភិវឌ្ឍចំការកៅស៊ូ ជាមូលហេតុចំបងនៃការកាប់ឆ្ការព្រៃនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (Liu et al. 2006) ។ នៅប្រទេសជាច្រើនក្នុងតំបន់យើង ផ្ទៃដីចំការកៅស៊ូ បានកើនឡើងជាបណ្តើរៗ ។ កំណើនតំរូវការកៅស៊ូធម្មជាតិ និងតំលៃជ័រកៅស៊ូ គឺជាកំលាំងចំបងដែលជំរុញឱ្យមានការពង្រីកផ្ទៃដីចំការកៅស៊ូ ។

យោងតាមឯកសារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២00៦ ផ្ទៃដីសម្បទានភាគច្រើន គឺជាតំបន់គ្របដណ្តប់ទៅដោយព្រៃធម្មជាតិ ដូចអាចពិនិត្យឃើញតាមតួលេខនិយាមកា (coordinates) នៃដីសម្បទានក្នុងកិច្ចសន្យា ដោយប្រើផែនទីឌីជីថលនៃការប្រើប្រាស់ដី ដែលរដ្ឋបាលព្រៃឈើបានកសាងឡើងក្នុងឆ្នាំ១៩៩៧ ។ រឿងនេះមានន័យថា ព្រៃឈើទាំងនេះត្រូវបានកាប់ឆ្កាដើម្បីយកដីធ្វើចំការកៅស៊ូ ។ ដូច្នេះបញ្ហាសំខាន់ៗជាច្រើនក៏ចោទឡើងទាក់ទងនឹងបំលាស់ប្តូរការប្រើប្រាស់ដី ហើយក៏ផុសសំណួរដ៏តឹងតែងស្តីពី ការចំណាយនិងផលចំណេញផ្នែកសេដ្ឋកិច្ចព្រមទាំងផលប៉ះពាល់នៃការផ្លាស់ប្តូរនេះទៅលើសង្គម និងបរិស្ថាន ។

នៅពេលថ្មីៗនេះ រដ្ឋាភិបាលបានបង្ហាញឆន្ទៈយ៉ាងមុតមាំក្នុងការអនុវត្តសម្បទានដីសេដ្ឋកិច្ច និងការអភិវឌ្ឍដំណាំកៅស៊ូ ។ ការផ្តល់ដីសម្បទានកសិ-ឧស្សាហកម្មទ្រង់ទ្រាយធំៗបែបនេះ គឺសំដៅបង្កើតចំណូលរដ្ឋ លើកទឹកចិត្តសហគ្រាសឯកជន និងបង្កើតការងារសំរាប់សហគមន៍ជនបទ ហើយគេអះអាងថា វាអាចចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែក្នុងករណីសិក្សានៅទីរីង គេមានភស្តុតាងតិចតួចណាស់ដែលបង្ហាញថា គោលដៅអភិវឌ្ឍន៍នេះបានទទួលជោគជ័យ ។ម្យ៉ាងទៀតក៏មានរបាយការណ៍ថា ជាទូទៅកំរិតជីវភាពនៅក្នុងឃុំ ប្រែប្រួលកាន់តែយ៉ាប់យ៉ឺន ហើយ

បរិស្ថាននៅក្នុង និងនៅជុំវិញតំបន់ដីសម្បទាន មានការប៉ះពាល់មិនល្អ (NGOs Forum 2005) ។ ដូច្នេះ ការស្រាវជ្រាវស្តីពីចំណាយ និងផលចំណេញនៃបំលាស់ប្តូរដីព្រៃទៅជាចំការកៅស៊ូ គឺមានសារៈសំខាន់ខ្លាំងណាស់ ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងដំណាក់កាលដំបូងនៃការស្រាវជ្រាវ មានការប្រមូលព័ត៌មានទាក់ទងនឹងដីសម្បទានសេដ្ឋកិច្ច ដីព្រៃ និងចំការកៅស៊ូ ព្រមទាំងឯកសារពាក់ព័ន្ធនានា ។ ការងារនេះធ្វើឡើងតាមរយៈការសិក្សាឯកសារមានស្រាប់ ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ និងការពិភាក្សាជាមួយបុគ្គលសំខាន់ៗក្នុងវិស័យត្រូវស្រាវជ្រាវ ។ ស្ថាប័នចំបងៗសំរាប់ស្វែងរកឯកសារ ទិន្នន័យ និងធ្វើការពិភាក្សា រួមមាន អគ្គនាយកដ្ឋានចំការកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា រដ្ឋបាលព្រៃឈើ និងវិទ្យាស្ថានជាតិស្ថិតិ ។

អង្កេតដល់កន្លែង បានប្រមូលទិន្នន័យទាក់ទងនឹងប្រវត្តិនៃការអភិវឌ្ឍដំណាំកៅស៊ូ ចំណាយ និងផលចំណេញនៃចំការកៅស៊ូ ការប្រើប្រាស់ដីមុនសម័យដាំកៅស៊ូ ការយល់ឃើញរបស់ប្រជាពលរដ្ឋ ស្តីពីបំលាស់ប្តូរការប្រើប្រាស់ដី ប្រព័ន្ធដាំដុះដំណាំផ្សេងៗ ផលប៉ះពាល់នៃបំលាស់ប្តូរការប្រើប្រាស់ដីទៅលើការិតជីវភាពនៅមូលដ្ឋាន បន្ទុកចំណាយក្នុងការដាំដុះនិងថែទាំចំការកៅស៊ូជាដើម ។ ការចុះអង្កេតដល់កន្លែងចែកជា ៣ដំណាក់កាល ។

អង្កេតតាមគ្រួសារ បានប្រមូលទិន្នន័យស្តីពីផលប៉ះពាល់នៃចំការកៅស៊ូទៅលើតំបន់មូលដ្ឋាន ។ អង្កេតរួមមានការចុះសំភាសន៍ផ្ទាល់ជាមួយប្រជាជននៅមូលដ្ឋាន ដោយប្រើប្រាស់បញ្ជីសំណួរពាក់កណ្តាលរៀបរយ ។ បញ្ជីសំណួរនេះបានសាកល្បងជាមុន និងកែសំរួលរួចរាល់ ។ ក្រុមអ្នកសំភាសន៍បានទទួលការបណ្តុះបណ្តាល មុនពេលចុះធ្វើសម្ភាសន៍ដល់កន្លែង ។ អង្កេតនេះផ្តោតទៅលើភូមិចំនួន ៧ ដែលស្ថិតនៅក្នុង និងនៅជុំវិញចំការកៅស៊ូបានជ្រើសរើស ។ ក្នុងភូមិទាំង ៧ នេះ មានប្រជាជនសរុប ១៤៩០នាក់ ហើយអ្នកឆ្លើយសំភាសន៍នៅក្នុងអង្កេតគ្រួសារនេះ មាន ១៦៤នាក់ ។

បទសម្ភាសន៍ជាមួយជនគន្លឹះ បានធ្វើឡើងជាមួយមេភូមិ ឬមេឃុំ ហើយនិងបុគ្គលិក ឬកម្មករចំការកៅស៊ូ ។ ម្យ៉ាងទៀតក៏មានការស្រាវជ្រាវរក និងធ្វើសំភាសន៍តាមការសមស្របជាមួយបុគ្គលពាក់ព័ន្ធមួយចំនួនទៀត ដែលបំរើការនៅក្នុងឃុំ និងតំបន់ជិតខាង ។

## ៣. លទ្ធផល

### *៣.១ ដំណើរការកែប្រែដីធ្លី*

ចំការកៅស៊ូទីរីង ស្ថិតនៅក្នុងឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ មានចំងាយប្រមាណ ២៣០គីឡូម៉ែត្រ ភាគខាងជើងរាជធានីភ្នំពេញ ។ នៅក្នុងឃុំទីរីង មាន ៨ភូមិ គឺភូមិទំអរ វនាម វន្ទះ សំរោង ស្រឡៅស្រោង ខោស លែង និង ក្បាលដំរី និងមានប្រជាជនសរុប ៣៧២១នាក់ (៧៩៥គ្រួសារ) នៅឆ្នាំ២០០៥ ។ ឃុំនេះស្ថិតនៅចំកណ្តាល តំបន់ព្រៃធម្មជាតិធំបំផុតមួយដែលមិនទាន់អភិវឌ្ឍនៅកម្ពុជា និងមានសត្វព្រៃយ៉ាងច្រើនរស់នៅ ។

នៅដើមឆ្នាំ២០០០ រដ្ឋាភិបាលបានផ្តល់ដីក្រហមទំហំ ៦២០០ហិកតា ដល់ក្រុមហ៊ុនជុប ដើម្បីអភិវឌ្ឍដំណាំកៅស៊ូ ។ នៅខែវិច្ឆិកា ២០០០ ការសិក្សាមួយធ្វើឡើងដោយមន្ទីរកសិកម្មខេត្តកំពង់ធំ បានរកឃើញថា ដីព្រៃសម្បទានដែលផ្តល់ឱ្យក្រុមហ៊ុនជុបនេះ បានរិចរិលដល់ការិតមិនមាននៅសល់ដើមឈើមានតំលៃផ្នែក ពាណិជ្ជកម្មឡើយ ។ នៅឆ្នាំ២០០១ រដ្ឋាភិបាលបានចេញអនុក្រឹត្យដកតំបន់ដីក្រហមចេញពីដីព្រៃសម្បទាន និងបែងចែកដីទំហំ ៦២០០ហិកតា

ទៅឱ្យក្រុមហ៊ុនជុប ដើម្បីអភិវឌ្ឍចំការកៅស៊ូជាលក្ខណៈឧស្សាហកម្ម ដោយក្នុងនោះ ផ្ទៃដីប្រមាណ ១៨៤១ហិកតា ត្រូវបានផ្តល់ជូនប្រជាជនមូលដ្ឋានដើម្បីដាំដុះដំណាំកៅស៊ូជាលក្ខណៈគ្រួសារ ។ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនមិនបានផ្តល់ការបណ្តុះបណ្តាលលើផ្នែកដាំដុះកៅស៊ូ និងមិនបានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋក្នុងគម្រោងនោះឡើយ ។ គេក៏មិនឃើញមានលិខិតស្នាមជាលាយលក្ខណ៍អក្សររវាងក្រុមហ៊ុន និងប្រជាពលរដ្ឋមូលដ្ឋាន ស្តីពីចំការកៅស៊ូជាលក្ខណៈគ្រួសារនោះដែរ ។នៅឆ្នាំ២០០៧ ក្រុមហ៊ុនមានដើមកៅស៊ូដាំដុះលើដីក្រហមចំនួន ៤៣៥៩ហិកតា នៅក្នុងផ្ទៃដី ៦២០០ ហិកតា ដែលរដ្ឋាភិបាលបានផ្តល់ឱ្យ ។

សំណង គឺជាបញ្ហាដ៏ចំបងមួយសំរាប់ប្រជាពលរដ្ឋ ដែលបាត់បង់ដីធ្លីទៅលើចំការកៅស៊ូ ។ ក្រុមហ៊ុនចំការកៅស៊ូទីរីង មិនបានអនុវត្តទៅតាមកិច្ចសន្យារបស់ខ្លួនក្នុងការផ្តល់សំណងប៉ះប៉ូវដល់ប្រជាពលរដ្ឋ ក្នុងតំលៃ ១២៥ដុល្លារក្នុងមួយហិកតានោះទេ ។ ជាក់ស្តែង ក្រុមហ៊ុនបានផ្តល់សំណងខូចខាតដល់គ្រួសារប្រជាពលរដ្ឋ ដែលទទួលផលប៉ះពាល់ក្នុងតំលៃត្រឹមតែពីររវាង ១២ដុល្លារ និង ៧៥ដុល្លារក្នុងដីមួយហិកតាប៉ុណ្ណោះ ។លើសពីនេះទៀត មានប្រជាពលរដ្ឋពី២០ ទៅ ៣០គ្រួសារ មិនបានទទួលសំណងខូចខាតអ្វីសោះឡើយ ។

## ៣.២. ជីវភាពរស់នៅនៅមុនពេល និងក្រោយពេលមានចំការកៅស៊ូ

ដោយសារដីមានជីជាតិល្អ និងសំបូរទឹក អ្នកភូមិក្នុងតំបន់នោះរស់នៅដោយពឹងផ្អែកលើកសិកម្មពនេចរ និងការប្រមូលអនុផលព្រៃឈើ ។ មុនពេលមានចំការកៅស៊ូ គ្រួសារបានអង្កេត ពឹងផ្អែកជាចំបងទៅលើផលព្រៃឈើ ស្រូវវស្សា និងដំណាំលក់យកប្រាក់ ។ អ្នកឆ្លើយសំភាសន៍ ៣១% ប្រាប់ថា ស្រូវវស្សាគឺជាប្រភពចំណូលចំបងរបស់គាត់ ។ ឯ ២៨% ទៀតបានប្រាប់ថា ផលព្រៃឈើ គឺជាប្រភពចំណូលចំបង ។ ពួកគាត់ប្រមូលជ័រទឹក ប្រមាញ់សត្វ កាប់អុស និងប្រមូលអនុផលព្រៃឈើ ដូចជា វល្លិ៍ ផ្តៅ និងផ្លែឈើព្រៃជាដើម ។ ប្រជាពលរដ្ឋមួយចំនួនពឹងផ្អែកលើអាជីវកម្មខ្នាតតូច ការចិញ្ចឹមសត្វ និងការលក់កម្លាំងពលកម្ម ។

បន្ទាប់ពីមានការអភិវឌ្ឍចំការកៅស៊ូ ជីវភាពរស់នៅក្នុងតំបន់បានផ្លាស់ប្តូរយ៉ាងរហ័ស ។ ដោយសារព្រៃឈើត្រូវបានកែប្រែទៅជាចំការកៅស៊ូ មានប្រជាពលរដ្ឋត្រឹមតែ ៣% ប៉ុណ្ណោះ ដែលពឹងផ្អែកលើផលព្រៃឈើជាប្រភពចំណូលចំបង ។ ម្យ៉ាងទៀត មានប្រជាពលរដ្ឋតែ ១៩% ប៉ុណ្ណោះ ដែលពឹងផ្អែកលើផលិតកម្មស្រូវ ពីព្រោះដីស្រែមួយភាគរបស់គាត់ ត្រូវបានដកហូតទុកជាសម្បត្តិរដ្ឋ ។ ពួកគាត់មួយចំនួន មិនបានទទួលដីទំហំ ៣ហិកតា ដែលមានចែងនៅក្នុងគំរោងកែប្រែដីធ្លីឡើយ ។

ផ្អែកតាមឯកសារឆ្នាំរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGOs Forum) បន្ទាប់ពីការអភិវឌ្ឍចំការកៅស៊ូ ទិន្នផលស្រូវជាមធ្យម បានធ្លាក់ចុះពី ៨៦៤គីឡូក្រាម មកត្រឹម ៦៩៦គីឡូក្រាម ក្នុងមួយហិកតា ។ លើសពីនេះ ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រជាកសិករដាំដំណាំអ្វីផ្សេង ព្រមទាំងបញ្ឈប់រាល់សកម្មភាពនៅលើដីត្រៀមរហូតទាល់តែដីទាំងនោះបានប្រែក្លាយជាចំការកៅស៊ូ ។ ប្រជាកសិករមួយចំនួន បានចាប់ផ្តើមលក់សត្វចិញ្ចឹមរបស់ខ្លួនពីព្រោះក្រុមហ៊ុនធ្វើការផាកពិន័យ ៧៥ដុល្លារ ចំពោះកសិករណាដែលមានសត្វទៅក្នុងចំការកៅស៊ូ ។ ស្ថានភាពនេះកើតមាននៅភូមិរន្ទះ ។ អ្នកឆ្លើយសំភាសន៍ ៧៧% បានប្រាប់ថា បន្ទាប់ពីមានការបង្កើតចំការកៅស៊ូ ប្រាក់ចំណូលរបស់គ្រួសារគាត់ មិនគ្រប់គ្រាន់សំរាប់ទិញម្ហូបអាហារទេ ។ ការរកឃើញនេះ មានលក្ខណៈស្របទៅនឹងការសិក្សារបស់អង្គការ NGO Forum កាលពីឆ្នាំ២០០៥ ។

លទ្ធផលអង្កេតឆ្នាំ២០០៧ លើប្រជាពលរដ្ឋ ៦៥គ្រួសារ បានបង្ហាញថា ជាទូទៅក្រោយពីការបង្កើតចំការកៅស៊ូ ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋបានធ្លាក់ចុះ ។ ភាគរយគ្រួសារដែលរកប្រាក់ចំណូលបានតិចជាង ៣០ដុល្លារ/ខែ បានថយចុះពី ៤៤% មកត្រឹម ៤០% ក៏ពិតមែន ប៉ុន្តែចំនួនគ្រួសាររក ប្រាក់ចំណូលបានពី ១៨១ ទៅ ២៤០ដុល្លារ/ខែ បានធ្លាក់ចុះយ៉ាងខ្លាំងពី ១១% មកត្រឹម ៣% ។

**ក្រាហ្វិក ៧. ១: ប្រាក់ចំណូលគ្រួសារនៅមុនពេល (ឆ្វេង) និងក្រោយពេល (ស្តាំ) មានចំការកៅស៊ូ**




អ្នកឆ្លើយសំភាសន៍ដែលមានជីវភាពរស់នៅពាក់ព័ន្ធនឹងព្រៃឈើ កសិករធ្វើស្រែ និងអ្នកគ្មានការងារទទួលរងផលប៉ះពាល់ពីចំការកៅស៊ូ ខ្លាំងជាងក្រុមផ្សេងៗទៀត ។

អ្នកឆ្លើយសំភាសន៍ជាច្រើននាក់និយាយថា ផលចំណេញទទួលបានពីចំការកៅស៊ូ ភាគច្រើនបានទៅលើក្រុមហ៊ុនចំការកៅស៊ូទាំង ។ ក្នុងបទសម្ភាសន៍មួយ ក្រុមហ៊ុនបានបញ្ជាក់ថា ផលចំណេញក៏បានទៅដល់កម្មករ រដ្ឋបាលមូលដ្ឋាន ចំណូលពន្ធរដ្ឋ និងសេដ្ឋកិច្ចជាតិទាំងមូលដែរ ។ ក្រុមហ៊ុនបានសង្កត់ធ្ងន់ថា តាំងពីមានការបង្កើតចំការកៅស៊ូមក សន្តិសុខសង្គម និងសុវត្ថិភាពចរាចរ ក៏បានប្រសើរឡើងដែរ ហើយក្រុមហ៊ុនថែមទាំងជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់សាលារៀន និងមណ្ឌលសុខភាពទៀតផង ។

អ្នកឆ្លើយសំភាសន៍ ៦៨% បញ្ជាក់ថា ពួកម្ចាស់ចំការមិនបានចូលរួមធ្វើឱ្យជីវភាពរស់នៅក្នុងតំបន់ មានភាពប្រសើរឡើងទេ ប៉ុន្តែមាន ១៧% និយាយថា ជីវភាពរបស់គាត់ បានប្រសើរឡើងដោយសារចំការកៅស៊ូ ។ ពួកគាត់មិនមានទំនាក់ទំនងផ្ទាល់ជាមួយនឹងចំការកៅស៊ូទេ ប៉ុន្តែគាត់សង្កេតឃើញថា តាំងពីមានចំការកៅស៊ូមក មានការសាងសង់ផ្ទះថ្មីៗនៅក្នុងតំបន់នោះ ។ អ្នកឆ្លើយសំភាសន៍តែ ៥% ប៉ុណ្ណោះ ដែលនិយាយថា ចំការកៅស៊ូបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែមាន ៦៧% ផ្សេងទៀត និយាយថា មានការចូលរួមតិចតួចណាស់ ។

ផលប៉ះពាល់អវិជ្ជមានដែលមានលើកឡើងញឹកញាប់ជាងគេ គឺការបាត់បង់ដីកសិកម្ម ហើយបន្ទាប់មក គឺការរិចរិលធនធានព្រៃឈើ ។ ការបាត់បង់ប្រាក់ចំណូល ស្ថិតនៅលំដាប់ទីបីក្នុងចំណោមផលប៉ះពាល់អវិជ្ជមាន ហើយបន្ទាប់មកទៀត គឺចំណាកស្រុកជាលក្ខណៈសេដ្ឋកិច្ចចូលមកក្នុង និងចេញទៅក្រៅឃុំ ។ ចំពោះអត្ថប្រយោជន៍នៃចំការកៅស៊ូវិញ អ្នកឆ្លើយសំភាសន៍បានលើកញឹកញាប់ជាងគេពីការកាត់បន្ថយអត្រាជំងឺគ្រុនចាញ់ ហើយបន្ទាប់មកគឺ ឱកាសការងារ និងការកែលំអប្រព័ន្ធដំណាំចំរុះ និងការកែលំអជីវភាពរស់នៅ ។

អង្កេតឆ្នាំ២០០៧ បានរកឃើញ អ្នកឆ្លើយសំភាសន៍ ៥៧% ដែលយល់ថា ការកែប្រែព្រៃស្រោងទៅជាចំការ

កៅស៊ូ គឺជាការខុសឆ្គង ។ តួលេខនេះ ចុះទាបជាង ៣៣% សំរាប់ការកែប្រែព្រៃឈើប្រភេទផ្សេងទៀត ។ លទ្ធផលរកឃើញនេះបង្ហាញពីការរារែកខ្លាំងរបស់អ្នកឆ្លើយសំភាសន៍ក្នុងការផ្លាស់ប្តូរជីវភាពរស់នៅរបស់ខ្លួន ។ ព្រៃស្រោងផ្តល់នូវអត្ថប្រយោជន៍ច្រើនជាងដល់ប្រជាពលរដ្ឋ ដូចជា សំភារៈសំណង់ បន្លែ ផ្លែឈើ និងសាច់ ។ ព្រៃស្រោងក៏មានសំបូរបែបជាងគេនូវរុក្ខជាតិ និងសត្វជាច្រើនប្រភេទចំរុះគ្នា ។

អ្នកឆ្លើយសំភាសន៍ពី ១៨% ទៅ ២៦% ចាត់ទុកថា ការកែប្រែដីដាំដំណាំទៅជាចំការកៅស៊ូ គឺជាគំនិតល្អ ហើយបើសិនដកអ្នកឆ្លើយសំភាសន៍ដែលគ្មានយោបល់ចេញ អត្រានេះឡើងដល់ ៤២% ទៅ ៥៣% ។ យោបល់គាំទ្រការកែប្រែមុខដំណាំនេះ គឺផ្អែកទៅលើលទ្ធភាពអនុវត្តប្រព័ន្ធដំណាំចំរុះក្នុងចំការកៅស៊ូ ដែលផ្តល់ទិន្នផលបានប្រហាក់ប្រហែលគ្នានឹងស្ថានភាពនៅមុនពេលអភិវឌ្ឍន៍ចំការកៅស៊ូ ។

## ៤. ការវិភាគបែបសេដ្ឋកិច្ចនៃគំរោងអភិរក្សដំណាំ

ការសិក្សានេះ ផ្អែកលើលទ្ធផលនៃការសិក្សាមុនៗ ក្នុងការវាយតំលៃពីចំណាយ និងផលចំណេញនៃការអភិរក្សព្រៃឈើ ផលិតកម្មដំណាំ និងចំការកៅស៊ូធំៗ និងចំការកៅស៊ូតាមគ្រួសារ ។

### *ផលចំណេញនៃការអភិរក្សព្រៃឈើ*

ចំណូលពីការអភិរក្សព្រៃឈើ អាចបែងចែកជា ២ប្រភេទ:

- *ចំណូលផ្ទាល់ពីអនុផលព្រៃឈើ:* ការសិក្សានេះមិនបានវាយតំលៃពីផលចំណេញនេះទេហើយតំលៃអនុផលព្រៃឈើប្រមាណ ៣៧៥ដុល្លារក្នុងមួយឆ្នាំ គឺទទួលបានពីការសិក្សារបស់ Hansen និង Top (២០០៦) ។
- *ផលចំណេញខាងបរិស្ថាន:* ការសិក្សានេះមិនបានវាយតំលៃពីផលចំណេញនេះទេ ។ តំលៃផ្សេងៗទទួលបានពីការសិក្សាមុនៗដូចជា (១) Hansen និង Top (២០០៦) បង្ហាញថា ការអភិរក្សធនធានទឹកផ្តល់តំលៃ ៧០ដុល្លារ/ហិកតា/ឆ្នាំ ការអភិរក្សធនធានដីផ្តល់តំលៃ ៦០ដុល្លារ/ហិកតា/ឆ្នាំ ការស្រូបបង្ខាំងសារធាតុកាបូនគឺ ៧៥៩ដុល្លារ/ហិកតា/ឆ្នាំ ដោយមានកំណើនបន្ថែម ២%ក្នុងមួយឆ្នាំ និង (២) Bann (១៩៩៧) បង្ហាញថា ការអភិរក្សជីវចំរុះ ផ្តល់តំលៃ ៣០០ដុល្លារ/ហិកតា/ឆ្នាំ ។

### *បន្ទុកចំណាយនៃការអភិរក្សព្រៃឈើ*

បន្ទុកចំណាយក្នុងសេណារីយ៉ូនៃការអភិរក្សព្រៃឈើ អាចបែងចែកជា:

- *បន្ទុកចំណាយលើការការពារ និងរុក្ខវប្បកម្ម:* ការសិក្សានេះមិនបានវាយតំលៃពីចំណាយនេះទេ ។ តួលេខតំលៃ គឺយកចេញពីការសិក្សារបស់ Hansen និង Top (២០០៦) ។
- *ការវិនិយោគមូលធនទៅលើការប្រមូលអនុផលព្រៃឈើ:* ការសិក្សានេះមិនបានវាយតំលៃពីចំណាយនេះទេ ហើយតួលេខតំលៃ បានមកពីការគន់គូរផ្អែកលើឯកសារឆ្នាំ២០០៨ របស់វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM-LI) ។ ចំណាយទាំងនេះ ពាក់ព័ន្ធនឹងសំភារៈប្រើប្រាស់សំរាប់ប្រមូលផលព្រៃឈើ និងអនុផលព្រៃឈើ ជាពិសេស គោ រទេះ កាំបិត ពូថៅ ខ្សែពួរ ស្បែកជើង សំលៀកបំពាក់ និងមុង ។ ចំណាយទាំងនេះ កើតមានតែមួយលើកប៉ុណ្ណោះ នៅឆ្នាំដំបូង ដោយគេសន្មតថា

គោ និងរទេះ អាចប្រើរហូតដល់ចប់គំរោង ហើយកាំបិត ពូថៅ ខ្សែពួរ ស្បែកជើង សំលៀកបំពាក់ និងមុង ត្រូវផ្លាស់ប្តូរវៀងរាល់ពីរឆ្នាំម្តង ។ចំណាយក្នុងការប្រមូលផលព្រៃឈើនិងអនុផលព្រៃឈើ រួមមានចំណាយលើម្ហូបអាហារ និងការព្យាបាលសុខភាព ។

### ផលចំណេញនៃចំការកៅស៊ូធំៗ

ផលចំណេញនៃចំការកៅស៊ូធំៗ ទទួលបានតាមរយៈការលក់កៅស៊ូស្ងួត ផលិតផលបន្ទាប់បន្សំរបស់វា និងដើមកៅស៊ូចាស់ៗអាយុ២៥ឆ្នាំព្រមទាំងតាមរយៈតំលៃប្រយោលនៃការស្រូបបង្កាំងសារធាតុកាបូន ។ក្រៅពីនេះក៏អាចមានចំណូលពីការជួលដីសំរាប់ប្រព័ន្ធដំណាំចំរុះ នៅអំឡុងពេល ៣ឆ្នាំដំបូងផងដែរ ។ ប៉ុន្តែការសិក្សានេះ មិនបានគិតបញ្ចូលអត្ថប្រយោជន៍ចុងក្រោយនេះទេ ពីព្រោះវាចោទបញ្ហាច្រើន ។ ចំការកៅស៊ូធំៗមួយចំនួន បានលើកទឹកចិត្តកម្មករខ្លួនឱ្យដាំដំណាំនៅក្នុងចំការដោយមិនយកកំរៃឈ្នួលឡើយ ។

ថ្លៃផលិតផលកៅស៊ូស្ងួតនៅទីផ្សារអន្តរជាតិ ប្រែប្រួលជារៀងរាល់ខែ ហើយនៅខែមិថុនា ២០០៨ វាមានកំរិត ៣២៩០ដុល្លារ/តោន ។ការសិក្សានេះ ប្រើប្រាស់កំរិតថ្លៃជាមធ្យមក្នុងឆ្នាំ២០០៧ គឺ ២៣៣១ដុល្លារ/តោន ។ យោងតាមអង្កេតផ្ទាល់ដល់កន្លែងនៅឆ្នាំ២០០៧ ការសិក្សានេះបានសន្មតថា ថ្លៃកៅស៊ូស្ងួតនៅកសិដ្ឋាន ស្មើនឹង ៨៥% នៃថ្លៃនៅលើទីផ្សារអន្តរជាតិ ពោលគឺ ១៩៨១ដុល្លារ/តោន ។ ផលិតផលកៅស៊ូស្ងួត ចាប់ផ្តើមទទួលបានពី ០,៧២តោន/ហិកតា នៅឆ្នាំទី៦ ហើយកើនឡើងដល់ចំណុចខ្ពស់បំផុតគឺ ១,៨០តោន/ហិកតានៅឆ្នាំទី១៦ បន្ទាប់មកវាធ្លាក់ចុះមកត្រឹម ០,៧៩ តោន/ហិកតានៅឆ្នាំទី២៥ ។ ផលិតផលបន្ទាប់បន្សំរបស់កៅស៊ូ មានតំលៃស្មើនឹង ០,២% នៃតំលៃកៅស៊ូស្ងួតសរុប ។ គេប៉ាន់ស្មានថា ចំណូលទទួលបានពីការលក់ដើមកៅស៊ូចាស់ៗ គឺ ៣៣០០ដុល្លារ/ហិកតា ។

### បន្ទុកចំណាយរបស់ចំការកៅស៊ូធំៗ

បន្ទុកចំណាយនៃចំការកៅស៊ូធំៗ អាចបែងចែកជា ៦ប្រភេទគឺ (១) ការថែទាំដើមកៅស៊ូ (២) ការជ្រៀរជ័រ និងប្រមូលជ័រកៅស៊ូ (៣) សំភារៈ និងបរិក្ខារ (៤) ការកែច្នៃ និងការបង្កក (៥) ពន្ធ និង (៦) ចំណាយទូទៅ ។ ចំណាយសរុបប្រចាំឆ្នាំជាមធ្យមនៃចំការកៅស៊ូគឺ ៦២៨ដុល្លារ/ហិកតា ដែលក្នុងនេះ ចំណាយទាបបំផុតគឺ ២២៦ដុល្លារ/ហិកតា នៅឆ្នាំទី២ និងចំណាយខ្ពស់បំផុតគឺ ៨០៩ដុល្លារ/ហិកតានៅឆ្នាំទី១១ ។

### ផលចំណេញនៃចំការកៅស៊ូតាមគ្រួសារ

ចំការកៅស៊ូតាមគ្រួសារផ្តល់ផលចំណេញតាមរយៈ :

(១) ការលក់ជ័រកៅស៊ូខាប់ ក្នុងតំលៃ ០,៦៣ដុល្លារ/គីឡូក្រាម ដោយផលជ័រកៅស៊ូខាប់ប្រែប្រួលពី ១៤០០គីឡូក្រាម/ហិកតា នៅពេលដើមកៅស៊ូមានអាយុ ៦ឆ្នាំ ដល់ ៣៦០០គីឡូក្រាម/ហិកតានៅពេល វាមានអាយុ ២៥ឆ្នាំ ។

(២) ការលក់ដើមកៅស៊ូចាស់ៗក្នុងតំលៃប៉ាន់ស្មាន ៣៣០០ដុល្លារ/ហិកតា ។

(៣) ការដាំដំណាំចំរុះដូចជា សណ្តែកសៀង និងសណ្តែកបាយចំនួន ២ដងក្នុងមួយឆ្នាំ ដែលអាចលក់បានថ្លៃ ២៥០ដុល្លារ/ហិកតា/ឆ្នាំ ។ ប៉ុន្តែ ផលចំណេញចុងក្រោយនេះអាចទទួលបានតែក្នុងរយៈពេល ៣ឆ្នាំដំបូង បន្ទាប់ពី ការដាំដើមកៅស៊ូប៉ុណ្ណោះ ។

### *បន្ទុកចំណាយរបស់ចំការកៅស៊ូតាមគ្រួសារ*

ការធ្វើវិនិយោគដើម្បីបំប្លែងជ័រកៅស៊ូខាប់ទៅជាជ័រស្ងួត មានតំលៃខ្ពស់ពេកសំរាប់ចំការកៅស៊ូតាមគ្រួសារ ។ ដូចនេះ កសិករទាំងនោះតែងលក់ជ័រកៅស៊ូខាប់ទៅឱ្យឈ្មួញកណ្តាល តាមតំលៃនៅកសិដ្ឋាន ។ ចំពោះបន្ទុកចំណាយវិញ គេអាចបែងចែកជាចំណាយពលកម្ម និងចំណាយលើធាតុចូល ។ ពលកម្មសំរាប់ការដាំដុះ រួមមាន ការរៀបចំដីដាំដុះ និងការជីករណ្តៅ ។ ពលកម្មថែទាំដើមកៅស៊ូ រួមមាន ការជំរះស្មៅ ការដាក់ជី ការជួសដើមកៅស៊ូ និងការព្យាបាលជំងឺដើមកៅស៊ូ ។ ចំណាយលើធាតុចូល រួមមាន ដើមកៅស៊ូ ជី ផលិតផលគីមី និងសំភារៈប្រមូលផលកៅស៊ូ ។

## ៥. គោលនយោបាយជាអនុសាសន៍

ដោយមិនមានតួលេខប៉ាន់ស្មាននៃតំលៃការខូចខាតបរិស្ថានដោយសារការបង្កើតចំការកៅស៊ូទ្រង់ទ្រាយធំ គេគិតថាចំការប្រភេទនេះអាចផ្តល់ផលប្រយោជន៍ខាងសេដ្ឋកិច្ចបានច្រើនជាងការអភិរក្សព្រៃឈើបន្តិចបន្តួច ។ ការសិក្សានេះផ្តល់ជាអនុសាសន៍ថា អត្ថប្រយោជន៍ដែលបានមកពីចំការកៅស៊ូទ្រង់ទ្រាយធំ មួយចំណែកគួរផ្តល់ទៅឱ្យសហគមន៍ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសង្គម និងចំណាយទៅលើការអប់រំប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

ការខូចខាតដល់បរិស្ថាន ដោយសារការកែប្រែដីព្រៃឈើទៅជាចំការកៅស៊ូ មានទំហំធំធេងណាស់ ។ ដូច្នេះ ដើម្បីកាត់បន្ថយការខូចខាតនេះ សំរាប់គំរោងកែប្រែដីព្រៃឈើនានា គួរបង្កើតឱ្យមានការបង់ថ្លៃសេវាបរិស្ថាន ។

ការកែប្រែ និងការអភិវឌ្ឍដីព្រៃឈើ មិនធ្វើឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានបាត់បង់ប្រភពចំណូលរបស់ពួកគេទេ ។ ការសិក្សានេះសូមលើកជាអនុសាសន៍ថា សមាសភាគសង្គមនៃគំរោងកែប្រែដីព្រៃឈើ គួរមានអាទិភាពខ្ពស់បំផុតជាពិសេសសំរាប់សម្បទានដីសេដ្ឋកិច្ច ដើម្បីឱ្យអត្ថប្រយោជន៍ផ្សេងៗអាចធ្លាក់ ទៅដល់ដៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល គួរតែចូលរួមចំណែកក្នុងនីតិវិធីផ្តល់សំណងខូចខាត ហើយក៏គួរបង្កើតឱ្យមានកម្មវិធីតាមដានបន្ត និងផ្តល់ជំនួយបច្ចេកទេសផងដែរ ។

គេគួរជំរុញចំការកៅស៊ូតាមគ្រួសារ ឱ្យផ្តល់នូវជីវភាពប្រកបដោយចីរភាពដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ ការសិក្សានេះសូមលើកសំណើដល់រដ្ឋាភិបាល និងអ្នកអភិវឌ្ឍគំរោងនានា ឱ្យជួយជ្រោមជ្រែងដល់កសិករ ក្នុងការជំនះបញ្ហាលំបាកផ្សេងៗ ។ គំរោងរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) នៅខេត្តកំពង់ចាម គួរពង្រីកបន្ថែមទៅកាន់ខេត្តមានដីក្រហមឯទៀតៗ ។

# ជំពូក ៨

# ចំនួនម៉ោងធ្វើការ និងសុខភាពកុមារក្នុងវិស័យកសិកម្មនៅជនបទៈ ភស្តុតាងផ្អែកលើការពិសោធ និងផលប៉ះពាល់ចំពោះគោលនយោបាយ

*ដោយលោកបណ្ឌិត ហ៊ាន ភូមិន្ទ ជាអតីតអ្នកស្រាវជ្រាវ និងអ្នកសំរបសំរួលកម្មវិធីអភិវឌ្ឍន៍សង្គមនៅ វិបសអ*

## ១. សេចក្តីផ្តើម

### *១.១ សាវតារ*

កុមារនៅជនបទកម្ពុជា នៅតែចូលរួមច្រើនក្នុងវិស័យកសិកម្ម និងការងារផ្ទះ ។ ពួកគេរស់នៅយ៉ាងសាមញ្ញ និងជួយឪពុកម្តាយធ្វើការងារផ្សេងៗដែលមានចាប់តាំងពីការសាបព្រោះ រហូតដល់ច្រូតកាត់ ។ ពួកគេក៏ជួយឃ្វាលគោក្របី ប្រមូលអុស ចាប់ត្រីនិងសត្វផ្សេងៗទៀតក្រោយមកពីសាលារៀនវិញ ។ កុមារមានតួនាទីសំខាន់សំរាប់សេដ្ឋកិច្ចគ្រួសារ ព្រោះកំលាំងពលកម្មរបស់ពួកគេ មានផលប៉ះពាល់ផ្ទាល់លើសុខមាលភាពគ្រួសារ ។ សហគមន៍ចាត់ទុកកុមារដែលជាពលករក្នុងវិស័យកសិកម្ម ជាក្មេងល្អដែលយល់ពីទុក្ខលំបាករបស់ឪពុកម្តាយ ។ ដោយនៅកម្ពុជាការធ្វើស្រែចំការដើម្បីមួយរស់គេឃើញមានជាទូទៅ ដូច្នេះការចូលរួមរបស់កុមារក្នុងបរិយាកាសកសិកម្ម គឺជារឿងធម្មតា ។ ផលប៉ះពាល់នៃសកម្មភាពទាំងនេះចំពោះសុខភាពកុមារ ជាកត្តាសំខាន់មួយដែលត្រូវគិតបញ្ចូលក្នុងការកាត់បន្ថយភាពក្រីក្រ និងការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ឱ្យបានសំរេច ។

ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយ មានការសិក្សាមួយចំនួន ស្តីពីផលប៉ះពាល់នៃពលកម្មកុមារលើការបង្កើតមូលធនមនុស្ស ប៉ុន្តែការសិក្សាតិចតួចណាស់ដែលពិនិត្យពីទំនាក់ទំនងរវាងពលកម្មកុមារ និងបញ្ហាសុខភាព ។ ធៀបនឹងវិស័យដទៃទៀត កសិកម្មផ្តល់ការងារជាច្រើនដល់កុមារ ទោះបីគេបានចាត់ទុកវាថា ជាវិស័យគ្រោះថ្នាក់បំផុតសំរាប់កុមារក្តី (United States General Accounting Office 1998) ។ ផលប៉ះពាល់នៃពលកម្មកុមារនៅប្រទេសកំពុងអភិវឌ្ឍពិសេសពលកម្មកុមារក្នុងវិស័យកសិកម្មនៅជនបទ ហាក់ដូចជាត្រូវបានមើលរំលងពីសំណាក់ច្បាប់ពលកម្មនៅកម្ពុជាបច្ចុប្បន្ន ។ ផលប៉ះពាល់នៃពលកម្មលើសុខភាពកុមារក្នុងរយៈពេលវែង មានការប៉ាន់ស្មានទាបជាងការពិត ដោយសារការធ្វេសប្រហែស និងទស្សនៈដែលថា តាមរយៈការងារកសិកម្ម កុមារនឹងទទួលបានចំនេះធ្វើពីឪពុកម្តាយ ហើយពួកគេអាចត្រៀមខ្លួនសំរាប់ពេលធំពេញវ័យ (Satz 2003) ។ ជាក់ស្តែងក្នុងការសិក្សាថ្មីៗភាគច្រើនស្តីពីផលប៉ះពាល់នៃពលកម្ម កុមារលើសុខភាព គេបានសន្មតថា វាមានតែលក្ខណៈវិជ្ជមាន (Guarcello et al. 2004) ។ អង្គការពលកម្មអន្តរជាតិ (ILO, 1998) រាយការណ៍ថា កុមារនៅទូទាំងពិភពលោកកំពុងប្រឈមនឹងគ្រោះថ្នាក់អំពីបរិយាកាសការងាររបស់ពួកគេ ដូចជា ការប្រើថ្នាំគីមីសំលាប់សត្វល្អិត ការលើកដាក់ឥវ៉ាន់ធ្ងន់ៗ ការប្រើប្រាស់គ្រឿងចក្រដោយមិនបានហ្វឹកហាត់ត្រឹមត្រូវ ការត្រូវកំដៅថ្ងៃខ្លាំង ព្រមទាំងកង្វះខាតទឹក និងអនាម័យ ។

ពលកម្មកុមារក្នុងវិស័យកសិកម្ម ជារឿយៗមានម៉ោងធ្វើការយូរ ចាប់តាំងពីវ័យក្មេងៗ ។ នៅតណ្ហាពលករកុមារក្មេងៗ (អាយុខ្ទង់ ១១ឆ្នាំ) ជារឿយៗធ្វើការ ១៦ រឺ ១៧ម៉ោងក្នុងមួយថ្ងៃ (Human Rights Watch 2002) ។ Guarcello et al. (២០០៤) បានរកឃើញថា ម៉ោងធ្វើការជះឥទ្ធិពលខ្លាំងលើលទ្ធភាពមានផលប៉ះពាល់អវិជ្ជមានលើសុខភាព ។ ទោះបីជា ពលកម្មកុមារក្នុងវិស័យកសិកម្មនៅតែមានពាសពេញបណ្ដាប្រទេសកំពុងអភិវឌ្ឍ ហើយកុមារមួយចំនួនកំពុងប្រឈមនឹងគ្រោះថ្នាក់ក្នុងការងារក្ដី ក៏ហាក់មានមតិស្របគ្នាថា ការងារកសិកម្មអាចមានផលប៉ះពាល់វិជ្ជមានតាមរយៈការពង្រឹងវិន័យ ទំនួលខុសត្រូវ ទំនុកចិត្តខ្លួនឯង និងឯករាជភាព និងការបង្រៀនកុមារនូវជំនាញកសិកម្មពីសំណាក់ឪពុកម្ដាយ ។ ផ្ទុយទៅវិញ ពលកម្មកុមារ អាចផ្ដល់ផលប៉ះពាល់អវិជ្ជមានលើសុខភាព និងការលូតលាស់ (Parker 1997; ILO 1998) ។ សុខភាព និងសុខមាលភាពរបស់គ្រប់ក្រុមអាយុទាំងអស់សុទ្ធតែមានសារៈសំខាន់ តែក្នុងនោះ ការលូតលាស់ក្នុងវ័យកុមារ និងវ័យជំទង់ គឺជាគ្រឹះសំខាន់សំរាប់ពេលពេញវ័យ ។ O'Donnell et al. (២០០៣) បានរកឃើញភស្តុតាងតិចតួចណាស់ស្ដីពីផលប៉ះពាល់ភ្លាមៗចំពោះសុខភាព សំរាប់ករណីពលករកុមារវៀតណាមក្នុងវិស័យកសិកម្ម ប៉ុន្តែគាត់រកឃើញថា ពលកម្មក្នុងវ័យកុមារនេះបង្កើនហានិភ័យមានជំងឺរហូតដល់ទៅ ៥ឆ្នាំក្រោយមកទៀត ហើយហានិភ័យនេះកើនឡើងទៅតាមរយៈពេលធ្វើការ ។ ផ្ទុយទៅវិញ Fentiman et al. (២០០២) បានរកឃើញថា គ្មានអ្វីខុសគ្នាទេរវាងខាងការរីកធំធាត់របស់កុមារ ដែលបានចុះឈ្មោះចូលរៀនសាលា និងកុមារដែលមិនបានចុះឈ្មោះចូលរៀន (ដោយសន្មតថា កុមារដែលមិនបានចុះឈ្មោះចូលរៀន គឺជាប់ទៅធ្វើការ) ។

ការសិក្សាមួយចំនួន បានកត់ត្រាពីផលប៉ះពាល់វិជ្ជមាននៃកំរិតអប់រំរបស់ឪពុកម្ដាយទៅលើការលូតកំពស់របស់កូន (Cochran et al. 1982) ។ ការសិក្សាជាច្រើនទៀតបានលើកឡើងថា កំរិតអប់រំគ្មានជះឥទ្ធិពលអ្វីដោយផ្ទាល់លើការលូតលាស់ឡើយ ប៉ុន្តែវាតំណាងអោយអថេរមិនបានសង្កេតពិនិត្យមួយចំនួន ដូចជា សុខភាពមាតាជាដើម (Wolfe&Behrman 1987) ។កាន់តែច្បាស់ជាងនេះទៀត Thomas et al. (១៩៩១) គេបានរកឃើញថា ផលប៉ះពាល់ស្ទើរតែទាំងអស់នៃកំរិតអប់រំរបស់ម្ដាយ អាចបកស្រាយបានតាមសូចនាករនៃការទទួលព័ត៌មាន (ដូចជា ការអានសារព័ត៌មាន ការមើលទូរទស្សន៍ និងការស្ដាប់វិទ្យុជាដើម) ។Blunch (២០០៤) បានរកឃើញថា នៅប្រទេសហ្គាណា ការដែលឪពុកម្ដាយចេះអាន ចេះសរសេរ និងគិតលេខ មានផលប៉ះពាល់វិជ្ជមានលើស្ថានភាពសុខភាពបណ្ដោះអាសន្នរបស់កុមារ (ការថែទាំ និងការចាក់វ៉ាក់សាំង មុននិងក្រោយពេលសំរាលកូន) និងសុខភាពដាច់ណាត់កុមារ (ជំងឺ និងមរណភាព) ។ ដោយសារម្ដាយ ជាញឹកញាប់ចំនាយពេលនៅជាមួយកូនច្រើនជាងឪពុក ដូច្នេះ កំរិតអប់រំរបស់ម្ដាយជះឥទ្ធិពលខ្លាំងលើសុខភាពកូន ។ Maitra (២០០៤) បានរកឃើញថា កំរិតអប់រំរបស់ស្ត្រីមានឥទ្ធិពលលើការថែទាំសុខភាពជាងកំរិតអប់រំរបស់ប្ដី ហើយការត្រួតត្រារបស់ស្ត្រីលើធនធានក្នុងផ្ទះ (សមត្ថភាពទុកដាក់លុយកាក់) ក៏មានឥទ្ធិពលខ្លាំងលើការថែទាំសុខភាពដែរ ។Glewwe (១៩៩៩) បានរកឃើញថា នៅប្រទេសម៉ារុក ចំនេះដឹងរបស់ម្ដាយខាងផ្នែកសុខភាពនេះ ហាក់ដូចជាចាំបាច់ណាស់ក្នុងការចិញ្ចឹមបីបាច់កូនៗអោយមានសុខភាពល្អ ។

នេះជាការសិក្សាដំបូងបំផុត ពីផលប៉ះពាល់ខាងសុខភាពនៃពលកម្មកុមារក្នុងវិស័យកសិកម្ម ដោយផ្អែកលើម៉ោងធ្វើការ ហើយប្រធានបទនេះមិនធ្លាប់ឃើញមានក្នុងឯកសារស្ដីពីពលកម្មកុមារពីមុនមកទេ ។ ការសិក្សានេះក៏ពិសេសផងដែរ ព្រោះថា មានការចុះអង្កេតមួយបានធ្វើឡើងនៅខែតុលា ២០០៦ ដើម្បីបំពេញកង្វះខាតមួយចំនួនក្នុងការសិក្សាមុនៗ ។ឧទាហរណ៍ ទោះបីជាការសិក្សារបស់ Guarcello et al. (២០០៤) បានលើកឡើងពីសារៈសំខាន់នៃការស្វ័យវាយតំលៃពីសុខភាពទូទៅ និងការវាស់វែងពីកំពស់និងទំងន់ស្តង់ដារតាមអាយុនិងភេទក្តី (BMI-age) ក៏

ពួកគេគ្មានទិន្នន័យបែបនេះឡើយ ដូច្នេះហើយក៏ប្រើប្រាស់ជំងឺនិងរបួសដែលបានស្វ័យរាយការណ៍ឡើង ជាតំណាងជំនួសអោយវិញ ។ កន្លងមកគេបានដឹងជាទូទៅពី ការដោះដូររវាងសុខភាព និងម៉ោងធ្វើការរបស់កុមារក៏ពិតមែន ប៉ុន្តែការសិក្សានេះ បានបង្កើតនូវកំរិតម៉ោងធ្វើការ ដែលអាចជួយសំរួលដល់អ្នកកសាងគោលនយោបាយក្នុងការបង្កើតច្បាប់ វិធីតិវិធីថ្មី សំរាប់ពលកម្មកុមារក្នុងវិស័យកសិកម្ម ។ ការសិក្សានេះបានជួយបង្កើនប្រភពឯកសារស្តីពីពលកម្មកុមារក្នុងវិស័យកសិកម្ម ហើយលទ្ធផលរកឃើញក៏ស្របគ្នានឹង ការសិក្សាមុនៗដែរ ។ ការសិក្សានេះរកឃើញទៀតថា ពលកម្មកុមារក្នុងវិស័យកសិកម្មពិតជាមានផលប៉ះពាល់លើសុខភាពកុមារមែន ប្រសិនបើកុមារធ្វើការលើសពី ២,៥ម៉ោងក្នុងមួយថ្ងៃ ។ កត្តាកំណត់សំខាន់ៗផ្សេងទៀតបានបង្ហាញថា សុខភាពកុមាររងផលប៉ះពាល់ខ្លាំងពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ ដូចជា វិទ្យុ ទូរទស្សន៍ និងសារព័ត៌មានជាដើម ។ ការសិក្សាក៏លើកឡើងពីកត្តាកំណត់មួយចំនួនទៀតខាងសុខភាពកុមារដែរ ដូចជា ទឹក និងអនាម័យ ។ ជាចុងក្រោយ ការសិក្សាមានផលប៉ះពាល់ចំពោះគោលនយោបាយខាងការការពារពលករកុមារក្នុងវិស័យកសិកម្មនៅកម្ពុជា ។

### ១.២. គោលបំណងនៃការសិក្សា

ការសិក្សានេះសំដៅផ្តល់ភស្តុតាងពីពលកម្មកុមារក្នុងវិស័យកសិកម្មនៅជនបទកម្ពុជា និងផលវិបាកចំពោះសុខភាព ។ ពលកម្មកុមារក្នុងវិស័យកសិកម្មផ្តល់ផលប៉ះពាល់អវិជ្ជមានដល់សុខភាព ប្រសិនបើកុមារទាំងនោះ ត្រូវប្រឈមនឹងស្ថានភាព មានគ្រោះថ្នាក់ (ILO ១៩៩៨) ។ពលកម្មកុមារក្នុងវិស័យកសិកម្ម នៅតែជាប្រពៃណីរបស់កម្ពុជា ហើយអ្នកភូមិយល់ថា ការរួមចំណែករបស់កុមារក្នុងសេដ្ឋកិច្ចគ្រួសារនិងពលកម្មប្រចាំថ្ងៃ ជាការងារស្រាលចាំបាច់ និងជួយសំរាលកំលាំងពលកម្មមនុស្សចាស់ ។ ការសិក្សានេះ ស្រាវជ្រាវតាមដានពីពលកម្មកុមារក្នុងវិស័យកសិកម្មនៅកម្ពុជា ដូចខាងក្រោម:

១. កត្តាកំនត់ពីសុខភាពកុមារ និងភាពខុសគ្នានានាខាងផ្នែកសុខភាពរវាងកុមារធ្វើការងារកសិកម្ម និងកុមារដែលមិនធ្វើការ ។
២. កំរិតម៉ោងសំរាប់ពលកម្មកុមារក្នុងវិស័យកសិកម្ម ដែលមិនប៉ះពាល់ដល់ការលូតលាស់ និងសុខភាពរបស់កុមារ ប្រសិនបើពលកម្មនេះមានផលប៉ះពាល់ដល់សុខភាពមែន ។
៣. ផលប៉ះពាល់ចំពោះគោលនយោបាយ ។

## ២. ទិន្នន័យ និងអថេរ

ដោយមានសាស្ត្រាចារ្យ Seiichi Fukui ជួយដឹកនាំនិស្សិតបញ្ចប់ការសិក្សាមួយក្រុមរួមទាំងអ្នកនិពន្ធអត្ថបទនេះផង បានចុះអង្កេតដល់កន្លែងលើកដំបូងនៅខែតុលា ២០០៦ នៅ ៤ភូមិ គឺភូមិព្រៃចង្ក្រា ភូមិកាន់តម្រា ភូមិត្រពាំងក្រឡឹង នៅខេត្តកំពង់ស្ពឺ និងភូមិកល់គម នៅខេត្តតាកែវ ។ លក្ខណៈរបស់អង្កេតនេះ គឺប្រមូលទិន្នន័យគ្រួសារបែបសេដ្ឋកិច្ច-សង្គមកិច្ច ដោយមានម៉ូឌុលជាច្រើនដូចជា ប្រព័ន្ធធ្វើសិកម្ម ចំណាយប្រើប្រាស់ក្នុងគ្រួសារ ចំណាកស្រុក ពលកម្មកុមារក្នុងវិស័យកសិកម្ម សុខភាពកុមារ និងមូលធនសង្គម ។ យើងបានសម្ភាស ១៦៨គ្រួសារ និងកុមារអាយុពី៥-១៤ឆ្នាំ ចំនួន ២១៤នាក់ ក្នុងនោះ កុមារីមាន ១០៧នាក់ និងកុមារា ១០៧នាក់ ។ កុមារភាគច្រើនក្នុងការសិក្សារបស់យើង មិនបានប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត រឺដំណើរការគ្រឿងចក្រអ្វីឡើយ (មើលតារាង ៨. ១) ។ កុមារ

៩៩នាក់ក្នុងគំរូរបស់យើងមិនធ្វើការ និង ១១៥នាក់ទៀតកំពុងធ្វើការ ។ យើងបានអោយនិយមន័យ "កុមារធ្វើការ" ស្របគ្នានឹងនិយមន័យក្នុងអនុសញ្ញា ILO លេខ ១៣៨ និងអង្កេតពលកម្មកុមារនៅកម្ពុជាឆ្នាំ២០០១-២០០២ (NIS 2002) ។ តាមនេះ កុមារពាក់ព័ន្ធនឹងសកម្មភាពកសិកម្មផ្សេងៗ ត្រឹមតែ ១ម៉ោង ក្នុង៧ថ្ងៃមុនក្តី ក៏ចាត់ទុកថាជាកុមារកំពុងធ្វើការដែរ ។

**តារាង ៨.១: ចំនួន និងភាគរយកុមារអាយុពី ៥-១៤ឆ្នាំ គិតតាមប្រភេទកុមារដែលដំណើរការគ្រឿងចក្រ និងថ្នាំសំលាប់សត្វល្អិត**

| | មិនដំណើរការគ្រឿងចក្រ | ដំណើរការគ្រឿងចក្រ | សរុប |
|---|---|---|---|
| មិនបានប្រើថ្នាំសំលាប់សត្វល្អិត | 190 | 0 | 190 |
| | 100.00 | 0.00 | 100.00 |
| | 90.48 | 0.00 | 88.79 |
| បានប្រើថ្នាំសំលាប់សត្វល្អិត | 20 | 4 | 24 |
| | 83.33 | 16.67 | 100.00 |
| | 9.52 | 100.00 | 11.21 |
| សរុប | 210 | 4 | 214 |
| | 98.13 | 1.87 | 100.00 |
| | 100.00 | 100.00 | 100.00 |

*ប្រភព: តាមការគណនារបស់អ្នកនិពន្ធ បានពីទិន្នន័យអង្កេតឆ្នាំ២០០៦*

យើងបានប្រើសូចនាករសំខាន់ៗពីរសំរាប់សុខភាពកុមារ ។ ទីមួយ យើងបានអោយកុមារវាយតំលៃពីសុខភាពរបស់ខ្លួនគេផ្ទាល់ ។ ដោយផ្អែកលើមូលដ្ឋាននេះ កុមារ ១៥១នាក់មានសុខភាពល្អ និង ៦៣នាក់ទៀតមានសុខភាពមិនល្អ ។ ទីពីរ យើងបានប្រើសូចនាករការវាស់វែងពីការលូតលាស់រាងកាយរបស់ BMI តាមអាយុ ។ យើងរកឃើញថាកុមារជិតដល់ ៤៧% មានទំងន់មិនគ្រប់ និងប្រហែល ៥០% មានទំងន់ធម្មតា ហើយកុមារ ៣% ទៀតកំពុងស្ថិតក្នុងហានិភ័យនៃការលើសទំងន់ ។ យើងក៏បានរកឃើញកុមារប្រហែល ៧៤% ទទួលបានអាហារមិនគ្រប់គ្រាន់ និងមានតែ ២៦% ប៉ុណ្ណោះ ដែលស្ថិតក្នុងក្រុមកុមារមានការលូតលាស់ធម្មតា ។ "កំពស់តាមអាយុ" វាស់វែងពីផលប៉ះពាល់នៃកង្វះអាហារនៅអតីតកាលរបស់កុមារ ។

## ៣. សេចក្តីសន្និដ្ឋានរបកគំហើញ

ការសិក្សានេះ បានចាប់ផ្តើមពីការកំណត់នូវកង្វះខាតក្នុងការសិក្សាមុនៗស្តីពីពលកម្មកុមារក្នុងវិស័យកសិកម្ម និងផលប៉ះពាល់លើសុខភាពកុមារ ។ ចំពោះខាងឯកសារវិញ សៀវភៅ រឺឯកសារស្តីពីផលប៉ះពាល់នៃពលកម្មកុមារក្នុងវិស័យកសិកម្មទៅលើសុខភាព គឺមិនសូវមានទេ ។ ម្យ៉ាងទៀត ការសិក្សានេះ បានចុះអង្កេតដល់កន្លែង ដើម្បីបំពេញកង្វះខាតនានាក្នុងការសិក្សាមុនៗ ។

របកគំហើញនៃការសិក្សានេះ បានជួយបង្កើនឯកសារស្តីពីពលកម្មកុមារជាទូទៅ និងផលប៉ះពាល់ចំពោះសុខភាពជាពិសេស ។ ការរកឃើញនេះ គឺស្របគ្នានឹងការសិក្សារបស់ O'Donell et al. (២០០៣) ដែលរកឃើញភស្តុតាងតិចតួចពីផលប៉ះពាល់ភ្លាមៗចំពោះសុខភាពនៃពលកម្មកុមារក្នុងវិស័យកសិកម្មនៅវៀតណាម ប៉ុន្តែរកឃើញភស្តុតាងថា ការធ្វើការក្នុងវ័យកុមារបង្កើនហានិភ័យមានជំងឺរហូតដល់ ៥ឆ្នាំក្រោយមក ហើយហានិភ័យនេះកើនឡើងទៅតាមរយៈពេលធ្វើការ ។ Ham (២០០៨) បានរកឃើញថា ពលកម្មកុមារជួយបង្កើនមូលធនមនុស្ស ព្រោះថា ការអប់រំរបស់កុមារ ជាកត្តាសំខាន់មួយដែលកំណត់ពីកំរិតប្រាក់ឈ្នួលរបស់ពួកគេ ។ នេះជាហេតុផលដែលជំរុញឱ្យក្រុមគ្រួសារសំរេចចិត្តឱ្យកូនរៀនបណ្តើរ ធ្វើការបណ្តើរ និងដែលឪពុកម្តាយបន្តវិនិយោគលើការអប់រំរបស់កូនៗ ។ ម្យ៉ាងទៀត គ្រួសារក្រីក្រមិនមានលទ្ធភាពអោយកូនៗទៅរៀន ដោយគ្មានធ្វើការងារគួបផ្សំនឹងការសិក្សាឡើយ ។ រាល់គោលនយោបាយដែលសំដៅលុបបំបាត់ពលកម្មកុមារក្នុងវិស័យកសិកម្ម ត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីការពារផលប្រយោជន៍របស់កុមារ ដូចជាការសិក្សា និងសុខភាពជាដើម ។

ការសិក្សាថ្មីនេះ បញ្ជាក់ថា ពលកម្មកុមារក្នុងវិស័យកសិកម្ម មានផលប៉ះពាល់អវិជ្ជមានលើសុខភាពកុមារ ប្រសិនបើកុមារធ្វើការក្នុងវិស័យកសិកម្មលើសពី ២,៥ម៉ោងក្នុងមួយថ្ងៃ ។ ដោយសារចំនួនម៉ោងធ្វើការជាមធ្យមរបស់កុមារក្នុងវិស័យកសិកម្ម គឺប្រហែល ២,៥ម៉ោងក្នុងមួយថ្ងៃ ដូច្នេះការរកឃើញនេះជួយផ្តល់ព័ត៌មានដល់អ្នកបង្កើតគោលនយោបាយថា ត្រូវមានគោលនយោបាយសំដៅគាំពារពលករកុមារក្នុងវិស័យកសិកម្ម ។ ការសិក្សានេះក៏បានស្នើឡើងថា កម្ពុជាគួរតែអនុវត្តតាមអនុសាសន៍របស់អង្គការពលកម្មអន្តរជាតិ (ILO, ១៩៩៨) ដែលថាការចូលរួមរបស់កុមារក្នុងវិស័យកសិកម្ម អាចបង្កការគំរាមកំហែងដល់សុខភាពកុមារយោងតាមបរិយាកាសធ្វើការរបស់ពួកគេ ។ ការរកឃើញក៏បានស្នើឡើងថា កុមារគួរអនុញ្ញាតឱ្យធ្វើការត្រឹមកំរិត ២,៥ម៉ោងក្នុងមួយថ្ងៃនៅរដូវធ្វើកសិកម្ម ព្រោះពលកម្មរបស់ពួកគេអាចជួយសំរាលកំលាំងពលកម្មមនុស្សពេញវ័យ និងជួយដល់សេដ្ឋកិច្ចគ្រួសារ ។

ការសិក្សានេះ ក៏រកឃើញដែរថា ការបំបៅដោះកូន ការចូលរួមរបស់គ្រួសារក្នុងកម្មវិធីបណ្តុះបណ្តាលពីការថែទាំសុខភាព លទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ចំណូលគ្រួសារ ការចាក់ថ្នាំបង្ការ និងអាយុមេគ្រួសារ គឺជាកត្តាសំខាន់ៗបំផុតដែលជួយឱ្យកុមារមានសុខភាពល្អ ។ ការសិក្សានេះជួយផ្តល់ជាគំនិតខ្លះៗពីផលប៉ះពាល់ខាងគោលនយោបាយនៃបញ្ហាសុខភាពកុមារនៅតាមជនបទប្រទេសកម្ពុជា ។

## ៤. ផលប៉ះពាល់ចំពោះគោលនយោបាយ

ការសិក្សានេះ មានផលប៉ះពាល់ខាងគោលនយោបាយ ដូចតទៅនៅកម្ពុជា:

*៤.១:* កំណើនចំនួនម៉ោងពលកម្មកុមារក្នុងវិស័យកសិកម្ម មានផលប៉ះពាល់អវិជ្ជមានលើសុខភាពកុមារ ។ គោលនយោបាយសំដៅគាំពារពលករកុមារក្នុងវិស័យកសិកម្ម ដែលធ្វើការលើសពី ២,៥ម៉ោងក្នុងមួយថ្ងៃ ចាំបាច់ត្រូវបង្កើតឡើង ។ ដោយសារកុមារភាគច្រើននៅជនបទកម្ពុជា ជួយទ្រទ្រង់ដោយផ្ទាល់ដល់សេដ្ឋកិច្ចគ្រួសារ រឺជួយដល់គ្រួសារនៅរដូវធ្វើកសិកម្ម ដូច្នេះរាល់កិច្ចប្រឹងប្រែងសំដៅលុបបំបាត់ពលកម្មកុមារ រឺដាក់កំហិតលើការចូលរួមរបស់កុមារក្នុងវិស័យកសិកម្ម ត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្នបំផុត ព្រោះថា អាចប៉ះពាល់ដល់មធ្យោបាយរកចិញ្ចឹមជីវិតរបស់ពួកគេ ។ ការជ្រៀតជ្រែកចូលក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់គ្រួសារ រឺសហគមន៍ អាចមិនបានការពារ

ផលប្រយោជន៍របស់កុមារយ៉ាងល្អបំផុតនោះទេ ហើយអាចបំពានលើមាត្រា ៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលចែងថា រាល់អន្តរាគមន៍ត្រូវតែបានជាប្រយោជន៍ល្អបំផុតដល់កុមារ ។

*៤.២:* រាល់គោលនយោបាយ គួរអនុញ្ញាតឱ្យកុមារធ្វើការមិនលើសពី ២,៥ម៉ោងក្នុងមួយថ្ងៃ នៅអំឡុងរដូវធ្វើកសិកម្ម ។ ការដាក់កំហិតលើការចូលរួមរបស់កុមារនៅអំឡុងពេលធ្វើកសិកម្ម មានផលប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ព្រោះថា តាំងពីយូរយារណាស់មកហើយ ប្រជាជនតែងប្រើពលកម្មកុមារ ដើម្បីជួយសំរាលកំលាំងពលកម្មមនុស្សពេញវ័យ ។

*៤.៣:* កំណើនលទ្ធភាពបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់គ្រួសារ ទំនងជួយបង្កើនប្រូបាបប៊ីលីតេកុមារមានសុខភាពល្អ ហើយវាក៏ផ្តល់ផលប្រយោជន៍ច្រើនទៀតដល់ឯកជន និងសង្គម ។ ទី១ គ្រួសារអាចរៀនពីរបៀបរបបល្អៗនៃការថែទាំសុខភាពពីកម្មវិធីសុខភាពក្នុងទូរទស្សន៍ សារព័ត៌មាន និងវិទ្យុ ។ ទី២ ប្រព័ន្ធផ្សព្វផ្សាយ ផ្តល់ព័ត៌មានថ្មីៗទាន់ពេលស្តីពីការរាតត្បាតនៃជម្ងឺផ្តាសាយបក្សី មេរោគហ៊ីវ/អេដស៍ និងជម្ងឺផ្សេងៗទៀតដែលប្រជាជនត្រូវយកចិត្តទុកដាក់ខ្ពស់ ។ ទី៣ ប្រព័ន្ធផ្សព្វផ្សាយជួយធានាឱ្យមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធ ជាមួយនឹងការអភិវឌ្ឍសង្គមថ្មីៗ ជាពិសេសគំរូអភិវឌ្ឍន៍នៅតាមតំបន់នីមួយៗ ។

*៤.៤:* ទឹកស្អាត និងអនាម័យ មានផលប៉ះពាល់ច្រើនទៅលើកំណែលំអសុខភាពកុមារ ។ ដូចនេះ គោលនយោបាយគួរសំដៅបង្កើនការយល់ដឹងជាសាធារណៈ ពីរបៀបរបបល្អក្នុងការថែទាំសុខភាពទាំងនេះ និងបង្កើនលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យនៅតាមតំបន់ជនបទ ។

## បញ្ជីឯកសារបោះពុម្ពផ្សាយរបស់ CDRI


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ។

៤. ជីម-ចរិយា ស្រ៊ុន-ពិចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ីដឹលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាខ្មែរថ្លៃ ៩.000រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.000រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ីៈ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥00រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ៅ (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.000រៀល ។

៩. តេង-យូគី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១0. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១0) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.000រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ៅ សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥00រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរតំលៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរថ្លៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធទេព-សាវ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផលទេព-សាវ៉ាវីនិង Sarthi Acharya (ធ្នូ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និងសុក-ហាច (មីនា២០០២) *ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផលនិង Sarthi Acharya (កក្កដា២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា: ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ជាអង់គ្លេសតំលៃ ៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ: ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម: ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.០០០រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ: ការវិភាគលើ ការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាខ្មែរតំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា: ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាខ្មែរ ៥.០០០រៀល ជាអង់គ្លេស ៥ដុល្លារ ។

៣០. Caroline Hughes និង គីម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K.A.S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា: ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Kasper K. Hansen និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (ឯកសារពិភាក្សាលេខ៣៣) ជាភាសាអង់គ្លេស ៨,០០ដុល្លារ ។

៣៤. ប៉ក់-គឹមជឿន ហ៊ង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គីម-សេតារា, Jenny Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦ដុល្លារ ។

៣៥. គីម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) ***Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia*** (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស ៤ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) ***Youth Migration and Urbanisation in Cambodia*** (ឯកសារពិភាក្សាលេខ ៣៦) ជាភាសាអង់គ្លេស ៣,៥ដុល្លារ ។

៣៧. Brett M. Ballard, Christian Sloth, David Wharton, Ingrid FitzGerald, K.A.S Murshid, Kasper K. Hansen, ភីម-រុនស៊ីណារិទ្ធិ និង លឹម-សុវណ្ណារា (មេសា ២០០៧) ***"We Are Living with Worry All the Time": A Participatory Poverty Assessment of the Tonle Sap (PPA)*** ជាភាសាអង់គ្លេស ១៨ដុល្លារ ។

៣៨. Ingrid FITZGERALD និង សូ-សុវណ្ណារិទ្ធិ (កញ្ញា ២០០៧) ***Moving Out of Poverty: Trends in Community Well-Being and Household Mobility in Nine Cambodian Villages (MOPs)*** ជាភាសាអង់គ្លេស ២០ដុល្លារ ។

៣៩. CDRI (ធ្នូ ២០០៧) ***Cambodia Land Titling Rural Baseline Survey Report*** ជាភាសាអង់គ្លេស ៧ដុល្លារ ។

៤០. CDRI (ធ្នូ ២០០៧) ***Cambodia Land Titling Urban Baseline Survey Report*** ជាភាសាអង់គ្លេស ៧ដុល្លារ ។

៤១. Chem Phalla *et al.*, *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* (Working Paper No. 37)

៤២. Pak Kimchoeun and David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38)

៤៣. Horng Vuthy and David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39)

៤៤. CDRI, *Impact of High Food Prices in Cambodia*

៤៥. Eng Netra and David Craig (forthcoming), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40)

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ / ០១២ ៨៦៧-២៧៨

🖷 (៨៥៥-២៣) ៨៨០-៧៣៤

E-mail: cdrimail@online.com.kh

Website: http://www.cdri.org.kh





តំលៃ ៨.000រៀល

9 789995 052164